



# មនុស្ស ជាមួយ នឹង ការងារ

# មនុស្សជាមួយនឹងការងារ

≈α≈α≈α≈α≈α≈

មនុស្សអត់ការងារជាមនុស្សអន់ ជាមនុស្សទ្រមក់ ប៉ុន្តែបើមានការងារអាក្រក់ ទុច្ចរិតទៅវិញនោះ ជាមនុស្សគម្រក់តែម្តង ដេកលក់វិញប្រសើរជាង ។

ការងារបែងចែកមនុស្សលោកឱ្យខ្ពង់ខ្ពស់ ឬថោកទាប ដូច្នេះសូមមនុស្សលោកទាំងឡាយ ខំប្រឹងប្រែងលះបង់នូវការងារណាដែលសៅហ្មង ដើម្បីឱ្យខ្លួនឯងបានសណ្តករបូតរួចផុតអំពីភាពនៃបុគ្គលថោកទាប ហើយខំប្រឹងប្រែងព្យាយាមក្នុងការងារណាដែលបរិសុទ្ធ ប្រាសចាកទោស ឱ្យបានទៅជាមនុស្សឧត្តុង្គឧត្តម ខ្ពង់ខ្ពស់ រស់នៅដោយក្តីស្ងប់ រីករាយជានិច្ច ដោយមកអំពីបានពិចារណាឃើញអំពើដ៏បរិសុទ្ធរបស់ខ្លួនឯង ។

## មនុស្សយើងត្រូវតែយកចិត្តទុកដាក់ចំពោះ

**ការងារ** ជាពិសេសគឺការងារដែលខ្លួនឯងកំពុងធ្វើ បើការងារនោះប្រាសចាកនូវទោសហើយ ទោះជាការងារអ្វីក៏ដោយ កុំឱ្យមើលងាយថា អន់ឬថោកទាបឱ្យសោះ ត្រូវចេះស្រឡាញ់ការងារនោះ ព្រោះមិនមានអ្នកណាម្នាក់គាំទ្រយើងឱ្យខ្ពង់ខ្ពស់ ក្រៅអំពីខ្លួនឯងដែលគោរពនូវការងាររបស់ខ្លួនឡើយ ។ ការងារអ្វីក៏ដោយ ក៏ត្រូវចាប់ផ្តើមពីដំបូងទៅដែរ ហើយរាល់ការងារទាំងអស់ វាតែងតែមាននូវឧបសគ្គមករារាំងជាធម្មតា ប៉ុន្តែថា បើមានការព្យាយាម និង សេចក្តីអត់ធន់ហើយ ការងារនោះរមែងបានសម្រេច មានលទ្ធផលល្អគួរជាទីគាប់ចិត្ត ផ្ទុយមកវិញ មនុស្សដែលមិនយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួន មិនខុសអំពីមនុស្សដែលអត់ការងារឡើយ ហើយមិនយូរប៉ុន្មាន អ្នកនោះនឹងទៅជាមនុស្សបាត់បង់នូវការងារ ក្លាយទៅជាមនុស្សពិការទាំងដែលនៅមានអវយវៈគ្រប់គ្រាន់ ខ្លាចលំបាកហើយខ្ជិលមិនព្យាយាម មិនរួចអំពីសេចក្តីលំបាកឡើយ ខ្វះខន្តីសេចក្តីអត់ធន់ ការងារមិនបានល្អ ខ្វះការតស៊ូ ការងារមិនសម្រេច រវល់តែរឿងស្នេហា កាន់ការងារធំមិនបាន ព្រោះសេចក្តីប្រហែសធ្វេស ការងារដែលចេះស្ទាត់ហើយនោះត្រឡប់ទៅជាបរាជ័យដូចបុគ្គលល្ងង់ខ្លៅ ។

## ការងារមានតម្លៃចំពោះមនុស្សនៅត្រង់ណា?

ទ្រព្យសម្បត្តិជាលទ្ធផលរបស់ការងារក៏ពិតមែនហើយ ប៉ុន្តែទ្រព្យសម្បត្តិមិនមែនអាចជួយឱ្យមនុស្សអស់ការសៅហ្មងបានឡើយ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

បើបាត់បង់ស្មារតី  បុរសស្ត្រីនឹងដល់នូវសេចក្តីសៅហ្មងដោយសារ ទ្រព្យសម្បត្តិនោះឯង សូមមនុស្សទាំងអស់គ្រប់គ្នា កុំធ្វើការងារ ដើម្បីបានទ្រព្យសម្បត្តិតែម្យ៉ាងឱ្យសោះ  តែត្រូវធ្វើការងារដើម្បី រំដោះខ្លួនឯងឱ្យរួចអំពីការសៅហ្មង  ប្រៀបបីដូចពពួកប្រេតដែល សុំឱ្យញាតិធ្វើបុណ្យឧទ្ទិសឱ្យ  ដើម្បីខ្លួនបានរួចអំពីទីដ៏ថោកទាប ដូច្នោះឯង  នេះជាតម្លៃនៃការងារ ដែលមានសម្រាប់មនុស្សគ្រប់ គ្នា យើងអាចធ្វើបុណ្យឧទ្ទិសឱ្យដល់ប្រេតជាញាតិ សុំឱ្យពួកប្រេត ជាញាតិ  រួចចាកអំពីទីឋានដែលបានទៅកើតជាប្រេតនោះ  ប៉ុន្តែ សូមមនុស្សលោកកុំភ្លេចធ្វើបុណ្យឧទ្ទិសឱ្យខ្លួនឯង  ដើម្បីខ្លួនឯង បានរួចអំពីមនុស្សប្រេតក្នុងជាតិនេះផង។  អ្នកដទៃធ្វើល្អមកលើ យើង គឺ វាល្អពិតហើយ ប៉ុន្តែមិនមែនជាអំពើល្អរបស់យើងឡើយ មនុស្សមិនមាននូវអំពើល្អខ្លួនឯង  មិនអាចជួយខ្លួនឯងបានទេ ទាំងអ្នកដទៃក៏មិនអាចជួយបានដែរ  ។  គុណតម្លៃនៃការងារ មនុស្សគ្រប់គ្នាត្រូវសិក្សាស្វែងយល់ឱ្យបានប្រាកដច្បាស់  បើពុំ ដូច្នោះទេ  ប្រាកដជាយល់ថាការងារបំរើតណ្ហា  ជាការងារមាន តម្លៃទៅវិញ។

ដើម្បីឱ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះបរមពោធិ-



សត្វបានធ្វើការងារច្រើនណាស់  ទាំងឋិតនៅក្នុងពេលវេលាដ៏យូរ អង្វែងក្រៃលែង  គ្រប់ការអស្ចារ្យនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់  គឺ ជាលទ្ធផលនៃការងារដែលព្រះអង្គបានធ្វើ  កាលដែលព្រះអង្គនៅ ជាព្រះពោធិសត្វនៅឡើយ  ។  ក្នុងពេលនេះយើងមិនអាចធ្វើជា ព្រះពុទ្ធទៅបានទេ ប៉ុន្តែយើងអាចធ្វើនូវការងារ ដែលការងារនោះ អាចជួយឱ្យយើងបានដល់នូវឋានៈដែលយើងត្រូវការ ។

នៅក្នុងលោកនេះ  មិនមានអ្វីដែលយើងបានមកដោយ ឯងៗ  ដែលមិនមែនជាលទ្ធផលនៃការងាររបស់ខ្លួនឯងនោះទេ គ្រាន់តែថា  ការងារនោះ  មានការងារខ្លះយើងបានធ្វើហើយក្នុង ជាតិនេះ  និងមានការងារខ្លះទៀត  យើងបានធ្វើអំពីជាតិមុនមក ការយល់ដឹងអំពីលទ្ធផលនៃការងារយ៉ាងនេះ រមែងកាត់បន្ថយនូវ តណ្ហា ដែលតែងប្រាថ្នាក្នុងវត្ថុទាំងពួងមិនមានទីបំផុតនោះ ឱ្យថយ កម្លាំង ហើយបានញ៉ាំងសេចក្តីសន្តោសឱ្យចំរើន ព្រោះហេតុតែការ បានយល់ដឹងនោះឯង ។

**សេចក្តីសុខរបស់មនុស្សជាប់ទាក់ទងជាមួយនឹង ការងារប្រាសចាកទោស**  សេចក្តីសុខព្រោះមានទ្រព្យសម្បត្តិ ប្រើប្រាស់ បរិភោគមិនអស់ មិនចេះខ្វះ  ប៉ុន្តែបើប្រៀបជាមួយនឹង

ការងារប្រាសចាកទោសវិញ សេចក្ដីសុខដែលជាប់ទាក់ទងជាមួយនឹងទ្រព្យសម្បត្តិ មានទំហំតូចជាសេចក្ដីសុខតិចតួចទេ ចំណែកការងារប្រាសចាកទោសវិញនោះ នាំមកនូវសេចក្ដីសុខដ៏ទូលំទូលាយ ទាំងដែលជាសេចក្ដីសុខបរិសុទ្ធទៀតផង ។ សូមមនុស្សលោកទាំងឡាយ នាំគ្នាគោរពបូជានូវការងារប្រាសចាកទោស ត្រូវរក្សាខ្លួនដោយខ្លួនឯង កុំព្រោះតែប្រាក់ព្រមលក់ខ្លួនឱ្យថៅកែបាប ពោលគឺហ៊ានធ្វើការងារប្រកបដោយទោសនោះឱ្យសោះ ។ ការងារប្រាសចាកទោសគឺជាព្រះមួយអង្គ គង់នៅជួយថែរក្សាចំពោះមនុស្សណា ដែលធ្វើការងារប្រាសចាកទោសនោះឯង ។ ការងារប្រាសចាកទោស ជាអ្នកបង្កើតមនុស្សលោកគ្រប់គ្នា ព្រមទាំងពពួកទេវតាទាំងអស់ផងដែរ ។ ការងារប្រាសចាកទោសបានជួយមនុស្សដែលបំរុងធ្លាក់នរកទៅហើយនោះ ឱ្យបានជាទេវតាវិញ ។ ការងារប្រាសចាកទោសគឺជាកំពង់ទឹក ដែលសំរាប់ចុះទៅលាងបាប ។

**អំពីការខារចាយទាយទ្រព្យសម្បត្តិ** ទ្រព្យសម្បត្តិដែលបានមកអំពីការងារប្រាសចាកទោស មនុស្សយើងមិនត្រូវធ្វេសប្រហែសឡើយ មិនមែនមិនឱ្យអស់ទេ ប៉ុន្តែត្រូវអស់ក្នុងហេតុដែលគួរ ហើយចាំបាច់ត្រូវតែឱ្យអស់ទៀតផង ហេតុដែលគួរមាន ៤ប្រការគឺ :

១- ចិញ្ចឹមជីវិតខ្លួនឯង ចិញ្ចឹមមាតាបិតា បុត្រភរិយា ទាសកម្មករ អ្នកដែលមកអាស្រ័យជាមួយនិងញាតិមិត្ត ឬអ្នកដទៃណា១ដែលខ្លួនសមគួរនឹងចិញ្ចឹម ឱ្យបានឆ្អែត រស់នៅជាសុខសម្រាន្ត ។

២- ចាយវាយប្រើប្រាស់ដោយការឆ្លាតឈ្លាស ដើម្បីជួយខ្លួនឯងឱ្យផុតអំពីរឿងអន្តរាយ មានការអន្តរាយព្រោះភ្លើង ព្រោះទឹក ព្រោះចោរជាដើម បានសេចក្ដីថា ចាយទ្រព្យដើម្បីការពារទ្រព្យ ។

៣- ចាត់ចែងជួយសង្គ្រោះញាតិ សម្រាប់ទទួលភ្ញៀវ សម្រាប់ធ្វើបុណ្យឧទ្ទិសដល់អ្នកស្លាប់ ឧទ្ទិសដល់ទេវតា និងចាត់ចែងជួយប្រទេសជាតិទៀតផង ។

៤- បរិច្ចាគធ្វើទានឱ្យដល់សមណព្រាហ្មណ៍ ជាការបរិច្ចាគដ៏ខ្ពង់ខ្ពស់ ព្រោះបូជាគុណមានសីលគុណជាដើម ដែលគុណនេះមានអំណាចអានុភាពដ៏ក្រៃលែង អាចញ៉ាំងមនុស្សធម្មតាម្នាក់ឱ្យបានទៅជាព្រះសម្មាសម្ពុទ្ធ ឬព្រះបច្ចេកពុទ្ធ ជាបុគ្គលបរិសុទ្ធ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ផុតលោក ។

ការងារចាត់ចែងចាយវាយនូវទ្រព្យសម្បត្តិ ប្រព្រឹត្តទៅសមគួរតាមហេតុយ៉ាងនេះ ទ្រព្យសម្បត្តិនោះឈ្មោះថាអស់ទៅដោយប្រពៃ ។ ត្រូវប្រយ័ត្នការពារទ្រព្យសម្បត្តិ កុំឱ្យវិនាសដោយសារការប្រព្រឹត្តនូវអបាយមុខ ៨ប្រការគឺ :

១- លេងស្រី

២- លេងទឹកស្រវឹង សេពគ្រឿងញៀនផ្សេងៗ

៣- ដើរស៊ីចាយសប្បាយក្នុងការបរិភោគ ជាអ្នកលេងស៊ី

៤- លេងល្បែងស៊ីសង ល្បែងភ្នាល់ផ្សេងៗ

៥- ត្រាច់ទៅតាមច្រកល្ហករឿយៗនៅពេលយប់

៦- ដើរមើលមហោស្រពល្បែងរបាំរាំរែករឿយៗ

៧- ប្រកបរឿយៗនូវសេចក្តីខ្ជិល

៨- សេពគប់បាបមិត្ត ។

អបាយមុខទាំងអស់ មិនមែននាំឱ្យវិនាសតែទ្រព្យសម្បត្តិទេ វាថែមទាំងបញ្ចុះតម្លៃនៃជីវិតរបស់ខ្លួន និង គ្រួសាររបស់ខ្លួន កាត់បន្ថយនូវស្មារតីដែលជារបស់មានតម្លៃបំផុតសម្រាប់ជីវិតមនុស្សទៀតផង ។



អបាយមុខជាខ្លោងទ្វារនៃនរក ជាមេរោគ ជាបាបមិត្តដឹកនាំឱ្យធ្វើការងារប្រកបដោយទោស ជាប្រធាននៃសេចក្តីវិនាសគ្រប់យ៉ាង តាមពិតមនុស្សយើងមិនគួរបៀតបៀនខ្លួនឯងឡើយព្រោះមិនមានអ្នកណាជាទីស្រឡាញ់របស់យើង ជាងខ្លួនយើងទេមិនមានអ្នកណាជួយយើង ឱ្យដូចជាខ្លួនឯងឡើយ បើខ្លួនឯងមិនជួយខ្លួនឯងហើយ ព្រះណាក៏ជួយយើងមិនរួចដែរ ។

**អំពីការខារសេពគប់មិត្ត** មិនសេពគប់នឹងបាបមិត្ត បើសេពគប់ ត្រូវសេពជាមួយបណ្ឌិត ប៉ុន្តែសូមប្រយ័ត្នកុំឱ្យបាបមិត្តក្លាយជាសត្រូវ បើនៅតែមានសូមចៀសឱ្យឆ្ងាយ បើចៀសមិនផុតត្រូវមានស្មារតីគ្រប់ពេល ។ ត្រូវរៀនឱ្យស្គាល់មនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ការងារនេះសំខាន់ណាស់ កុំប្រហែសឱ្យសោះ មនុស្សដូចម្តេចទើបជាមិត្តពិតប្រាកដ ព្រោះមនុស្សខ្លះជាមិត្តក្នុងរោងស្រា ខ្លះទាល់តែមានការពឹងពាក់ទើបមករាក់ទាក់ហៅយើងថាមិត្តៗ មនុស្សខ្លះហៅយើងថាសម្លាញ់ចំពោះមុខ ប៉ុន្តែក្រោយខ្នងចងអាឃាតព្យាបាទ ច្រណែន ចង់ឱ្យយើងវិនាសទ្រព្យ គាប់ចិត្តនិងយើងធ្លាក់បុណ្យធ្លាក់ស័ក្តិ ។

ក បុគ្គលដែលជាមិត្តគិតយកតែប្រយោជន៍ខ្លួន១ បុគ្គល

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដែលជាមិត្តល្អតែសំដី១ បុគ្គលដែលនិយាយចាក់បណ្តោយឱ្យគាប់ចិត្ត១ បុគ្គលដែលជាមិត្តសម្លាញ់ក្នុងផ្លូវវិនាស១ បុគ្គលទាំង៤ពួកនេះ យើងត្រូវដឹងថា មិនមែនជាមិត្តពិតប្រាកដទេ គ្រាន់តែជាមិត្តប្លម ហើយគប្បីចៀសវាងឱ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

**I- បុគ្គលដែលជាមិត្តពិតយកតែប្រយោជន៍ខ្លួន មានលក្ខណៈ ៤ យ៉ាងគឺ :**

**១. អញ្ញទត្ថុហរោ ហោតិ** គិតចង់បានអ្វីៗអំពីមិត្តតែម្យ៉ាង ដោយសេចក្តីថា ជាអ្នកមានដៃទទេមកកាន់ផ្ទះរបស់សម្លាញ់ ហើយពោលសរសើររបស់នេះ របស់នោះ ដែលជាសម្បត្តិទ្រព្យរបស់សម្លាញ់ ឬក៏និយាយថា មានអ្នកដទៃសរសើរយ៉ាងនេះយ៉ាងនោះ ជួនកាលក៏ចាប់កាន់បបោសអង្អែល ស្ទើរសុំស្ទើរមិនសុំរហូតទាល់តែបានសម្រេចសមតាមបំណង ។ មនុស្សណាដែលហៅយើងថាមិត្តៗ ប៉ុន្តែចង់តែបានសម្បត្តិទ្រព្យរបស់យើង មនុស្សនោះជាមិត្តប្លម មិនមែនជាមិត្តពិតប្រាកដទេ បើយើងឱ្យញយៗ ថ្ងៃក្រោយសុំត្រង់ៗតែម្តង មនុស្សនេះឱ្យមិនចេះគ្រប់ទេ ថ្ងៃណាឈប់ឱ្យ គេដើរនិយាយប្រាប់គេឯងថាយើងអាក្រក់ចិត្តមិនបាន ខ្វេះកកាយរឿងនេះរឿងនោះសម្អុយឈ្មោះយើង នេះហើយទោសរបស់ **អភិជ្ឈា** យើងវិញក៏អញ្ចឹងដែរ ត្រូវការពារឱ្យណាស់ ចំពោះអភិជ្ឈានេះ ព្រោះវាអាចឱ្យយើងលួចប្រាក់គេទាំងដែលមិនដឹងថាខ្លួនឯងជាចោរទៀតផង ។

**២. អប្បេន ពហុមិច្ឆតិ** ប្រាថ្នាចង់បានរបស់ច្រើនៗអំពីសម្លាញ់ ដោយគ្រាន់តែឱ្យអ្វីៗដល់សម្លាញ់បន្តិចបន្តួចប៉ុណ្ណោះ គឺយករបស់តូចទាក់យករបស់ធំ ។

**៣. ភយស្ស កិច្ចំ ន ករោតិ** មិនជួយធ្វើកិច្ចការសម្លាញ់នៅពេលដែលសម្លាញ់មានភ័យ មនុស្សរបៀបនេះ គឺទាល់តែមានវិបត្តិអ្វីមួយខ្លួនឯង ទើបរត់មកជួយធ្វើកិច្ចការងារឱ្យយើង មិនមែនជួយដោយស្មោះ ស្រឡាញ់យើងទុកជាមិត្តពិតប្រាកដនោះទេ។

**៤. សេវតិ អត្ថការណា** សេពគប់មិត្តព្រោះហេតុតែប្រយោជន៍ផ្ទាល់ខ្លួន មនុស្សរបៀបនេះ មិនឃើញគុណតម្លៃនៃចិត្តសប្បុរសរវាងគ្នានិងគ្នាទេ គេមករាប់អានយើងព្រោះយើងមានលុយ ឬអ្វីៗដែលគេចង់បានអំពីយើងតែប៉ុណ្ណោះ ។

ការងារជ្រើសរើសមិត្ត ជួនកាលមួយជីវិតរកមិត្តពិត



Document Produced by deskPDF Unregistered :: http://www.docudesk.com

ប្រាកដតែម្នាក់មិនបានផង មានមិត្តខ្លះតណ្ហាក្រាស់ក្បត់ចិត្តយើង ប៉ុន្តែវាអាចមកអំពីខ្លួនយើងផងដែរ ដែលរកមនុស្សល្អមកធ្វើជាមិត្តមិនបាន ព្រោះមារយាទយើងវាអន់ពេក ដូច្នេះដើម្បីកុំឱ្យខកខានមិនបានមិត្តល្អ ត្រូវអធិដ្ឋានចិត្តខ្លួនឯង យកកុសលធម៌ជាមិត្តដោយការប្រព្រឹត្តជួយខ្លួនឯង បើយើងប្រព្រឹត្តល្អជាប់លាប់ហើយបាបមិត្តរមែងឃ្លាតឆ្ងាយអំពីយើង ម្តងម្នាក់ៗ ទីបំផុតយើងនឹងបានមិត្តដ៏ល្អជាពុំខាន ក្នុងសេចក្តីនេះសំខាន់គឺជួយខ្លួនឯងជាមុនសិន ។

**II- បុគ្គលដែលជាមិត្តល្អតែសំដី មានលក្ខណៈ ៤ យ៉ាងដែរគឺ :**

**១. អតីតេន បដិសន្ថរតិ** មិត្តទទួលរាក់ទាក់ដោយរបស់ដែលអស់ទៅហើយ មនុស្សប្រភេទល្អតែមាត់ តែចិត្តមិនប្រាកដឃ្លេងឃ្លោងពុតត្បុត និយាយបោកបញ្ឆោត មនុស្សពួកនេះចេះសង្គ្រោះយើងចំពោះតែរបស់ដែលអស់ទៅហើយតែប៉ុណ្ណោះយ៉ាងនេះថា «ទាល់តែថ្ងៃហ្នឹងទើបសម្លាញ់ឯងមក ម្សិលម៉្ងៃម៉េចក៏មិនមក ខ្ញុំខំតែរៀបចំទុកដាក់ស្រូវអង្ករ ផ្លែដូងផ្លែខ្នុរ រើសសុទ្ធតែសម្រាំងៗល្អៗ ទុកឱ្យសម្លាញ់ឯងហ្នឹងណា៎ ហើយម៉េចក៏មិនឆាប់មក ចំជាស័យមែនសម្លាញ់ឯងនេះ ព្រោះចៃដន្យអី ទើបតែម្សិលមិញហ្នឹង គេចេះតែមកអង្វរសួររកទិញពេក គ្នាក៏លក់អស់ទៅ» ។

**២. អនាគតេន បដិសន្ថរតិ** មិត្តទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក មនុស្សរបៀបនេះ តែងតែសន្យាថានឹងឱ្យ ប៉ុន្តែគេចេះមានល្បិចលេបពាក្យលេបសម្តី គេមិនបានឱ្យតម្លៃជីវិតរបស់គេនៅលើការងាររក្សាពាក្យសម្តីឡើយ មិនមែនបានសេចក្តីថា គេមិនស្រឡាញ់ខ្លួនរបស់គេនោះទេ ប៉ុន្តែនេះគឺមកអំពីខ្វះការចេះដឹងរបស់គេហ្នឹងឯង មនុស្សនេះយកជាការពុំបានឡើយ ខ្មោចកណ្តុរប្រសើរជាងមនុស្សនិយាយកុហកបោកប្រាស់ បើយើងយកវាទៅកប់ក្នុងដីចំការ ។

**៣. និរត្ថកេន សង្គណ្ហាតិ** សង្គ្រោះដោយអំពើមិនជាប្រយោជន៏ មនុស្សល្អតែសម្តី និយាយអ្វីៗយកគាប់យកគួរ ប៉ុន្តែខ្លឹមសារចាញ់ក្អាត់យំតាមវាលស្រែសន្ទូង ស្រូវបែកគុម្ព វាញូរងំពីរោះជាង ព្រោះថាមនុស្សរបៀបនេះ បើគេនៅលើផ្ទះ រួចហើយយើងក៏ទៅដល់ គេហៅយើងដោយពាក្យរាក់ទាក់ដូច្នេះថា «យីអើ! សម្លាញ់ទេតើ ចូរឡើងមកសម្លាញ់ ចូរអង្គុយទីនេះចុះ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ម៉េចទៅសម្លាញ់ភ្ជួរបានប៉ុន្មានស្រែហើយ ? គ្នាឥឡូវធូរកម្លាំងច្រើនណាស់ ដោយសារបានអាត្រាក់ទ័រមួយហ្នឹងមក សម្លាញ់អើយ សម្លាញ់ឯងហ្នឹង បើបានតែមួយគ្រឿងសម្រាប់ភ្ជួរចំណាប់តែម្តង នៃសម្លាញ់! បើគ្នាមានពីរគ្រឿង គ្នាឱ្យទៅសម្លាញ់ឯងមួយគ្រឿង មែនណា៎ ឱ្យវាណាណើម្តង » ទីបំផុតយើងអត់ដដែល យើងកាន់តែដឹងថា អ្នកដែលអាចជួយយើងបានពិតប្រាកដ គឺខ្លួនយើងហ្នឹងហើយ ដូច្នេះមានតែយើងកុំខ្ជិល ប្រឹងប្រែងធ្វើការងារគាំទ្រនូវការងាររបស់ខ្លួន មានតែការងាររបស់ខ្លួនយើងទេដែលសង្គ្រោះយើងបានពិតប្រាកដ ត្រូវចេះមានអំណត់កុំមើលងាយការងាររបស់ខ្លួនឯងថាអន់ ហើយទៅសរសើរតែការងាររបស់អ្នកដទៃនោះ តាមពិតជីវិតយើងរស់សព្វថ្ងៃ ដោយសារតែការងាររបស់យើងប៉ុណ្ណោះ សេចក្តីនេះមិនខុសអំពីម៉ែយើងចិញ្ចឹមយើង ចំណែកម៉ែអ្នកដទៃចិញ្ចឹមអ្នកដទៃ ទោះជាម៉ែអ្នកដទៃនោះមានសម្បត្តិទ្រព្យច្រើនរាប់កោដិយ៉ាងណាក៏ដោយ តែយើងមិនត្រូវតិះដៀល ម៉ែយើងដែលក្រីក្រនោះទេ ព្រោះថាយើងបានរស់ដោយសារម៉ែកំសត់របស់យើងជាអ្នកចិញ្ចឹម ។

**៤- បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ** កាលកិច្ចទាំងឡាយ កើតឡើងភ្លាមៗ ក៏សម្តែងអាងរបស់ខូចខាត ។

មនុស្សនេះយើងពឹងពាក់អ្វីយកជាការពុំបានឡើយ ប៉ុន្តែគេបានសម្តីណាស់ ដោយសារយើងធ្លាប់ជួយគេច្រើន គេនិយាយសូមទោសយើង គេថា « សូមទោសចុះសម្លាញ់អើយ រទេះគ្នានោះវាបរលែងកើតទៅហើយ ស្តាយមែនទែន បើនៅប្រើកើតនោះ គ្នាមានទៅកំណាញ់អី គ្នាគិតថាធ្វើវាដែរណា៎ ប៉ុន្តែមួយថ្ងៃជាមួយថ្ងៃវាចេះតែរវល់ » នេះបើយើងមានការប្រញាប់ចង់ខ្ចីរទេះរបស់មិត្តប្លួមនោះ ។

អំពីមិត្តល្អតែសំដីនេះ វាមានលក្ខណៈយ៉ាងណាមួយក្នុងលក្ខណៈ ៤ យ៉ាង ដូចបានរៀបរាប់ហើយ ពោលគឺចិត្តមិនស្មោះមិនត្រង់តាមពាក្យសម្តី តាមពិតមានមនុស្សច្រើនណាស់ ដែលមានចិត្តស្រកេកស្រកាកទៅដោយល្បិច មានបំណងបំភ្លេចគុណគឺសេចក្តីល្អរបស់អ្នកដទៃ ប៉ុន្តែគេមានពាក្យសម្តីជារនាំងបិទបាំងខ្លួនរបស់គេ ដោយគេចូលចិត្តនិយាយលើកជើងលើកដៃ សរសើរបញ្ជោរចំពោះមិត្តភក្តិ យើងត្រូវតែប្រយ័ត្នឱ្យណាស់ចំពោះមនុស្សដែលមិនមានចិត្តស្មោះត្រង់ចំពោះយើង គេអាចបោកយើងប្រើឱ្យធ្វើការងារប្រកបដោយទោសបាន បើយើងមិនបានពិនិត្យឱ្យដិត



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដល់ យើងអាចរងគ្រោះបានគ្រប់ពេលវេលា បើយើងមិនបានប្រយ័ត្ន ជូនកាលពាក្យសម្តីដែលយើងបាននិយាយ វាអាចជាចំណុចខ្សោយរបស់យើង ត្រូវប្រយ័ត្នកុំអាងទុកចិត្តអ្នកនេះអ្នកនោះ ហើយចេះតែពីនិយាយមិនគិត ម្យ៉ាងទៀតបើមានគេបបួលយើងឱ្យធ្វើការងារអ្វីៗ បើមានមន្ទិលសង្ស័យក្នុងការងារនោះ ត្រូវរកអ្នកដទៃទៀតដែលយើងទុកចិត្តជាងគេ ពិគ្រោះពិភាក្សាឱ្យបានច្រើននាក់ ជាពិសេសគឺមាតាបិតារបស់យើង កុំធ្វើអ្វីស្រេចតែចិត្តឱ្យសោះ ព្រោះមនុស្សចាស់ៗគាត់មានការពិសោធន៍ច្រើនជាងយើងដែលនៅវ័យក្មេង យើងត្រូវបន្ទាបខ្លួនទទួលយកពាក្យប្រៀនប្រដៅអំពីមនុស្សចាស់ កុំអាងខ្លួនឯងបានរៀនសាលាច្រើនជាងគាត់ ហើយមើលងាយចំណេះដឹងរបស់គាត់ តាមពិតកូនប្រុសស្រីត្រូវសូមពាក្យទូន្មានប្រៀនប្រដៅ អំពីមាតាបិតាជីដូនជីតាឱ្យបានច្រើនបំផុត នៅពេលដែលយើងចូលទៅបំរើគាត់ មានពេលច្របាច់ដៃច្របាច់ជើងជូនគាត់ជាដើមនោះ ព្រោះគាត់ស្រឡាញ់យើងដោយស្មោះ ហ៊ានប្តូរជីវិតចំពោះយើងទៀតផង ។

**III–បុគ្គលដែលជាមិត្ត និយាយចាក់បណ្តោយឱ្យតែគាប់ចិត្ត មានលក្ខណៈ៤យ៉ាងដូចនេះគឺ:**



**១.បាបកម្មំបិស្ស អនុជានាតិ** យល់ព្រមឱ្យមិត្តធ្វើបាប មនុស្សណាដែលអនុញ្ញាតឱ្យយើងធ្វើនូវបាបកម្ម មានការសម្លាប់សត្វជាដើម ដើម្បីផ្គាប់ចិត្តយើង ក៏ដូចជាអនុញ្ញាតឱ្យយើងទៅកើតក្នុងឋាននរក ប្រេតអ៊ីចឹងដែរ ។

ពាក្យសរសើរនៅក្នុងលោកមានច្រើនណាស់ ហើយវាជាគ្រឿងនាំឱ្យស្រវឹង នាំឱ្យវង្វេងដ៏ក្រៃលែងទៀតផង មានមនុស្សច្រើនណាស់ដែលស៊ីជោរ ទីបំផុតត្រូវបរាជ័យក្នុងការងាររបស់ខ្លួន ព្រោះខ្លួនឯងមានចំណុចខ្សោយ ។ តាមពិតមនុស្សយើងមិនមែនល្អបរិសុទ្ធដោយសារពាក្យសរសើរ ឬពាក្យបញ្ជោរទេ ពិតមែនតែមានពេលខ្លះ បានធ្វើឱ្យយើងមានកម្លាំងចិត្តខ្លាំងក្លាក្នុងការងារដោយសារពាក្យសរសើរក៏ដោយ ប៉ុន្តែដែលយើងជាមនុស្សល្អបរិសុទ្ធពិតនោះ គឺព្រោះយើងមានការងារប្រាសចាកទោសឯណេះទេតើ មិនមែនដោយសារគេថាយើងល្អ យើងក៏ល្អតាមគេថានោះទេ បើមនុស្សអាក្រក់ឬល្អតាមតែពាក្យរបស់អ្នកដទៃ សូម្បីព្រះសម្មាសម្ពុទ្ធក៏មិនផុតពីការសៅហ្មងដែរ តែនេះពុំមែនដូច្នោះឡើយ មានតែការងារប៉ុណ្ណោះដែលរៀបចំមនុស្សឱ្យជាបុគ្គលសៅហ្មង ឬបុគ្គលបរិសុទ្ធ ។

**២. កល្យាណកម្មំបិស្ស អនុជានាតិ** យល់ព្រមឱ្យមិត្ត ធ្វើនូវអំពើល្អ ការយល់ព្រមនេះមិនមែនដោយចិត្តសប្បុរស ក្នុងនាមជាមិត្តចិត្តល្អនោះទេ បើជាមិត្តពិតជាអនុគ្រោះយើងមែន មិនមែនពេលខ្លះព្រមឱ្យយើងធ្វើបាប ដោយមិនបានហាមឃាត់នោះឡើយ ។

យើងត្រូវតែប្រយ័ត្នឱ្យណាស់ ចំពោះមនុស្សខ្លះដែលនិយាយចាក់បណ្តោយ គេមិនមានគំនិតចង់ឱ្យយើងចំរើននោះទេ គេមានតែត្រេកអរនៅពេលណាដែលយើងធ្លាក់ដុនដាប ចំពោះមិត្តប្លមគេមានចិត្តគិតប្រឡងប្រណាំងជាមួយយើងជានិច្ច នៅពេលដែលយើងមានលំនឹង ឬកំពុងចំរើនគេមិនចោលយើងទេ គេពឹងយើងលិទ្ធដៃលិទ្ធជើង នៅពេលណាដែលយើងចុះខ្សោយឬមានសេចក្តីប្រមាទភ្លាំងភ្លាត់បន្តិចបន្តួចនៅក្នុងការងារ គេជួយច្រានយើងដោយពាក្យសរសើរ ក្នុងគោលបំណងកុំឱ្យយើងមើលឃើញនូវការប្រហែសធ្វេសរបស់យើង លុះដល់កំហុសយើងកាន់តែច្រើន ដើម្បីជ័យជំនះរបស់គេមកលើយើង គឺគេដើរខ្សឹបប្រាប់អ្នកដទៃ នូវអ្វីៗដែលជាសេចក្តីប្រមាទធ្វេសប្រហែសរបស់យើង ថែមទាំងប្រឌិតរឿងអាស្រូវមិនពិតផ្សំបញ្ចូលទៀតផង គឺដល់ពេលដែលគេធាក់យើងឱ្យខ្ទាត ដើម្បីគេបានកន្លែងនោះ ព្រោះគេឃ្លានយូរហើយ ។

មានបុគ្គលខ្លះមិនហ៊ានហាមឃាត់យើងដែលធ្វើនូវអំពើឆ្គាំឆ្គង ប៉ុន្តែមិនប្រាកដជាយល់ព្រមឱ្យយើងប្រព្រឹត្តនោះឡើយ មកអំពីគេខ្លាចយើងខឹង ខ្លាចយើងស្អប់គេ បានជាគេមិនហ៊ានឃាត់ គេអាចធ្វើជាមិត្តល្អបាន បើគេព្យាយាមដឹកនាំឱ្យយើងស្តាប់ធម៌រៀនធម៌ គេសរសើរយើងក្នុងផ្លូវល្អ ក្នុងគោលបំណងឱ្យយើងមាននូវស្មារតីវៀរចាកអំពើសៅហ្មងដោយខ្លួនឯង ។

មនុស្សមានច្រើនប្រភេទណាស់ ប៉ុន្តែការជ្រើសរើសមិត្តមិនមែនជាការផ្សងព្រេងដូចចាក់ឆ្នោតទេ គឺត្រូវតែសិក្សាអំពីលក្ខណៈមនុស្សឱ្យបានច្បាស់ តាមដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង តាមពិតព្រះសម្មាសម្ពុទ្ធជាកល្យាណមិត្តមួយព្រះអង្គដ៏កំពូលក្រៃលែង ជាមួយនឹងពុទ្ធបរិស័ទយើង ការប្រព្រឹត្តព្រហ្មចរិយធម៌បានសម្រេចទាំងមូល ដោយអាស្រ័យព្រះអង្គជាកល្យាណមិត្ត ប៉ុន្តែសេចក្តីនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងឱ្យយើងមាននូវកល្យាណមិត្ត តាមដានពិនិត្យការប្រព្រឹត្តរបស់យើងរាល់ថ្ងៃ ខុសឬត្រូវយ៉ាងណាៗឱ្យហ៊ានជួយថាជួយប្រាប់ ព្រម



Document Produced by deskPDF Unregistered :: http://www.docudesk.com

ទាំងនៅរួមសុខទុក្ខទៀតផង ។

មនុស្សល្អកម្ររកបានណាស់ មនុស្សល្អធ្វើអាក្រក់បានដោយលំបាកក៏ពិតមែន ប៉ុន្តែមនុស្សអាក្រក់ធ្វើអាក្រក់បានដោយងាយ ថែមទាំងមិនចេះឆ្អែតក្នុងការធ្វើនូវអំពើអាក្រក់នោះទៀតផង ដូចជាមិត្តប្លមផ្នែកខាងនិយាយចាក់បណ្ដោយក្នុងលក្ខណៈប្រការទី៣ បានដល់ :

**៣. សម្មុខស្ស វណ្ណំ ភាសតិ** និយាយសរសើរមិត្តតែក្នុងទីចំពោះមុខ មនុស្សយើងបានដឹងអំពីចំណុចទន់ខ្សោយរបស់មនុស្សផងគ្នា ទើបនិយមយកពាក្យសរសើរមកធ្វើជាឧបករណ៍ប្រើប្រាស់ សម្រាប់ទាក់យកផលកម្រៃ ឬសម្រាប់ផ្តួលរំលំគ្នាទៀតផង ដូចជាពាក្យសរសើរនៃមនុស្សដែលជាមិត្តប្លម ពាក្យសរសើរនោះវាជាគ្រឿងស្រវឹង ឬវាជាគ្រឿងបំពុលរបស់គេ មនុស្សយើងដែលមិនបានយកចិត្តទុកដាក់ពិចារណាឱ្យបានដិតដល់ ក៏រមែងបរិភោគនូវគ្រឿងស្រវឹង ឬគ្រឿងបំពុលនោះ ដោយពុំដឹងខ្លួនពោលគឺវង្វេងភ្លេចសតិ ។

មនុស្សយើងខំប្រឹងធ្វើល្អ ដោយការចំណាយធនធានឱ្យទៅជាទាន ឬក៏ការខ្នះខ្នែងផ្សេងៗជាដើម លុះដល់មានអ្នកដទៃរំលឹកឈ្មោះសរសើរ ក៏ភ្លេចនឹកជ្រះថ្លាចំពោះកុសលធម៌ ដែលជាកល្យាណមិត្រ ជាគុណដ៏ប្រសើរពិតៗ ដោយមកអំពីរវល់តែត្រេកអរពេញចិត្តនឹងខ្លួនឯងដែលគេសរសើរ ចំពោះមុខមហាជន មានពេលខ្លះទៀត គេសរសើរប៉ុណ្ណឹងមិនគ្រប់ល្មមទេ ចង់ឱ្យគេនឹកសរសើរបន្ថែមទៀត ក៏បានពោលថា «កុំចាំបាច់សរសើរខ្ញុំអី» គឺចង់ឱ្យគេស្ញើចថា ខ្លួនឯងមិនចេះស៊ីជោរឡើយ ។

ការលិចលង់ផុងខ្លួនក្នុងពាក្យសរសើរ ត្រូវបានបាត់បង់នូវគំនរបុណ្យកុសលអស់ច្រើនណាស់ គឺកុសលគ្រប់កាលទាំងបី (មុនធ្វើ កំពុងធ្វើ ធ្វើរួចហើយ) ទាំងការតាំងចិត្តក៏មិនបានស្លុះចុះស៊ប់ឱ្យណែននៅក្នុងបុណ្យកុសលពិតប្រាកដទៀតផង វាមិនត្រឹមតែជាមេរោគបំផ្លាញសុខភាពផ្លូវចិត្ត បញ្ចុះកម្លាំងរបស់បុណ្យកុសលប៉ុណ្ណឹងទេ ការវង្វេងនឹងពាក្យសរសើរ នាំឱ្យមនុស្សលោកជួយខ្លួនឯងមិនរួចអំពីរណ្ដៅលាមកគឺអំពើទុច្ចរិតទៀតផង ។ ភិក្ខុត្រូវទោសបារាជិកហើយ នៅហ៊ានបន្លំខ្លួនធ្វើជាសង្ឃ ព្រោះខ្លាចបាត់បង់នូវពាក្យសរសើរនិងកិត្តិយសជាដើម មិត្តក្បត់មិត្ត សិស្សក្បត់គ្រូ ប្ដីប្រពន្ធក្បត់គ្នា ។ល។ ព្រមដោយបាបកម្មផ្សេងៗទៀតមានបាណាតិបាត (សម្លាប់សត្វមានជីវិត) ជាដើម គឺមួយ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ចំណែកធំព្រោះចង់បានមុខមាត់ កិត្តិយស កេរ្តិ៍ឈ្មោះ និង ពាក្យសរសើរ មានខ្លះរហូតដល់ទៅបោកប្រាស់ប្រាក់គេ ដើម្បីយកមកកសាងវត្តនៅស្រុករបស់ខ្លួនឯងក៏មានដែរ ។

ពាក្យសរសើរគឺជាមាត់ជ្រោះដ៏រអិលមួយកន្លែង វាងាយនាំឱ្យធ្លាក់បាក់កស្លាប់ណាស់ ចំពោះបុគ្គលដែលគ្រាន់តែប្រយ័ត្នល្មមៗនោះ ព្រោះហេតុដូច្នេះ ទើបយើងត្រូវប្រយ័ត្នឱ្យមែនទែនចំពោះមនុស្សដែលជាមិត្តប្លម គេសរសើរយើងរឿយៗនៅចំពោះមុខតែប៉ុណ្ណោះ ។

**៤. បរម្មុខស្ស អវណ្ណំ ភាសតិ** ពោលទោសមិត្តក្នុងទីកំបាំងមុខ គេមិនមានចិត្តអាណិតមេត្តាយើងឡើយ គេបានផ្សែផ្សំរឿងនេះបន្តិចរឿងនោះបន្តិច ស្មានខ្លះប្រហែលខ្លះ ពិតខ្លះ មិនពិតខ្លះ ក្នុងការនិយាយអំពីយើងជាមួយនឹងអ្នកដទៃ ។

គួរនឹករលឹកដល់ទឹកចិត្តឪពុកម្ដាយ គាត់ពោលស្ដីថាឱ្យកូនចៅ ទូន្មានប្រៀនប្រដៅរឿយៗជានិច្ច ប៉ុន្តែទោះគាត់ដឹងនូវកំហុសខុសឆ្គាំឆ្គងរបស់យើងជាកូនយ៉ាងណាៗ ការនេះគាត់មិនដើរនិយាយប្រាប់គេប្រាប់ឯង អំពីអ្វីដែលជារឿងមិនល្អរបស់កូនគាត់ទេ គាត់ពិតជាបិទបាំងណាស់ បើសិនជារឿងហ្នឹងវាធ្ងន់ធ្ងរពេកអ្នកដទៃក៏បានដឹងខ្លះដែរនោះ គាត់ក៏និយាយដែរ ប៉ុន្តែបន្តិចបន្តួចប៉ុណ្ណោះ នៅពេលដែលមានគេសាកសួរបញ្ជាក់រឿងនោះៗថែមទាំងសម្ដែងទឹកចិត្តកង្វល់ ភ័យព្រួយចំពោះកូនរបស់គាត់ទៀតផង មិនមែននិយាយដោយសប្បាយរីករាយនូវទោសកំហុសរបស់យើងដែលជាកូនរបៀបដូចមិត្តប្លមនោះទេ ដូច្នេះមាតាបិតាគឺជាមិត្តជិតដិត ស្និទ្ធស្នាល ប្រកបដោយការតស៊ូនិងការលះបង់ដ៏ធំធេង ចំពោះបុត្តធីតា ។

ការនិយាយអំពីទោសកំហុសរបស់អ្នកដទៃ មិនមែនសុទ្ធតែមិនល្អទាំងអស់នោះទេ បើយើងនិយាយដោយស្មារតី មិនបៀតបៀនអ្នកដទៃ មិនដើម្បីលើកតម្កើងខ្លួនឯង គឺនិយាយដោយកុសលចិត្តពិតៗ ក្នុងន័យដើម្បីឱ្យអ្នកស្ដាប់កុំធ្វើតម្រាប់តាម ការនិយាយដោយចិត្តគំនិតបែបនេះជាការប្រពៃ សេចក្ដីនេះ សូម្បីយើងនិយាយអំពីគុណអ្នកដទៃពិតៗក៏មិនប្រាកដថាសុទ្ធតែល្អនោះទេ ព្រោះវាអាចជាពិសពុល ដោយអំណាចចិត្តអកុសលនាំឱ្យនិយាយ ដូច្នេះរឿងនេះយើងគ្រាន់តែចាំទុកថា « បុគ្គលពាលមានការសំឡឹងទោសអ្នកដទៃជាកម្លាំង បណ្ឌិតមានការមិនសំឡឹងទោសអ្នកដទៃជាកម្លាំង អ្នករៀនច្រើនមានការពិចារណាជា



Document Produced by deskPDF Unregistered :: http://www.docudesk.com

កម្លាំង អ្នកស្ងប់រម្ងាប់មានសេចក្តីអត់ធន់ជាកម្លាំង » ។

**IV- បុគ្គលដែលជាមិត្តសំឡាញ់ក្នុងផ្លូវវិនាស មានលក្ខណៈ ៤ យ៉ាងគឺ :**

១. សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរាមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ពិតជាលំបាកលះមែនហើយ ចំពោះអ្វីដែលធ្លាប់ជាប់ចិត្ត ធ្លាប់ញៀន ធ្លាប់ញ៉ាម ប៉ុន្តែក្នុងលោកនេះបើមានការលះបង់នូវអ្វីៗបានដោយធូរៗនោះ ការព្យាយាមក៏មិនមានតម្លៃអ្វីដែរ ។

ស្មារតីជារបស់មានតម្លៃណាស់ គឺជាកូនសោសម្រាប់ចាក់យកនូវសួស្តីពិតប្រាកដ មិនមែនគ្រាន់តែសរសេរពាក្យថា «សួស្តីឆ្នាំថ្មី » ដាក់មុខផ្ទះ ហើយសួស្តីចេះតែកើតមាននោះឡើយ តាមពិតមនុស្សម្នាក់ៗអាស្រ័យសេចក្តីមិនប្រមាទ មាននូវសតិសម្បជញ្ញៈ ទើបអាចនាំមកនូវសួស្តីឱ្យខ្លួនឯងនិងអ្នកដទៃទៅបាន ដូច្នេះបើយើងពិតជាស្រឡាញ់ខ្លួន និងសង្គមគ្រួសាររបស់ខ្លួន ព្រមទាំងប្រជាពលលោកផង យើងត្រូវខិតខំថែរក្សាឱ្យមុតមាំក្រៃលែងនូវស្មារតីរបស់ខ្លួនឯង ថែមទាំងប្រឹងប្រែងក្នុងការបំប៉នឱ្យរីកចំរើនទៀតផង **គុណតម្លៃរបស់មនុស្សដែលប្រសើរជាងសត្វតិរច្ឆាន ដោយអាស្រ័យស្មារតី ។**

២. វិកាលវិសិខាចរិយានុយោគេ សហាយោ ហោតិ ជាសម្លាញ់ក្នុងការប្រកបរឿយៗនូវការត្រាច់ទៅតាមច្រកល្ហកខុសកាល មានមនុស្សចូលចិត្តដើរលេងយប់ ទោះបីយប់ជ្រៅក៏នៅតែដើរ មិនរក្សាផ្ទះសម្បែងទ្រព្យសម្បត្តិ មិនរក្សាប្រពន្ធកូន សូម្បីខ្លួនឯងក៏ឈ្មោះថាមិនចេះស្រឡាញ់ខ្លួន ជួនកាលដើរទៅប្រទះចោរ ឬជួបសត្រូវ ម្យ៉ាងទៀត ធ្វើឱ្យអ្នកស្រុករង្កៀស ព្រោះនឹកថាជាចោរដើរលួចប្លន់ពេលយប់ ជួនកាលជាន់ដានចោរត្រូវគេចោទប្រកាន់ ។

បើបណ្ឌិតដឹងថាខ្លួនជាទីស្រឡាញ់របស់ខ្លួនហើយ ត្រូវតែប្រឹងប្រែងថែរក្សាខ្លួនឯងឱ្យបានល្អ ការថែរក្សាខ្លួន មិនមែនស្អិតស្អាងខ្លួន ឬពួនសម្ងំក្នុងបន្ទប់លើវិមានប្រាសាទនោះទេ ការបំពេញសេចក្តីល្អ អប់រំគុណធម៌ សន្សំសំចៃកម្លាំងឱ្យបានរឹងប៉ឹង ដើម្បីប្រកបការងារដែលប្រាសចាកទោស ឈ្មោះថាជាការគ្រប់គ្រងថែរក្សាខ្លួន ។

តណ្ហារបស់បុគ្គលណាដែលទ្រុស្តសីល មានមារយាទ



Document Produced by deskPDF Unregistered :: http://www.docudesk.com

អាក្រក់ រមែងគ្របសង្កត់នូវបុគ្គលនោះឯង ប្រៀបដូចជាវល្លិជ្រៃ ដែលរួបរឹតដើមឈើដទៃក្នុងព្រៃភ្នំ បុគ្គលនោះមិនខុសអំពីចោរ ដែលបំណងប្រាថ្នានឹងធ្វើនូវសេចក្តីវិនាសឱ្យដល់អ្នកដទៃឡើយ ប៉ុន្តែក្នុងសេចក្តីនេះ បុគ្គលនោះគឺជាចោរដែលធ្វើនូវសេចក្តីវិនាសឱ្យដល់ខ្លួនឯង ។

៣. **សមជ្ជាភិចរណេ សហាយោ ហោតិ** ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព រូប សម្លេង ក្លិន រស ផោដ្ឋព្វៈជាអន្ទាក់នៃសេចក្តីស្លាប់ សត្វលោកគ្រប់គ្នាប្រឹងប្រែងការពារវិបត្តិភយន្តរាយ ការពារនូវសេចក្តីស្លាប់កុំឱ្យឆាប់មកដល់ខ្លួន ប៉ុន្តែសត្វលោកស្លាប់រាប់ដងមិនអស់ ក៏ព្រោះតែតណ្ហានៃខ្លួនឯង សត្វលោកពិតជាក្បត់ជាមួយនឹងខ្លួនឯងប្រាកដមែន ។

មនុស្សយើងមិនមែនបានជាមនុស្សល្អឯងៗទេ គឺត្រូវអាស្រ័យការអប់រំកាយ អប់រំវាចា អប់រំចិត្ត ការអប់រំនេះក៏កុំចូលចិត្តយល់ថាងាយៗឱ្យសោះ ត្រូវដុសខាត់កិលេសរឿយៗ ដោយមានជំនឿមុតមាំក្នុងការដឹកនាំរបស់អ្នកប្រាជ្ញ ឧស្សាហ៍ខ្មីឃ្មាតសង្វាតសូត្ររៀន មានការមិនធ្វេសប្រហែសដោយស្មារតីប្រុងប្រយ័ត្ន កុំឱ្យបោះជំហានទី១ចូលក្នុងផ្លូវខុស បើបានជ្រុលជ្រួសប្រញាប់ដកថយ មានការបង្ហាត់ចិត្តឱ្យបានស្ងប់រម្ងាប់ក្នុងកិច្ចការងារ និងមានវិជ្ជាជីវិតឃើញទោសកាមគុណ ។

ក្នុងសាច់រឿងកុនល្ខោនល្បែងរបាំ មានការដឹកនាំអប់រំតិចតួចណាស់ ដើម្បីឱ្យអ្នកមើលបានជាមនុស្សល្អនោះ ប៉ុន្តែក្នុងកិច្ចការមើលមហោស្រពនេះ វាបានជំនួសមកវិញនូវការខាតបង់ពេលវេលាសម្រាប់ធ្វើកិច្ចការងារល្អៗ អាចជាការខាតបង់នូវទ្រព្យសម្បត្តិ ជាពិសេសវានាំបណ្តាលឱ្យមានចិត្តរាយមាយ រវើរវាយក្នុងរឿងកាមគុណ រីករាយភ្លើតភ្លើន រហូតដល់ហ៊ានប្រព្រឹត្តនូវអំពើសៅហ្មងច្រើនយ៉ាងទៀតផង ព្រោះបាត់បង់ស្មារតី ។

កូនប្រុសស្រីគួរមានកម្មវិធីសិក្សាអប់រំ ដោយការទទួលយកនូវឱវាទល្អៗ ចំណេះដឹងនិងបទពិសោធន៍ក្នុងឆាកជីវិត អំពីមាតាបិតា ជីដូនជីតា ក្នុងពេលសម្រាកអំពីការងារពេលថ្ងៃ ឬជាពិសេសនៅពេលបរិភោគអាហារល្ងាចរួច នេះជាប្រពៃណីអំពីបុរាណមក ឯការមើលល្បែងរបាំកុនល្ខោនជាប្រក្រតី ទូរទស្សន៍ជាប្រចាំរាល់រាត្រី បន្តភាគរឿងនេះរឿងនោះ ដោយមិនចូលចិត្តចំពោះកម្មវិធីអប់រំផ្សេងៗ វាជាការបំផ្លាញខ្លួនឯង ធ្វើឱ្យទន់ខ្សោយនូវស្មារតី ខាតបង់កម្លាំងសម្រាប់ធ្វើការងារនៅពេលថ្ងៃ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ដាច់នូវប្រពៃណីដែលកូនប្រុសស្រីត្រូវប្រាស្រ័យសន្ទនាជាមួយចាស់ទុំ នៅពេលល្ងាចៗឬព្រលប់ៗដែលត្រូវជួបជុំគ្នា ។

**៤. ជូតប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ** ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗនូវល្បែងភ្នាល់ ដែលជាទីតាំងនៃសេចក្ដីប្រមាទ អ្នកលេងឈ្នះរមែងមានពៀរ អ្នកលេងចាញ់រមែងសោកស្ដាយ ក្ដៅក្រហាយដេកជាទុក្ខ អ្នកលេងល្បែងនិយាយអ្វីៗទឹកមាត់មិនប្រៃ ដោយសេចក្ដីថា គេមិនយកជាការព្រោះថាខ្លួនគឺជាអ្នកលេងល្បែង ម្យ៉ាងទៀតបញ្ចុះតម្លៃក្រុមគ្រួសារ ដោយលំបាកក្នុងការស្ដីដណ្ដឹងកូនអ្នកដទៃ ឬអ្នកដទៃមិនមកស្ដីកូនរបស់ខ្លួន ព្រោះគេគិតថាជាពូជអ្នកល្បែង ណាមួយត្រូវទទួលការមើលងាយអំពីញាតិមិត្ត ទាំងទ្រព្យសម្បត្តិក៏ត្រូវវិនាសដោយអាស្រ័យល្បែងនោះៗ។

អ្នកលេងល្បែងងាយបាត់បង់នូវគុណធមិណាស់ គេហ៊ានបោកប្រាស់ ហ៊ានប្រព្រឹត្តចោរកម្ម ហ៊ានសម្លាប់មនុស្ស ហ៊ានផិតក្បត់ ។ល។ គេហ៊ានលក់នូវសុភមង្គលក្នុងក្រុមគ្រួសារ ឱ្យទៅវង់ល្បែង ប្ដីប្រពន្ធលែងលះគ្នា ។

ការងារដែលគួរធ្វើ គេលះបង់ចោល ចំណែកការងារដែលមិនគួរធ្វើ គេបែរជាប្រព្រឹត្ត ព្រោះវិបត្តិនូវស្មារតីដោយអាស្រ័យល្បែង ។

សេចក្ដីមិនប្រមាទ ជាផ្លូវនៃសេចក្ដីមិនស្លាប់ សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់ អ្នកដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ អ្នកដែលប្រមាទហើយ ទុកដូចជាបុគ្គលដែលស្លាប់ទៅហើយ តាមពិតមនុស្សប្រមាទស្អុយជាងខ្មោចស្លាប់ ព្រោះសាកសពគ្រាន់តែមិនមានវិញ្ញាណអាស្រ័យនៅប៉ុណ្ណោះ ឯបុគ្គលមាននូវសេចក្ដីប្រមាទវិញនោះ មិនមានវិញ្ញាណជាកុសលពិតមែន ប៉ុន្ដែនៅមានចិត្តសន្ដានបាប វិញ្ញាណជាអកុសលជាមនុស្សខ្មោច ស្អុយអសោចិ៍បញ្ច្រាសខ្យល់ ។

យសស័ក្ដិរមែងចំរើនកើតមានដល់បុគ្គលដែលមានសេចក្ដីព្យាយាម ប្រឹងប្រែង មាននូវស្មារតី មានការងារប្រពៃ ពិចារណាហើយទើបធ្វើជាអ្នកសង្រួម រស់នៅប្រកបដោយធមិ និងជាអ្នកមិនប្រមាទ ។

សរុបសេចក្ដីមក អបាយមុខគ្រប់ប្រភេទណាមួយក្ដី បុគ្គលសេពនូវអបាយមុខនោះៗក្ដី សូមបុរសស្ត្រីគេចចៀសវាង ឱ្យដូចមនុស្សដែលខ្លាចខ្មោចលង ហើយគេចចៀសវាងចាកព្រៃខ្មោច



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដូច្នោះដែរ ។

៤ មិត្តដែលមានឧបការៈ ១ មិត្តដែលរួមសុខទុក្ខ១ មិត្តដែលប្រាប់នូវប្រយោជន៍១ មិត្តដែលមានការឈឺឆ្អាល១ បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង៤ពួកនេះថា ជាមិត្តមែនទែន គឺមិនមែនជាមិត្តប្លមឡើយ ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាម្តាយជាមួយនឹងកូនដែលកើតអំពីផ្ទៃ ដូច្នោះឯង ។

បណ្ឌិតបរិបូណ៌ដោយសីល រមែងរុងរឿងដូចជាភ្លើងឆេះសន្ធោសន្ធៅ នៅលើកំពូលភ្នំនារាត្រីកាលខែរនោច ។ បុគ្គលកាលសន្សំនូវទ្រព្យសម្បត្តិ រមែងធ្វើទ្រព្យឱ្យជាគំនរ ដូចជាឃ្មុំធ្វើសម្បុក សន្សំក្បាលទឹក មិនឱ្យខូចពណ៌មិនឱ្យខូចក្លិននៃផ្កាឈើឡើយ ដោយសេចក្តីថា សន្សំទ្រព្យដែលបានមកដោយការងារប្រាសចាកទោស មិនបៀតបៀនខ្លួនឯងនិងអ្នកដទៃ ចិញ្ចឹមជីវិតដោយប្រពៃ កពូននូវភោគៈទាំងឡាយ ដូចជាកណ្ដៀរកពូននូវដីធ្វើដំបូកដូច្នោះឯង ។

គ្រហស្ថក្នុងត្រកូល គប្បីចែកនូវភោគៈទាំងឡាយជាបួនចំណែកគឺ : មួយចំណែកសម្រាប់បរិភោគផង ចាយវាយការពារអន្តរាយផង ធ្វើនូវពលីគឺការសង្គ្រោះផ្សេងៗ និងការបូជាគុណ ទំនុកបំរុងសមណព្រាហ្មណ៍អ្នកមានសីលផង ពីរចំណែកទៀតសម្រាប់ប្រកបការងារ ធ្វើកសិកម្មឬពាណិជ្ជកម្ម និង មួយចំណែកផ្សេងទៀតទុកតម្កល់ការពារអន្តរាយ ក្រែងមានការខាតទុនចំពោះមុខរបរពាណិជ្ជកម្ម កសិកម្ម ដែលជាការងារស្វែងរកទ្រព្យនោះៗ ។

អ្នកគ្រប់គ្រងផ្ទះជាអ្នកមាននូវមុខរបរ ប្រកបការងារប្រាសចាកទោសទាំងឡាយ សន្សំនូវភោគៈ គប្បីជាអ្នកមានមិត្តល្អដូចតទៅ :

**ក/ -មិត្តល្អចំពូកទី I ជាមិត្តមាននូវឧបការៈមានលក្ខណៈ ៤ យ៉ាងគឺ :**

១. **បមត្តំ រក្ខតិ** រក្សាមិត្តដែលធ្វេសប្រហែស មនុស្សយើងមានការប្រមាទ ពោលគឺការបាត់បង់នូវសតិជារឿយៗ រហូតដល់ទៅមានពេលខ្លះហ៊ានបរិភោគនូវទឹកស្រវឹង បន្ថែមឱ្យខ្លួនឯងដែលមានសតិទន់ខ្សោយស្រាប់ទៅហើយនោះ ឱ្យរឹងរឹតតែវិបត្តិស្មារតី លែងដឹងខុសត្រូវអ្វីទាំងអស់ទៀតផង ក្នុងការប្រមាទបែបនេះ មិត្តមាននូវឧបការៈ រមែងជួយរក្សាការពារ ព្រោះថាបុគ្គលអ្នកប្រមាទមិនអាចរក្សាខ្លួនឯងបានឡើយ ដូច្នេះទើបយើងត្រូវ

មាននូវមិត្តល្អ មិត្តមានឧបការៈ ។

លោកសេដ្ឋីពិតជាមាននូវអ្វី ដែលអ្នកក្រខ្សត់មិនមានប្រាកដណាស់ ប៉ុន្តែសេដ្ឋីអាចមិនមាននូវអ្វី ដែលមនុស្សទ័លក្រមាន ជាពិតប្រាកដផងដែរ ដូច្នេះការចងមិត្ត មិនចំពោះទៅសំដៅរកតែអ្នកមានទ្រព្យច្រើននោះទេ រឿងសំខាន់នៅលើគុណធម៌ ។ គុណធម៌ឬចិត្តសប្បុរស មិនមែនជារបស់ដាក់លក់ សម្រាប់ឱ្យអ្នកមានប្រាក់ទិញយកនោះឡើយ ព្រោះថាចិត្តសប្បុរសមានតម្លៃជាងមាសប្រាក់ទាំងអស់ ទាល់តែបុគ្គលអប់រំនូវគុណធម៌ឱ្យច្រើនៗ ទើបអាចមានទៅបាន នូវចិត្តសប្បុរសនេះ ។

**២. បមត្តស្ស សាបតេយ្យំ រក្ខតិ** រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស មិត្តមាននូវឧបការៈ បានគិតថា សម្លាញ់របស់យើងបានចេញទៅក្រៅផ្ទះ មានការធ្វេសប្រហែសចោលផ្ទះសម្បែង ទ្រព្យសម្បត្តិទីកន្លែង ម្លោះហើយរបស់នោះៗវាអាចបាត់បង់ទៅដោយប្រការផ្សេងៗបាន លុះគិតដូច្នេះហើយ ក៏ទៅកាន់ផ្ទះសម្លាញ់ ដើម្បីគយគន់ឬឃ្លាំចាំមើលថែទាំរក្សានូវផ្ទះសម្បែង ឬ ទ្រព្យសម្បត្តិទាំងឡាយទាំងពួងនោះ ។

ការថែរក្សាទ្រព្យសម្បត្តិ វាជាការងារមួយចាំបាច់ ទោះជាត្រូវចំណាយទុនខ្លះក៏ដោយ ព្រោះការគង់វង់នៃទ្រព្យសម្បត្តិគឺជាកាំជណ្ដើរសម្រាប់ឈានឡើងទៅរកអ្វីមួយ ដែលខ្លួនឯងចង់បាន ប៉ុន្តែវាក៏ជាមាត់ជ្រោះដ៏រអិលផងដែរ ។

ព្រោះតែប្រហែសជាមួយប្រាក់ មនុស្សខ្លះត្រូវជំពាក់បំណុលគេសងមិនរួច រហូតដល់ស្លាប់ទៅ ទុកបំណុលឱ្យកូនចៅខ្មោចម៉ែឪក្លាយជាសត្រូវរបស់កូនទៀតផង ក្រពះតូចតែមួយសោះ ដូចម្ដេចក៏ត្រូវជំពាក់បំណុលគេច្រើនម្ល៉េះ នេះជារឿងគួរពិចារណា ។

មនុស្សខ្លះរកតែកូនមួយគ្មាន ប៉ុន្តែល្មោភលោភលន់គ្មានព្រំដែន មិនចេះធ្វើទាន ហាក់ដូចជាទុកចាយទៅជាតិក្រោយទៀតអ៊ីចឹងឯង ។

ជីវិតនេះកើតមក មិនមែនដើម្បីបានលុយ ឬដើម្បីបានអ្វីដទៃទៀតនោះទេ តាមពិតជីវិតកើតមកចៀសមិនផុតពីស្លាប់ឡើយ ប្រៀបដូចស្លឹកឈើ ប៉ុន្តែប្រយោជន៍ខ្លឹមសារនៃការបរិភោគអាហារ បន្តការរស់មួយថ្ងៃៗនោះ គឺព្រោះដើម្បីស្វែងរកការមិនស្លាប់ពិតប្រាកដមួយ បើមិនដូច្នេះទេ វាមិនខុសអ្វីអំពីការដែលមនុស្សល្ងង់ ខំប្រឹងដងទឹកដាក់ពាងធ្លុះនោះឡើយ គឺវាបានតែ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ការនឿយហត់អត់ប្រយោជន៍ ។

មិនដែលមានអ្នកណាទៅឆោតល្ងង់ ដោយខំប្រឹងជញ្ជូនពន្លឺថ្ងៃទុកក្នុងផ្ទះ សម្រាប់បំភ្លឺពេលយប់ទៀតនោះទេ ព្រោះផ្ទះវាមិនចេះទុកដាក់នូវពន្លឺថ្ងៃអ្វីនោះឡើយ តែដល់ពេលយប់វាងងឹតហើយ យ៉ាងណាមិញ ការងារដែលគេធ្វើនៅពេលមានជីវិតរស់នៅ គេមិនធ្វើដើម្បីសេចក្ដីស្លាប់នោះទេ ប៉ុន្តែគេធ្វើដើម្បីឱ្យរួចអំពីជីវិតនេះ ដែលតែងតែកើតស្លាប់នោះឯង ។

ការថែរក្សានូវសម្បត្តិទ្រព្យ សម្រាប់ទំនុកបំរុងឱ្យដល់ជីវិតគឺការរស់ ពិតជាមានប្រយោជន៍ប្រាកដណាស់ បើជីវិតនេះជាគ្រឿងទ្រទ្រង់នូវសេចក្ដីល្អ ការងារជាកុសលនោះ ។

**៣. ភីតស្ស បដិសរណំ ហោតិ** ជាទីពឹងពំនាក់ជាក់ប្រាកដ ចំពោះមិត្តនៅពេលមានភ័យ គឺនៅពេលមិត្តមានវិបត្តិភ័យព្រួយអំពីរឿងអ្វីមួយ មិត្តដែលមាននូវឧបការៈបានពោលដូច្នេះថា «មិត្តឯងកុំភ័យ កុំព្រួយអ្វីឡើយ កាលបើសម្លាញ់ដូចជារូបខ្ញុំនេះនៅរស់ មិត្តឯងកុំខ្លាចឱ្យសោះ» ហើយក៏ជួយដោះស្រាយ កម្ចាត់បង់នូវភយន្តរាយនោះៗបាន ។

ការជួយអ្នកដទៃ មានការជួយមិត្តជាដើម បុគ្គលគប្បីធ្វើដោយរួសរាន់ មិនចាំបាច់រួញរា ដោយរវល់តែគិតថាក្រែងគេមិនដឹងគុណយើងនោះទេ តាមពិត ការជួយសង្គ្រោះអ្នកដទៃ គឺជាសក្ការៈសម្រាប់បូជាចំពោះព្រះពុទ្ធ ព្រោះជាការប្រព្រឹត្តតាមឱវាទរបស់ព្រះអង្គ ម្យ៉ាងទៀតយើងគោរពសេចក្ដីល្អនោះៗ ព្រោះសេចក្ដីល្អអាចជួយមនុស្សឱ្យរួចផុតចាកទុក្ខបាន បើយើងយល់ដឹងក្នុងសេចក្ដីទាំងអស់នេះ ក៏មិនចាំបាច់រវល់ខ្វល់អ្វី អំពីរឿងអ្នកដទៃដឹងឬមិនដឹងនោះឡើយ ហើយថែមទាំងធ្វើដោយប្រញាប់ប្រញាល់ទៀតផង ព្រោះថាបើបុគ្គលធ្វើនូវសេចក្ដីល្អយឺតពេក ដូចជាគេដើរតាមផ្លូវដែលរអិលនោះ ឈ្មោះថាទុកឱកាសឱ្យចិត្តត្រេកអរនឹងបាប ។

សត្វលោកដែលកើតមកហើយ សុទ្ធសឹងតែត្រូវការសេចក្ដីសុខ ដូច្នេះបើយើងមិនបានជួយទំនុកបំរុងគេទេ កុំតែបៀតបៀនគេដើម្បីសេចក្ដីសប្បាយរបស់ខ្លួន និងក្រុមគ្រួសាររបស់ខ្លួនឱ្យសោះ ដូចជាការចាប់សត្វយកមកទុកក្រុងក្នុងទ្រុងតូចចង្អៀត ចាប់ត្រី ចាប់បក្សាបក្សី ដើម្បីសេចក្ដីសប្បាយកែការអផ្សុករបស់ខ្លួននោះ វាជាអំពើខ្វះមនុស្សធម៌ មនុស្សយើងមិនគួរលោភលន់អ្វីពេកពន់នោះទេ ព្រោះថា បានកើតមកជាមនុស្សទៅហើយ គួរ

តែជួយសង្គ្រោះ ចំពោះសត្វលោកដែលមាននូវសេចក្តីទុក្ខលំបាក ជាការជប់លៀងក្នុងជីវិតមង្គល ដែលបុណ្យបានផ្តល់កំណើត ឱ្យយើងបានកើតមកជាមនុស្ស ។

៤. **ឧប្បន្នេសុ កិច្ចេសុ ករណីយេសុ តទ្ទិគុណំ ភោគំ អនុប្បទេតិ** កាលបើកិច្ចដែលត្រូវធ្វើ កើតឡើងហើយ តែងជួយផ្តល់នូវភោគៈជាទ្វិគុណ ជាងទ្រព្យដែលមិត្តត្រូវការ បើមិត្តត្រូវការមួយរយដើម្បីដោះស្រាយបញ្ហា ក៏ពោលទៅមិត្តសម្លាញ់នោះថា «សម្លាញ់អើយ មួយរយវាមិនគ្រប់គ្រាន់ទេ កិច្ចការហ្នឹងនោះចូរសម្លាញ់យកពីររយទៅ កុំឱ្យវាផុតផើយ » ហើយក៏បានឱ្យទៅដោយចិត្តស្មោះត្រង់ នេះជាលក្ខណៈមិត្តមាននូវឧបការៈ ។

ជីវិតមនុស្សមានតម្លៃជាងប្រាក់មួយរយដុល្លារ ព្រោះជីវិតមនុស្សមិនមែនបានមកដោយការទិញដូរទេ គឺគ្រប់គ្នាដែលបានកើតជាមនុស្សព្រោះអាស្រ័យបុណ្យ មហាសេដ្ឋី មហាមូលធន ក៏មិនអាចទិញជីវិតរបស់ខ្លួនទុកនៅឱ្យរស់រហូតបានឡើយ ទោះជាមានសម្បត្តិច្រើនប៉ុនណាក៏ដោយ តែដល់ពេលត្រូវស្លាប់ វាត្រូវតែស្លាប់ ដូច្នេះបើយើងមិនបានជួយអ្នកដទៃជាទ្វិគុណទេ ក៏គួរតែជួយតាមការស្នើសុំ តែបើមិនបានជួយតាមការស្នើសុំ ក៏កុំតែបៀតបៀនសម្លាប់គេ ដោយគ្រាន់តែបានប្រាក់កម្រៃប៉ុណ្ណេះ ឬប៉ុណ្ណោះទៅ គឺវានៅក្នុងថ្នាក់គ្រាន់បើដែរ មិនមែនថាល្អណាស់នោះទេ ប៉ុន្តែវាមិនបានឈ្មោះថាជាមនុស្សព្រៃផ្សៃ ។

ជីវិតអ្នកដទៃម្នាក់ ពិតមែនតែមិនមែនជាប្រាក់ពីរឬបីរយដុល្លារ ដែលយើងស៊ីឈ្នួលបានមក ប៉ុន្តែជីវិតអ្នកដទៃម្នាក់នោះ គឺមានតម្លៃសម្រាប់ក្រុមគ្រួសាររបស់គេណាស់ គេស្តាយស្រណោះយំសោកបោកខ្លួន នៅពេលដែលបុគ្គលណាម្នាក់ ជាទីស្រឡាញ់របស់គេបានត្រូវបាត់បង់ជីវិត ។ មនុស្សយើងទាល់តែចេះឱ្យតម្លៃជីវិតអ្នកដទៃផង ទើបជីវិតរបស់ខ្លួនវាមានតម្លៃ យើងមិនអាចយកឈ្នះអ្នកដទៃដោយសេចក្តីអាក្រក់ អំពើអាក្រក់របស់ខ្លួនឯងបានទេ តាមពិតនៅពេលគំនិតអាក្រក់កើតឡើង ចង់បៀតបៀនអ្នកដទៃនោះ យើងឈ្មោះថាចាញ់ស្រេចបាត់ទៅហើយ ។

**៩/ -មិត្តល្អចំពូកទី II ជាមិត្តរួមសុខទុក្ខមានលក្ខណៈ ៤ យ៉ាងគឺ :**

១. **គុយ្ហមស្ស អាចិក្ខតិ** ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត មនុស្សយើងម្នាក់ៗដែលនៅមានកិលេស គង់ជួបប្រទះនូវរឿងដែលនាំឱ្យកង្វល់ក្នុងចិត្ត បើយើងលាក់រឿងនោះមិនឱ្យអ្នក



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដទៃជួយដោះស្រាយ វាអាចយើងខ្លួនឯងដោះមិនចេញ មានខ្លះប្រព្រឹត្តអំពើផ្តេសផ្តាសឱ្យដល់ខ្លួនឯងទៀតផង ប៉ុន្តែបើចេះតែនិយាយប្រាប់ដល់មនុស្សមិនរើសមុខ វាអាចកាន់តែធ្ងន់ធ្ងរ ដូច្នេះដែលល្អបំផុតនោះគឺមិត្តដែលមានសន្តានចិត្តល្អ មិត្តរួមសុខទុក្ខជាមួយយើង កាលដែលមិត្តល្អរបស់យើងបានដឹងហើយ គេមិនធ្វើព្រងើយឡើយ គេមានឧបាយដោះស្រាយ និងវិធីលួងលោមចិត្តយើងច្រើនយ៉ាង សម្រាប់ឱ្យយើងបាត់ទុក្ខកង្វល់ សប្បាយចិត្តឡើងវិញ ព្រោះហេតុនេះ បើយើងជាមិត្តល្អជាមួយអ្នកណា យើងត្រូវប្រាប់នូវអាថិកំបាំងរបស់យើងដល់អ្នកនោះ ។

ការមិនមានរោគជាលាភយ៉ាងប្រសើរ សេចក្តីសន្តោសតាមមានតាមបានជាទ្រព្យដ៏ប្រសើរ ការស្និទ្ធស្នាលនឹងគ្នាជាញាតិដ៏ប្រពៃ ព្រះនិព្វានជាបរមសុខ ។

ការបានឃើញនូវព្រះអរិយបុគ្គលទាំងឡាយ ជាការប្រពៃការនៅរួមជាមួយព្រះអរិយបុគ្គលទាំងនោះ នាំឱ្យកើតនូវសេចក្តីសុខគ្រប់គ្រា គ្រប់វេលា បុគ្គលដែលអាចបាននូវសេចក្តីសុខ ជានិច្ចកាលពិតប្រាកដ ព្រោះមិនបានជួបប្រទះនូវបុគ្គលពាលទាំងឡាយ ព្រោះថា បុគ្គលដែលត្រាច់រួមគឺសមាគមជាមួយជនពាល រមែងសោកសៅអស់កាលដ៏យូរអង្វែង ការនៅរួមជាមួយបុគ្គលពាលទាំងឡាយ ជាហេតុនាំឱ្យកើតទុក្ខជាប់ជានិច្ច ដូចជាការនៅរួមជាមួយនឹងសត្រូវ យ៉ាងនោះដែរ ចំណែកអ្នកមានបញ្ញាមានការនៅរួមគ្នាជាមួយអ្នកប្រាជ្ញ រមែងជាសុខ ដូចការសមាគមគ្នានៃពពួកញាតិ អ៊ីចឹងដែរ ។

អ្នកទាំងឡាយ ចូរសេពគប់ជាមួយនឹងអ្នកប្រាជ្ញ អ្នកមានបញ្ញាជាពហុស្សូត ជាអ្នកខ្ចីឃ្នាតក្នុងការងារល្អជាប្រក្រតី មានចរិយាវត្តល្អប្រពៃ ជាព្រះអរិយៈ ជាសប្បុរសមានបញ្ញាឈ្លាសវាងវៃ ឱ្យបានជាប់លាប់ជាអចិន្ត្រៃយ៍ បីដូចជាព្រះចន្ទដែលត្រាច់ទៅតាមផ្លូវ ដែលគេហៅថាផ្លូវនក្ខត្តឫក្ស ដូច្នោះឯង ។

**២. គុយ្ហមស្ស បរិគុយ្ហតិ** ជួយបិទបាំងនូវអាថិកំបាំងរបស់មិត្ត មិត្តល្អប្រៀបបីដូចជាសំពត់រុំកាយ ឬប្រៀបដូចជាឪពុកម្តាយដែលរក្សាកូនរបស់ខ្លួនយ៉ាងនោះឯង ពោលគឺមានចិត្តស្មោះត្រង់ មិនមានក្នុងផ្សេង ឯក្រៅផ្សេងនោះឡើយ ហើយហ៊ានពោលជំទាស់នឹងអ្នកដទៃ ដែលគេនិយាយអ្វីៗអាក្រក់ៗ រឿងនេះរឿងនោះ ខុសខ្លះត្រូវខ្លះ ដែលជារឿងរ៉ាវផ្ទាល់ខ្លួនរបស់សម្លាញ់ ។

តាមពិតរឿងអាថិកំបាំង មិនមែនសុទ្ធតែរឿងអាក្រក់

ទាំងអស់នោះទេ រឿងល្អក៏មានដែរ ប៉ុន្តែបើជារឿងបាបកម្ម អំពើខុសឆ្គាំឆ្គងរបស់ខ្លួនឯង គឺខ្លួនឯងមិនត្រូវលាក់ មិនត្រូវបិទបាំងទុកទេ ព្រោះវានាំឱ្យសៅហ្មងចិត្ត នៅពេលជិតស្លាប់ យ៉ាងហោចក៏ត្រូវប្រាប់ដល់មិត្តរួមសុខទុក្ខរបស់ខ្លួនដែរ តែបើវាជារឿងរបស់អ្នកដទៃវិញនោះ មិនត្រូវរើជជុះខ្ទេះកកាយ ហែកកើ្ត បង្ហាញខ្មាស ដោយចង់ឱ្យអ្នកផ្សេងៗដឹងនោះឡើយ ។

ទោសអ្នកដទៃមើលឃើញបានដោយងាយ សូម្បីតិចតួច ឬតូចតាចក៏ដោយ ឯទោសរបស់ខ្លួនឯងវិញ មើលឃើញដោយលំបាក ទោះជាកំហុសនោះធំប៉ុនណាក៏មើលមិនឃើញដែរ ព្រោះថាបុគ្គលនោះរមែងទម្លាក់ទោសដល់ជនដទៃ ដូចជាគេបាចអង្កាមបញ្ច្រាសខ្យល់ យ៉ាងនោះឯង ប៉ុន្តែគេរមែងបិទបាំងនូវទោសរបស់ខ្លួន ដូចជាព្រានព្រៃ បិទបាំងរាងកាយដោយគ្រឿងបិទបាំងផ្សេងៗ ក្នុងពេលរង់ចាំចាប់សត្វ ដូច្នោះដែរ ។

**៣ អាបទាសុ ន វិជហតិ** មិនបោះបង់មិត្តក្នុងគ្រាមានវិបត្តិ នៅពេលយើងមានភ័យ ឬវិបត្តិធំតូចអ្វីមួយនោះ មិត្តរួមសុខទុក្ខមិនលះបង់ចោលយើងឡើយ គឺនៅរាប់អានជាមិត្ត នៅជិតដិតនៅជួយលើកស្ទួយយើង នៅជាទីពឹង បីដូចជាអាវធំក្រាស់ក្នុងរដូវរងារ ។

រឿងសំខាន់នៅត្រង់ការអប់រំចិត្ត តាមពិត មិនមានអ្វីគ្រប់គ្រាន់សម្រាប់យើងឡើយ បើយើងមិនរៀនឱ្យចេះគ្រប់ចេះល្មមទេនោះ ដូចជាទ្រព្យសម្បត្តិជាដើម ទ្រព្យសម្បត្តិដែលប្រសើរពិតមិនមែននៅលើច្រើនឬល្អៗ ចាក់គរយកទៅណាមិនអស់នោះឡើយ ប៉ុន្តែបើម្ចាស់ទ្រព្យចេះល្មមតាមមាន តាមបាន ចំពោះសម្បត្តិដែលបានមកប្រកបដោយធម៌នោះ ទោះជាសម្បត្តិនុះតិចក៏ដោយ ក៏ឈ្មោះថាជាទ្រព្យដ៏ប្រសើរក្រៃលែង ត្រង់កន្លែងនេះមិនងាយមនុស្សបានឃើញឡើយ ព្រោះលោភៈច្រើនពេក សម្លឹងទៅរកតែទ្រព្យសម្បត្តិមាសប្រាក់ច្រើនៗ ទុកឱ្យខ្លួនឯងក្រមួយជីវិត មកអំពីមិនចេះគ្រប់គ្រាន់នោះឯង ។

មនុស្សខ្លះមានសម្បត្តិច្រើន ប៉ុន្តែជំពាក់បំណុលគេមិនតិចឡើយ ជំពាក់ទាំងជីវិតគេទៀតផង ព្រោះហេតុតែមិនចេះសន្តោសចំពោះទ្រព្យ ល្មោភក្នុងសម្បត្តិ ក៏ប្រព្រឹត្តការកេងប្រវ័ញ្ចកាប់សម្លាប់លួចប្លន់ ។ល។ មនុស្សខ្លះទៀត ដល់ពេលមានបានមានបុណ្យមានស័ក្តិ ក៏បំភ្លេចមិត្តសម្លាញ់ ដែលធ្លាប់រួមសុខរួមទុក្ខ ថែមទាំងធ្លាប់មាននូវឧបការៈផ្សេងៗទៀតផងនោះ ចោល



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

អស់រលីង មនុស្សរបៀបនេះនឹងមានកម្មពៀរ គឺមិនអាចមានមិត្តល្អតទៅបានឡើយ ។

ភ្នំមាសសុទ្ធដល់ទៅពីរ ក៏មិនអាចញុំាងឱ្យមនុស្សមិនសន្តោសម្នាក់ គ្រប់គ្រាន់បានឡើយ បុគ្គលដឹងសេចក្តីនោះហើយ គប្បីប្រព្រឹត្តឱ្យដឹងប្រមាណ ។

កាលបើសេចក្តីត្រូវការកើតឡើងហើយ មិត្តសម្លាញ់ទាំងឡាយនាំសេចក្តីសុខមកឱ្យ សេចក្តីសន្តោសចំពោះបច្ច័យ តាមមានតាមបាន នាំសេចក្តីសុខមកឱ្យ មនុស្សយើងគួរតែចាប់ផ្តើមចម្រើននូវសេចក្តីស្ងប់ ពីឥឡូវនេះទៅ បើចេះតែរង់ចាំ ក្រែងលោគ្មានពេល សេចក្តីស្ងប់ជាសុខយ៉ាងប្រសើរបំផុត ។

**៤. ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ** សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍របស់មិត្ត មិត្តរួមសុខទុក្ខស៊ូប្តូរជីវិត ពោលគឺហ៊ានលះបង់ជីវិតខ្លួនឯង ឬមិនគិតដល់ជីវិតរបស់ខ្លួន ក្នុងកិច្ចការងារដែលត្រូវជួយមិត្ត ។

មិត្តល្អកម្ររក ផ្ទុយមកវិញមានមនុស្សខ្លះ ព្រោះហេតុតែមាសប្រាក់ ហ៊ានលះបង់ញាតិមិត្ត ព្រោះដើម្បីកិត្តិយសនិងការសរសើរ សូម្បីម៉ែឪឯងក៏ហ៊ានសម្លាប់ មិនចាំបាច់និយាយដល់អ្នកដទៃទៀតឡើយ ។

តាមពិតកិត្តិយសរបស់មនុស្ស នៅត្រង់ការមានសីល មានពាក្យសម្តីហ្មត់ចត់ស្រស់ល្អដូចផ្កា មានប្រាជ្ញាវាងវៃ កិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង ម្យ៉ាងទៀតបុគ្គលបានយសព្រោះព្យាយាមរវៀសរវៃ មិនខ្ជិលច្រអូស មិនញាប់ញ័រក្នុងអន្តរាយទាំងឡាយដែលមកដល់ខ្លួន ឈ្លាសវៃក្នុងការងារ មានប្រព្រឹត្តិជាប់តគ្នាជានិច្ចគឺមិនដាច់សេចក្តីតស៊ូ ដោយឡែកទៀតបុគ្គលបានយសព្រោះចេះសង្គ្រោះ ជាអ្នកចងមិត្តបានល្អ ពោលយ៉ាងណាធ្វើយ៉ាងនោះ ប្រាសចាកសេចក្តីកំណាញ់ និងជាអ្នកចេះដឹកនាំពន្យល់ហេតុការណ៍ផ្សេងៗ ជាអ្នកណែនាំអប់រំរឿយៗដល់អ្នកដទៃ ។

ដើម្បីបានជាមនុស្សល្អ ត្រូវចេះដាស់តឿនខ្លួនដោយខ្លួនឯង ធ្វើជាតម្រួតម្នាក់ត្រួតខ្លួនឯង ដោយកុំចាំបាច់ទាល់តែគេត្រួត កាលបើយ៉ាងនេះឈ្មោះថា គ្រប់គ្រងខ្លួនឯងបាន បុគ្គលណាគ្រប់គ្រងរក្សាខ្លួនឯងបាន បុគ្គលនោះជាអ្នកមានសតិ ជាធម្មតាបុគ្គលមានសតិមាំទាំ រមែងនៅជាសុខគ្រប់ឥរិយាបថទាំង ៤ ។

មានតែខ្លួនឯងប៉ុណ្ណោះ ដែលអាចជាទីពឹងឱ្យខ្លួនឯងបាន

ព្រោះថាអ្នកដទៃមិនអាចលះបង់នូវកិលេសឱ្យយើងបានទេ ហេតុដូច្នេះហើយ បុគ្គលមានស្មារតី គប្បីរក្សាខ្លួនឱ្យបានល្អ ដាច់ខាតកុំបោះបង់ខ្លួនឯងចោល ក្នុងព្រៃជ្រៅគឺអវិជ្ជាឱ្យសោះ ព្រោះបើអត់អំពីខ្លួនឯងទៅ មិនមានអ្នកណាមកជួយយើង ជំនួសយើងបានឡើយ ។

**គ/ -មិត្តល្អចំពូកទី III គឺមិត្តប្រាប់នូវប្រយោជន៍ណែនាំ ក្នុងការងារល្អ ដោយប្រាថ្នាសេចក្តីសុខឱ្យដល់មិត្តមាន លក្ខណៈ ៤ យ៉ាងគឺ :**

១. បាបា និវារេតិ ហាមឃាត់មិត្តកុំឱ្យប្រព្រឹត្តធ្វើនូវអំពើអាក្រក់ ប្រៀបដូចជាជួយឃាត់ផ្លូវកុំឱ្យទៅតំបន់ខ្មាំងសត្រូវ ឬទៅកាន់ចំការមីន ដូច្នោះដែរ ។

បុគ្គលគប្បីលះបង់នូវអំពើអាក្រក់ទាំងឡាយ ដូចជាពួកឈ្មួញដែលមានទ្រព្យច្រើន មានគ្នាតិច គេចវាងយ៉ាងឆ្ងាយអំពីផ្លូវដែលមានចោរប្លន់ ឬក៏ដូចជាបុគ្គលដែលស្រឡាញ់ការរស់ ចៀសវាងនូវថ្នាំពិស យ៉ាងនោះឯង ។

បុគ្គលអ្នកចំរើនបញ្ញា បានឃើញនូវភពបី ដូចជាព្រៃដែលមានចោរប្លន់ ក៏ប្រញាប់រូតរះជំរះផ្លូវទៅកាន់ព្រះនិព្វាន ដែលជាផ្លូវគេចចេញអំពីភពបី ។

ការយកឈ្នះលើខ្លួនឯង ដែលជាអ្នកធ្វើអាក្រក់ សៅហ្មងដោយកិលេស មាយាពុតត្បុត ក្រេវក្រោធឃោរឃៅ ទើបជាការប្រសើរ ចំណែកការឈ្នះលើអ្នកដទៃ មានអ្វីនឹងប្រសើរទៅបាននុ៎ះ ព្រោះថា កាលបើបុគ្គលអប់រំខ្លួនបានល្អហើយ មានប្រក្រតីសង្រួមជាប់ជានិច្ច ដូចនេះ សូម្បីទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម ក៏មិនអាចធ្វើនូវជ័យជំនះនៃបុគ្គលនោះ ឱ្យត្រឡប់ទៅជាបរាជ័យវិញបានឡើយ ។

អ្នកស្រែ អាចធ្វើប្រឡាយបង្ហូរទឹក អំពីទីទួលមកទីទាបតាមការពេញចិត្ត អ្នកធ្វើព្រួញ រមែងពត់ព្រួញឱ្យត្រង់ ជាងឈើធ្វើរទេះ រមែងដាប់ចាំងអារឈូសនូវឈើនោះៗ ឱ្យត្រង់ឬឱ្យកោងតាមដោយទព្វសម្ភារៈដែលត្រូវធ្វើ បណ្ឌិតកាន់យកនិមិត្តទាំងអស់នេះ មកជាអារម្មណ៏ក្នុងការពិចារណា ក៏ធ្វើការទូន្មានចិត្តឱ្យសម្រេចបាន ព្រោះថា ទឹកក្តី ឈើធ្វើព្រួញក្តី ឈើធ្វើរទេះក្តី សុទ្ធតែមិនមានចិត្ត ប៉ុន្តែគេអាចបង្ហូរ ពត់ឱ្យត្រង់ និងចាំងដាប់នូវវត្ថុនោះៗ បានតាមប្រាថ្នា ឯចំណែកមនុស្សមានទាំងកាយ មានទាំងចិត្តដោយពិត ដូចម្តេចក៏មិនអាចធ្វើចិត្តរបស់ខ្លួន ឱ្យប្រព្រឹត្តទៅ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ក្នុងអំណាច ហើយបំពេញនូវធម៌សប់បាននោះ ព្រោះហេតុដូច្នេះ ទើបបណ្ឌិតអាចទូន្មានខ្លួនឯងបាន ការទូន្មានខ្លួនឯងបាន ទើបជាមនុស្សប្រសើរ គឺប្រសើរក្រៃលែង ។

**២. កល្យាណោ និវេសេតិ** ដឹកនាំឱ្យមិត្តប្រព្រឹត្តធ្វើនូវអំពើល្អ ប្រាកដណាស់អំពើល្អគួរដល់ការគោរពដ៏ក្រៃលែង ព្រោះអំពើល្អ បានធ្វើឱ្យបុគ្គលពាលត្រឡប់មកជាបណ្ឌិត កូនមិនដឹងគុណក្លាយមកជាកូនល្អសព្វគ្រប់ មិនត្រឹមតែប៉ុណ្ណោះ អំពើល្អអាចធ្វើឱ្យមនុស្សបុថុជ្ជនម្នាក់ បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធក្នុងលោកទៀតផង ។

បុគ្គលមានបញ្ញា ពិចារណាឃើញគុណតម្លៃនៃអំពើល្អពិតប្រាកដ រមែងសន្សំនូវអំពើល្អនោះដោយខ្លួនឯងផង ដឹកនាំបុគ្គលដទៃដែលគួរដឹកនាំ ឱ្យប្រព្រឹត្តធ្វើនូវអំពើល្អនោះផង អនុមោទនាត្រេកអរនូវគ្រប់អំពើល្អ ដែលអ្នកផងទាំងពួងបានធ្វើហើយផង ។ រមែងជាអ្នកសន្សំបុណ្យ ដោយមិនមើលងាយបុណ្យថាបន្តិចបន្តួច អាត្មាអញមិនចាំបាច់ធ្វើទេ អាត្មាអញធ្វើតែបុណ្យធំៗប៉ុណ្ណោះ យ៉ាងនេះឡើយ ព្រោះថា ការសន្សំបុណ្យ ប្រៀបបីដូចជាគេផ្ងារក្អមកណ្ដាលវាល នៅពេលមានភ្លៀងរលឹមស្រិចៗ ក្អមនោះអាចពេញបានទៅដោយទឹក ដែលស្រក់ចូលម្ដងបន្តិចៗនោះឯង ។

អំពើល្អជាឫសគល់នៃសេចក្ដីសុខ មានមនុស្សច្រើននាក់ណាស់ដែលចង់បាននូវសេចក្ដីសុខ ប៉ុន្ដែមិនធ្វើអំពើល្អឱ្យបានរឿយៗ មិនរក្សានូវគុណធម៌ឱ្យបានគង់វង់ឡើយ ព្រោះហេតុតែមិនច្បាស់ប្រាកដក្នុងចិត្ត ចំពោះឫសគល់នៃសេចក្ដីសុខ ដោយសង្ស័យថា អំពើល្អនាំឱ្យបានសុខពិតមែនឬ ចុះដូចម្ដេចបានជាអ្នកឯណោះគេធ្វើអាក្រក់ខ្លាំងណាស់ ប៉ុន្ដែគេមាន គេបាន ចាយវាយហឺហា ។

ការសង្ស័យ ឧបមាដូចជាផ្លូវឆ្ងាយដែលមានអន្តរាយ មានចោរភ័យជាដើម ផ្លូវរបៀបនេះបានធ្វើឱ្យអ្នកដំណើរមិនហ៊ានទៅត្រូវវង្វេងវង្វាន់ ទីបំផុតគឺមិនអាចបានទៅដល់គោលដៅឡើយ យ៉ាងណា ការសង្ស័យជាគ្រឿងរារាំងនូវកុសលធម៌ បុគ្គលដែលមាននូវសេចក្ដីសង្ស័យ ត្រូវស្ទះដំណើរដែលត្រូវដើរទៅរកសេចក្ដីសុខ ដូចសេចក្ដីឧបមាអំពីផ្លូវឆ្ងាយដែលមាននូវអន្តរាយ យ៉ាងនោះឯង ។

ការសង្ស័យជាគ្រឿងរារាំងនូវកុសលធម៌តើដូចម្ដេច សេចក្ដីនេះមានតួយ៉ាងជាឧទាហរណ៍បញ្ជាក់ឱ្យឃើញងាយៗ ដូចជាមនុស្សដែលមិនសូវយកចិត្តទុកដាក់ក្នុងព្រះធម៌ លុះបានជួបប្រទះ



Document Produced by deskPDF Unregistered :: http://www.docudesk.com

នូវការស្តាប់ធម៌ ដែលសម្តែងអំពីរឿងកម្ម ដែលកម្មមាននាទីចាត់ចែងឱ្យសត្វទាំងឡាយប្រណីតឬថោកទាប មានសុខ មានទុក្ខយ៉ាងណាៗ បានលើកយកហេតុផល ឧបមា ឧបមេយ្យប្រៀបធៀបព្រមដោយពុទ្ធភាសិតផ្សេងៗ ដែលធ្វើឱ្យអ្នកយកចិត្តទុកដាក់ក្នុងព្រះធម៌ កើតសេចក្តីជ្រះថ្លាដ៏ក្រៃលែង ប៉ុន្តែចំណែកអ្នកដែលមិនសូវយកចិត្តទុកដាក់ក្នុងព្រះធម៌ ក៏បែរទៅជាសង្ស័យព្រមទាំងមិនយល់ចូលចិត្តអំពី សត្វទាំងឡាយរមែងប្រព្រឹត្តទៅតាមកម្ម ។ កាលដែលមិនយល់ចូលចិត្តហើយ ក៏កើតការធុញទ្រាន់ មិនចង់ស្តាប់ រួចទៅសភាពនៃចិត្តក៏រាយមាយ នឹករកអារម្មណ៍ដទៃ ដែលតែងតែមានប្រក្រតីធ្លាក់ចុះក្នុងកាមគុណគឺនឹករកអារម្មណ៍ដែលនាំឱ្យសប្បាយរីករាយ រឿងនេះ រឿងនោះមកជំនួសការស្តាប់ព្រះធម៌ ។ កាលដែលនឹករាយមាយយ៉ាងនេះក៏ធុញទ្រាន់នឹងកន្លែងស្តាប់ព្រះធម៌នោះ កើតការអផ្សុក ព្រោះកន្លែងសម្តែងព្រះធម៌នោះ ឮសូរតែធម៌ទេសនា កើតការទាស់ចិត្តមិនគោរពព្រះធម៌ បើមានគ្នាជជែក ក៏ជជែកគ្នានៅពេលនោះទៅ។ លុះដល់ចប់ធម៌ទេសនា សរុបលទ្ធផលបានតែអកុសលស្អេកស្កះ ចំណែករសនៃព្រះធម៌ ដែលឈ្នះអស់រសទាំងពួងនោះ មិនបានលិទ្ធភ្លក្សឱ្យស្គាល់រសជាតិបន្តិចបន្តួចឡើយ នេះឯងវិចិកិច្ឆានីវរណៈ ការសង្ស័យជាគ្រឿងរារាំងនូវកុសលធម៌ ដូចនេះជាដើម ។

ព្រោះហេតុដូច្នេះ ក្នុងនាមជាមិត្តល្អ ឬជាគ្រូបាអាចារ្យមាតាបិតា ត្រូវខិតខំឧស្សាហ៍ដឹកនាំ ពន្យល់ហេតុផលរឿយៗ ដល់មិត្តសម្លាញ់ កូនសិស្ស បុត្តធីតា ឱ្យមានការប្រព្រឹត្តធ្វើនូវអំពើល្អឱ្យមានការចេះដឹង កុំឱ្យនៅមានសេចក្តីសង្ស័យឡើយ នេះជាកិច្ចនាទីសំខាន់ណាស់សម្រាប់អ្នកប្រាថ្នានូវប្រយោជន៍ឱ្យដល់អ្នកដទៃបានសេចក្តីសុខ ។

៣. **អស្សុតំ សាវេតិ** ឱ្យមិត្តបានស្តាប់នូវពាក្យដែលមិនធ្លាប់បានស្តាប់ ពាក្យមានប្រយោជន៍មានច្រើនណាស់ សម្រាប់ដាស់តឿនស្មារតី ជារបស់មានតម្លៃថ្លៃថ្លា ពាក្យសំដីមានរសជាតិធ្វើឱ្យអ្នកស្តាប់ភ្លឺថ្លាគំនិត មានការចម្រើនកើនប្រយោជន៍ ។

ដើម្បីឱ្យទឹកមាត់ប្រៃ ដោយសេចក្តីថា និយាយអ្វីៗគេស្តាប់គេតាម ត្រូវអ្នកនិយាយហ្វាត់ចត់ប្រព្រឹត្តល្អដោយខ្លួនឯងផងប្រៀបដូចរបស់ប្រើប្រាស់ បើជារបស់ថោក សូម្បីនៅថ្មីក៏គេមិនខ្ចីប្រើ ប៉ុន្តែបើជាវត្ថុមានតម្លៃ ទោះបីចាស់ទៅក៏គេតាំងទុកនៅ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ជាទីរលឹក ។

សំពត់សំបកឈើ កាលនៅថ្មីវាមានសម្ពស្សរឹងគ្រោតគ្រាត លុះដល់ចាស់គេច្បាស់ជាជូតជើង ឬចោលក្នុងគំនរសម្រាម យ៉ាងណា មនុស្សឥតបានការ ពុតត្បុតលោភលន់ ល្ងង់ខ្លៅ គេហៅថា មនុស្សសំពត់សំបកឈើ អ្នកណាទៅសេពគប់ជាមួយ រមែងរងទុក្ខរហូតស្លាប់ខ្លួន ដូចសំពត់សំបកឈើដែលមានសម្ពស្សរឹងគ្រោតគ្រាត ធ្វើឱ្យអ្នកស្លៀកលំបាកព្រោះសម្ពស្សនោះ អ៊ីចឹងឯង លុះដល់មនុស្សសំពត់សំបកឈើនោះចាស់ជរាទៅ ឬក៏ស្លាប់ទៅ នៅសល់ កេរ្តិ៍ឈ្មោះអសោចិ៍ គេលើកយកមកប្រដៅកូនចៅ កុំឱ្យប្រព្រឹត្តតាម ដូចសំពត់ដាច់ដាចដែលគេចោលក្នុងគំនរសម្រាមដូច្នោះឯង ។

សំពត់កម្ពលពណ៌ក្រហម ធ្វើក្នុងដែនគន្ធារៈ (សម័យបុរាណ) សាច់ល្អិតម៉ដ្ឋខៃ សម្ពស្សទន់ល្វៃ មានតម្លៃថ្លៃណាស់ ព្រោះគេលំបាកធ្វើ បើអ្នកណាមានសំណាងបានប្រើ បានស្លៀកបានដណ្តប់ ក៏សុខកាយសប្បាយចិត្ត យ៉ាងណា មនុស្សសប្បុរសឆ្លាតឈ្លាសក៏បីដូចសំពត់កម្ពល ដែលមានតម្លៃដូច្នោះដែរ អាចឱ្យអ្នកមកសេពគប់ បានជួបប្រសព្វនូវសេចក្តីសុខ បានស្តាប់ពាក្យពីរោះៗ ពាក្យណាធ្លាប់ស្តាប់ហើយ ក៏កាន់តែបានច្បាស់ឡើង ភ្លឺស្វាងរុងរឿងកាត់ក្តីកង្វល់ ។ សំពត់កម្ពលលុះដល់ពេលចាស់ទៅ ព្រោះតែរបស់មានតម្លៃសរសៃស្វិត គេយកទៅវេចខ្ចប់រតនវត្ថុមានកែវមណីជាដើម យ៉ាងណា មនុស្សបានការ ជាមនុស្សបានផ្តល់ប្រគល់នូវប្រយោជន៍ ឱ្យដល់អ្នកផងទាំងពួង ជាមនុស្សមានស្នាដៃ មានសេចក្តីមិនប្រមាទ ឆ្លាតឈ្លាសវាងវៃ ព្យាយាមតែក្នុងការងារប្រពៃ សូម្បីស្លាប់ទៅ ឬនៅក្នុងវ័យចាស់ កេរ្តិ៍ឈ្មោះពុំសាបសូន្យ កេរ្តិ៍ឈ្មោះនិងស្នាដៃអាចខ្ចប់សេចក្តីល្អរបស់អ្នកដទៃ ដូចសំពត់មានតម្លៃថ្លៃប្រណីត ទោះបីចាស់ពិតតែគេពុំចោលឡើយ គេដាក់ក្នុងហិបអប់គ្រឿងក្រអូប រុំខ្ចប់របស់មានតម្លៃដទៃផ្សេងទៀតបានយ៉ាងល្អ ។

**៤. សគ្គស្ស មគ្គំ អាចិក្ខតិ** ប្រាប់ផ្លូវទៅកាន់ទីកន្លែងដ៏ល្អក្រៃលែង បានដល់ផ្លូវបុណ្យកុសល ផ្លូវសុចរិតប្រព្រឹត្តទៀងត្រង់ បុរសស្ត្រីណាដើរតាមផ្លូវនោះ នឹងបានដល់ទីឋានដ៏សុខសាន្តមានស្ថានសួគ៌ ទេវលោក ជាដើម ។

បើប្រៀបទៅជាមួយនឹងស្ថាននរកនោះ ទេវលោក ព្រហ្ម-លោក ពិតជាសុខសាន្ត ប៉ុន្តែនៅតែជាស្ថានមិនទៀងទាត់ដដែលទេ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ទាល់តែព្រះនិព្វានទើបមានលំនឹង បច្ច័យមិនមាន គ្មានការតាក់តែង ស្ងប់ យ៉ាងក្រៃលែង ពិតជាបរមសុខ ។

យើងអាចធ្វើបុណ្យឧទ្ទិសឱ្យដល់ពួកប្រេតជាញាតិ ដើម្បីពួកប្រេតជាញាតិអនុមោទនាត្រេកអរនូវបុណ្យ ដែលយើងបានធ្វើហើយ ការអនុមោទនាជាកុសលមួយប្រភេទ ដែលមានអំណាចខ្លាំងក្លា អាចកាត់ផ្តាច់នូវសេចក្តីទុក្ខក្នុងកំណើតប្រេត ហើយដើរតួជាយានចម្លងមួយ នាំឱ្យពួកប្រេតជាញាតិនោះ ត្រឡប់មកកាន់សុគតិភពវិញ រហូតជ្រុលហួសអំពីកំណើតមនុស្ស ទៅដល់ទេវលោកទៀតផង ប៉ុន្តែជាការចាំបាច់ជាងរឿងឧទ្ទិសបុណ្យឱ្យដល់ពួកប្រេតទៅទៀតនោះ គឺការធ្វើបុណ្យឧទ្ទិសឱ្យខ្លួនឯង ទោះទានក្តី សីលក្តី ភាវនាក្តី ត្រូវតែខ្ជាប់ខ្ជួន ដើម្បីឱ្យខ្លួនរួចអំពីមនុស្សប្រេតក្នុងបច្ចុប្បន្នជាតិនេះឯង ។

អំណាចបុណ្យ មិនត្រឹមតែឱ្យយើងបានរួចអំពីមនុស្សប្រេតអសុរកាយ ក្លាយមកជាមនុស្សពិតប្រាកដប៉ុណ្ណោះទេ គឺអាចឱ្យយើងបានជាមនុស្សទេវតាទៀតផង ។

តាមពិតខ្លួនយើងមិនប្រាកដជាអ្វីនោះទេ ស្រេចតែអំពើកម្មយ៉ាងណា ក៏សន្មតជាមនុស្សតាមកម្មនោះៗទៅ ការបដិបត្តិក្នុងព្រះពុទ្ធសាសនា អាចធ្វើឱ្យខ្លួនយើងបានរួចចាកអំពីកំណើតទាំងអស់ ក្នុងភពបីនេះជាពិតប្រាកដ បើមានបញ្ញាចម្រើនច្រើនឡើងៗ ឃើញសង្ខារធម៌ដែលសន្មតថាជាខ្លួនយើងនោះ ត្រឹមតែជារបស់មិនទៀងប៉ុណ្ណោះ មិនមានអ្វីប្រាកដជាខ្លួនយើងឡើយ ដូចជាអំពើកម្មអ៊ីចឹង បើជាបាបកម្មក៏សន្មតថាខ្លួនយើង ជាមនុស្សនរកឬមនុស្សប្រេត បើជាបុញ្ញកម្មជាប់ជានិច្ចកាល ក៏សន្មតថាជាមនុស្សពិតឬក៏ជាមនុស្សទេព មនុស្សព្រហ្មទៅតាមកម្មដ៏ប្រសើរហ្នឹងអ៊ីចឹងទៅ តែបើបញ្ញាឃើញកម្មនោះៗ ពុំមែនជាសត្វបុគ្គល តួខ្លួនយើង **ខ្លួនយើងក៏ជាមនុស្សនិព្វាន មនុស្សស្ងប់** ព្រោះការរលត់អស់ទៅនូវសេចក្តីយល់ខុស ដោយសព្វគ្រប់ ។

ជីវិតសត្វលោករមែងប្រព្រឹត្តទៅតាមកម្ម មានបុគ្គលច្រើនណាស់ដែលមិនច្បាស់ក្នុងសេចក្តីពិតនេះ ព្រោះហេតុតែកម្មថ្មីៗក្នុងបច្ចុប្បន្នជាតិ បិទបាំងនូវកម្មចាស់ គេក៏យល់បញ្ច្រាសថាធ្វើអាក្រក់នាំឱ្យបានសុខ ធ្វើល្អនាំឱ្យបានទុក្ខ ការយល់ច្រឡំច្របូកច្របល់ ចំពោះកម្មនិងផល វាជារឿងល្ងង់របស់សត្វលោក ធ្វើឱ្យសត្វលោកពិការនូវស្មារតីដ៏យ៉ាងក្រៃលែង ។

ឧទាហរណ៍ដូចមនុស្សខ្លះមិនបានធ្វើស្រែជាច្រើនឆ្នាំមក



Document Produced by deskPDF Unregistered :: http://www.docudesk.com

ហើយ ទើបតែស្ទូងនៅក្នុងឆ្នាំនេះ មនុស្សនេះកំពុងតែដកស្ទូង ហើយក៏កំពុងតែអត់បាយផងដែរ រឿងនេះតើគួរយល់ថា មក អំពីឆ្នាំនេះគេធ្វើស្រែ បានជាគេអត់បាយដែរឬទេ ? មនុស្សខ្លះ ទៀតធ្វើស្រែរហូតមក មានស្រូវពេញជង្រុក ប៉ុន្តែឆ្នាំនេះខ្ជិល ណាស់ របរអ្វីក៏មិនរកដែរ គេដេកស៊ីកាន់ខែមកហើយ សភាព យ៉ាងនេះតើគួរយល់ថា គេបានដេកស៊ីស្រួលៗព្រោះតែគេមិនធ្វើ ស្រែដែរឬទេ ?

តាមពិតច្បាប់ធម្មជាតិក្នុងលោកទាំងអស់ វាជាច្បាប់ ហេតុផលប្រាកដណាស់ ដាំពូជយ៉ាងណា រមែងបានផលផ្លែផ្កា យ៉ាងនោះ ទោះបីមានក្លាយខ្លះក៏ព្រោះវាមានហេតុរបស់វាដែរ ដូចជាជាតិដី អាកាសធាតុ រដូវ ។ល។ មានខ្លះក្លាយទៅតាម រុក្ខជាតិដទៃ ដែលអាស្រ័យនៅជិតវា ប៉ុន្តែទោះជាយ៉ាងណា ក៏វា មិនក្លាយឆ្ងាយអំពីពូជពេកឡើយ ។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែក្នុងច្បាប់ហេតុនិងផល ដែរ ផល១វាមិនមែនកើតតែអំពីហេតុ១ទេ គឺហេតុច្រើនយ៉ាង ណាស់ ដូចជាមនុស្សដែលបានកើតមកនេះ មានក្រល្អជា ពិការគ ថ្លង់ យ៉ាងណាៗ គឺជាផលរបស់ហេតុក្នុងជាតិមុនខ្លះ និង ជាតិ



នេះខ្លះ មនុស្សកើតអំពីបុណ្យ គឺអំពើល្អក្នុងជាតិមុនប្រាកដណាស់ គ្រាន់តែថា បុណ្យនោះពេញឬខ្វះ តិចឬច្រើន ខុសគ្នាតែប៉ុណ្ណោះ លុះកើតហើយ វាត្រូវមានបុណ្យឬបាបដទៃទៀត ទាំងក្នុងជាតិ មុន ទាំងក្នុងជាតិនេះ ចូលជួយឧបត្ថម្ភ ឬបៀតបៀនកាត់បង់យ៉ាង ណាៗ វាជាធម្មតានៃសង្ខារធម៌ ដែលមិនមានអំណាចខ្លួនឯង វា រមែងប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។

ការសេពគប់ ជាបច្ច័យដ៏មានកម្លាំងមួយបែប ដែលអាច ធ្វើឱ្យផលផ្លាស់ប្តូរប្រែប្រួល ខុសអំពីហេតុដើម វាដូចជាផ្លែឈើ ដែលក្លាយអំពីពូជដើមរបស់វាដូច្នោះដែរ សេពគប់មិត្តខុសនាំឱ្យ ស្លាប់ សេពគប់មិត្តត្រូវនាំឱ្យរស់ មនុស្សល្ងង់មានខ្លួនឯងជាសត្រូវ នឹងខ្លួនឯង ចំណែកអ្នកប្រាជ្ញមានខ្លួនឯងជាទីពឹង ។

**ឃ/ -មិត្តល្អចំពូកទី IV គឺមិត្តចេះមានចិត្តឈឺឆ្អាល មាន លក្ខណៈ ៤ យ៉ាងគឺ :**

**១. *អភវេនស្ស ន នន្ទតិ*** មិនត្រេកអរនៅពេលមិត្តមាន សេចក្តីវិនាស សេចក្តីវិនាស ៥ យ៉ាង បានដល់ :

- វិនាសញាតិ ១
- វិនាសទ្រព្យសម្បត្តិ ១

Document Produced by deskPDF Unregistered :: http://www.docudesk.com

- វិនាសសុខភាពព្រោះមានរោគ ១

- វិនាសសីល ១

- វិនាសការយល់ត្រូវ ១ ។

នាងបដាចារា មានការជួបប្រទះនូវសេចក្តីវិនាសញាតិយ៉ាងខ្លាំង ព្រាត់ចាកជនជាទីស្រឡាញ់ ហើយក៏មានវិបត្តិស្មារតីរហូតដល់ឆ្កួត ប៉ុន្តែត្រូវបានព្រះសម្មាសម្ពុទ្ធជួយស្រោចស្រង់ឱ្យមាននូវសតិឡើងវិញ រហូតដល់ទទួលយកបាននូវព្រះធម៌ទេសនា សម្រេចជាសាវិកាដ៏ឆ្នើមមួយរូប ក្នុងព្រះពុទ្ធសាសនា ។

វិបត្តិនៅក្នុងជីវិត សុទ្ធតែអាចដោះស្រាយបានទាំងអស់ ឱ្យតែខ្លួនឯងព្រមជួយខ្លួនឯង និងអាស្រ័យជំនួយអំពីមិត្តល្អផង ដូច្នេះធ្វើជាមនុស្សត្រូវតែចេះបណ្តុះបណ្តាល ប្រាជ្ញាស្មារតីរបស់ខ្លួន ដើម្បីជួយខ្លួនឯង និងជួយដោះស្រាយនូវវិបត្តិឱ្យដល់អ្នកដទៃ កុំបីខាន ។

អកុសលនីវរណៈ សុទ្ធតែជាគ្រឿងរារាំងនិងបំផ្លាញសុខភាពស្មារតី ប្រាជ្ញាវាងវៃត្រូវបាត់បង់អស់ ឬមិនចម្រើនឡើងឡើយ ដូចជាការភ្លើតភ្លើនក្នុងកាមគុណ ការបណ្តោយចិត្តឱ្យទំពាស៊ីនូវកាមារម្មណ៍រឿយៗ គំនុំព្យាបាទ កំហឹងខឹងក្រោធ ការខ្ជិលសំអាតចិត្ត សុខស្រួលតែនឹងដេកដំណេកជ្រុកស្រុក ។ល។ ទាំងអស់ជាដើមនេះសុទ្ធតែជាមេរោគ ជាសត្រូវ ជាគ្រឿងរារាំងផ្លូវមិនឱ្យកុសលធម៌ដទៃចូលមកជួយឧបត្ថម្ភ ទំនុកបំរុងនូវសតិសម្បជញ្ញៈបានឡើយ ។

មនុស្សទន់ខ្សោយនូវសតិសម្បជញ្ញៈ រមែងធ្វើការច្របូកច្របល់ មិនគោរពតួនាទីរបស់ខ្លួន ឬគោរពមិនបានល្អ មិនបានសព្វគ្រប់ពេញលេញឡើយ ។ មនុស្សយើងកើតមកមានតួនាទីច្រើនណាស់ ក្រៅពីតួនាទីជាមនុស្ស នៅមានតួនាទីជាម៉ែឪ តួនាទីជាបុត្តធីតា តួនាទីជាគ្រូអាចារ្យ តួនាទីជាសិស្ស តួនាទីជាប្តី តួនាទីជាប្រពន្ធ តួនាទីជាមិត្ត តួនាទីជាចៅហ្វាយនាយ តួនាទីជាទាសកម្មករ តួនាទីជាអ្នកបួស ជាសមណព្រាហ្មណ៍ តួនាទីជាពុទ្ធបរិស័ទ តួនាទីជាអ្នកគ្រប់គ្រងភូមិស្រុកប្រទេសខេត្តខ័ណ្ឌ តួនាទីជាពលរដ្ឋ និង ជាពិសេសតួនាទីដោះស្រាយបញ្ហាជីវិត ដែលជីវិតខ្លួនឯងបាននាំមកជាមួយនូវបញ្ហាទាំងនោះ ។ ជីវិតពិតជាទុក្ខ ទាំងពេលកើត ទាំងពេលចាស់ ទាំងពេលឈឺ ទាំងពេលស្លាប់ ជីវិតជាទុក្ខព្រោះលំបាកលំបិនក្នុងជីវភាពទីទ័លក្រ បើជាអ្នកធូរធារដោយសម្បត្តិ ជីវិតក៏ជាទុក្ខព្រោះលំបាកក្នុងការស្ងួនគ្រងរក្សា ទោះបី



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

មានសេចក្តីសុខខ្លះក្នុងជីវិតនេះ ក៏សេចក្តីសុខនេះគ្រាន់តែជាធម្មជាតិម្យ៉ាង សម្រាប់បង្កើតតណ្ហា ដែលជាហេតុនៃសេចក្តីទុក្ខមិនដាច់តែប៉ុណ្ណោះ សេចក្តីសុខក្នុងលោក ជាសង្ខតធម៌ ជារបស់មារ ប្រៀបដូចទឹកឃ្មុំលាយឡំទៅដោយថ្នាំពិស ។

ធ្វើជាមនុស្ស ត្រូវចេះទទួលស្គាល់គ្នា យ៉ាងហោចណាស់ក៏ចេះទទួលស្គាល់ថា គេជាមនុស្សជាអ្នកបានធ្វើបុណ្យអំពីជាតិមុនមកដែរ គ្រប់គ្នាទាំងអស់បានមកកើតក្នុងលោកនេះ មិនមានអ្វីជារបស់ខ្លួនពិតប្រាកដឡើយ បានត្រឹមតែសន្មតមួយពេលមួយគ្រាតែប៉ុណ្ណោះ ដូច្នេះមិនត្រូវអាស្រ័យវត្ថុក្នុងលោកនេះ ហើយមើលងាយដល់អ្នកដទៃនោះទេ ត្រូវខំពង្រឹងស្មារតី រកឧបាយទប់ស្កាត់នូវកិលេសជាគ្រឿងរារាំងដល់សេចក្តីស្ងប់ ប្រញាប់រូតរះជម្រះផ្លូវមួយ សម្រាប់ចេញចាកលោកដោយមិនអាល័យ បានដល់អរិយ-មគ្គអង្គ ៨ ។

**២. ភវេនស្ស នន្ទតិ** ជួយត្រេកអរចំពោះការចំរើនរបស់មិត្ត ការមិនច្រណែនពន្លត់ភ្លើងឈ្នានីស ឯការច្រណែនវិញ រមែងដុតលោកនេះឱ្យឆេះទ្រលោម ដោយការព្យាបាទបៀតបៀនគ្នាពាក្យសម្តីចាក់ដោត និយាយដោយចិត្តឥតមេត្តា ដូច្នេះការមិនច្រណែនជាផ្កាឈូក ផុសទ្រទ្រសត្វលោកទាំងពួង ឱ្យផុតអំពីសមុទ្រភ្លើងកម្មពៀរវេរា ។

កើតមកជាមនុស្ស គួរតែខំប្រឹងរស់ដោយខ្លួនឯង គ្មានចាំបាច់ទៅច្រណែនអ្វីជាមួយអ្នកដទៃឡើយ គួរចម្រើននូវមេត្តាឱ្យរឿយៗ ព្រោះមេត្តានេះឯងហើយ ជាជំរកដ៏ប្រសើររបស់ចិត្ត ។

កើតមកជាមនុស្ស បើមិនបានចិញ្ចឹមអ្នកដទៃទេ ក៏គួរតែចិញ្ចឹមខ្លួនឯងឱ្យរស់ ដោយមិនបៀតបៀនអ្នកដទៃ ការចូលចិត្តសុំតាំងតែអំពីជីវស្លឹកគ្រៃជាដើមនោះ វាជាមារយាទមិនល្អ រាប់ចូលក្នុងលក្ខណៈបៀតបៀនគេដែរ មើលចុះ មេគោស៊ីតែស្មៅ ប៉ុន្តែវាមានទឹកដោះឱ្យមនុស្សបៅ ជាទូទៅពាសពេញស្រុក តើធម្មជាតិបង្កើតមនុស្សមក សម្រាប់ឱ្យមនុស្សទន់ខ្សោយ ខ្វះនូវសមត្ថភាពជាងមេគោទៅទៀតឬ ?

តាមពិតមនុស្សមាននូវសមត្ថភាពដ៏ក្រៃលែង អាចធ្វើឱ្យខ្លួនឯងបានបរិសុទ្ធ ជាទីពំនាក់អាស្រ័យនៃមនុស្ស និង ទេវតាបានទៀតផង វាចារបស់មនុស្សបរិសុទ្ធ ពិតជាពិសេសជាងទឹកដោះរបស់មេគោ អាចធ្វើឱ្យអ្នកក្រេបជញ្ជក់រសជាតិនៃពាក្យសម្តីនោះស្ងប់រម្ងាប់ចិត្ត កំចាត់តណ្ហាដែលជាការស្រេកឃ្លាន បាននូវសេចក្តី

ឆ្អែតដ៏យ៉ាងប្រសើរបំផុត ដូច្នេះធ្វើជាមនុស្សត្រូវខិតខំបណ្តុះបណ្តាលសមត្ថភាពរបស់ខ្លួនឯងឱ្យបានរឹងប៉ឹង ទាំងឱ្យនៅក្នុងគន្លងធម៌ល្អទៀតផង ។

លាភ យស សរសើរ សុខ ជាវត្ថុនាំឱ្យកើតការច្រណែនដោយគិតថា គេគ្រាន់បើជាងខ្លួន ប៉ុន្តែមានវត្ថុមួយពិសេសផ្សេងក្រៃលែងជាងលាភ យស សរសើរ សុខក្នុងលោកនេះទៅទៀត គឺបញ្ញារំលត់ការប្រកាន់ ថាមានតួខ្លួន ។

ខ្លួនឯងដោយពិតក្នុងបរមត្ថនាមរូប ពុំមានសោះឡើយ ដូច្នេះសេចក្តីប្រកាន់ ការលោភលន់ ការខឹងច្រឡោត ជាដើមនេះ សុទ្ធតែជាទិសដៅដែលត្រូវកំចាត់ ដោយការចំរើនបញ្ញា ។

គួរខ្លាសសេចក្តីល្ងង់ ល្ងង់នាំឱ្យវង្វេង ល្ងង់នាំឱ្យកើតការច្រណែនឈ្នានីស មិនត្រូវទុកឱ្យខ្លួនឯងល្ងង់រឿយៗទៅនោះទេ ត្រូវព្យាយាមកំចាត់ដោយការអុជប្រទីបបំភ្លឺគឺចម្រើនបញ្ញា បុគ្គលមានបញ្ញារំលត់ការប្រកាន់នូវនាមរូប ឃើញច្បាស់ថា រកតែតួខ្លួនឯងមិនមានយ៉ាងនេះ ក៏ត្រូវបញ្ចប់ការច្រណែន ជាអ្នកបានរួចផុតអំពីទីដែលគួរឱ្យស្លុតខ្លាច ហើយបានដល់កន្លែងដែលមានទីពឹងកក់ក្តៅក្រៃលែង ។



**៣. អវណ្ណំ ភណមានំ និវារេតិ** ហាមឃាត់មនុស្សដែលនិយាយអាក្រក់អំពីមិត្ត គឺមិត្តមានការជួយឃើរ្អាល មិនបណ្តោយឱ្យគេចេះតែនិយាយអំពីរឿងអ្វីៗ ដែលជាសេចក្តីមិនល្អផ្សេងៗរបស់មិត្តសម្លាញ់ឡើយ ។

ជាធម្មតានៃមនុស្សដែលច្រើនដោយកិលេស ចូលចិត្តជួបជុំគ្នានិយាយអំពីរឿងអ្នកដទៃ ជាពិសេសរឿងអាស្រូវរបស់គេ ពីព្រោះហេតុតែចង់បង្ហាញខ្លួនឯង ឱ្យគេស្គាល់ថាជាអ្នកគ្រាន់បើ ជួនកាលនិយាយព្រោះស្អប់ ដោយសារគេនោះធ្លាប់ធ្វើឱ្យខ្លួនទាស់ចិត្ត អំពីរឿងអ្វីមួយ ហើយក៏គុំគួនគេទុកក្នុងចិត្តទៅ ជួនកាលនិយាយអាក្រក់អំពីគេព្រោះច្រណែន ជួនកាលព្រោះតែចង់បង្អួតខ្លួនប្រាប់គេថា ខ្លួនឯងពូកែដឹងរឿងច្រើនតែប៉ុណ្ណោះ ព្រមដោយការខ្វះមេត្តា ក៏និយាយឥតសំចៃមាត់ទៅ ជួនកាលខ្លះទៀតចង់យកចិត្តគូជដែក កាលគូជដែកនោះខឹងស្អប់អ្នកណាៗហើយ ក៏ខំប្រឹងរករឿងអាក្រក់អំពីអ្នកនោះ ដើម្បីយកមកនិយាយឱ្យត្រូវគ្នា សរុបសេចក្តីមកព្រោះបីសាចគឺកិលេស ក្នុងចិត្តរបស់អ្នកនិយាយហ្នឹងឯង ដែលនាំឱ្យមានវាចាអាក្រក់ជាវចីទុច្ចរិត និយាយកុហក និយាយញុះញង់ និយាយទ្រគោះបញ្ឈឺចិត្តអ្នកដទៃ និង ពាក្យសម្តី

Document Produced by deskPDF Unregistered :: http://www.docudesk.com

និយាយឥតប្រយោជន៍ ។

កិរិយាមិនធ្វើនូវបាបទាំងពួង១ កិរិយាបំពេញកុសល១ កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់១ ទាំង៣នេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

អំណត់គឺសេចក្ដីអត់ធន់ ជា តបធម៌ គឺធម៌ជាគ្រឿងដុតបំផ្លាញនូវបាបដ៏ក្រៃលែង ព្រះសម្មាសម្ពុទ្ធក្ដី ព្រះបច្ចេកពុទ្ធក្ដី ព្រះអនុពុទ្ធក្ដី បានសម្ដែងថា ព្រះនិព្វានជាគុណដ៏ក្រៃលែង (ជាកំពូលនៃធម្មរតនៈ) អ្នកសម្លាប់សត្វដទៃក្ដី អ្នកបៀតបៀនដោយការប្រហារវាយតប់ បំផ្លិចបំផ្លាញអ្នកដទៃក្ដី មិនមែនជាសមណៈអ្នកស្ងប់រម្ងាប់ ទាំងមិនមែនជាបព្វជិតអ្នកបួសវៀរចាកបាបដោយទូទៅឡើយ ។

កិរិយាមិនតិះដៀលអ្នកដទៃ១ កិរិយាមិនបៀតបៀន (បំផ្លាញឬសម្លាប់) អ្នកដទៃ១ កិរិយាសង្រួមក្នុងព្រះបាតិមោក្ខ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់១ កិរិយាបំពេញសេចក្ដីព្យាយាមក្នុងអធិចិត្ត១ ទាំង៦នេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

កិរិយាមិនតិះដៀលអ្នកដទៃ គឺជាសីលល្អផ្នែកខាងសម្ដី កិរិយាមិនបៀតបៀន បំផ្លាញឬសម្លាប់សត្វដទៃ គឺជាសីលល្អតាមផ្លូវកាយ កិរិយាសង្រួមក្នុងព្រះបាតិមោក្ខ គឺបាតិមោក្ខសីល បានដល់សីលដែលជាប្រធាននាំឱ្យរួចផុតចាកទុក្ខ និង ឥន្ទ្រិយសំវរសីល បានដល់សីលបិទនូវកិលេសតាមទ្វារ៦ មានចក្ខុទ្វារជាដើម ។

ភាវៈដឹងប្រមាណក្នុងភត្តាហារ គឺជាសីលដែលនាំឱ្យបរិសុទ្ធក្នុងការចិញ្ចឹមជីវិត និង ជាសីលបន្សាបពិសក្នុងបច្ច័យ៤ ប្រើប្រាស់ទៅគ្មានទោស គ្មានបំណុល ចំណែកទីដេកនិងទីអង្គុយដ៏ស្ងាត់ គឺទីនៅដែលជាកន្លែងសប្បាយ ហាក់ដូចជាថ្នាំរម្ងាប់រោគប្រចាំកាយ ឬជាថ្នាំថែរក្សាសុខភាព ព្រោះជាកន្លែងស្ងាត់ចាកសត្រូវខាងក្រៅ មានលាភសក្ការៈ និង កាមារម្មណ៍ជាដើម ។

កិរិយាបំពេញសេចក្ដីព្យាយាមក្នុងអធិចិត្ត គឺការរុករកនូវសេចក្ដីសុខស្ងប់ក្នុងចិត្តរបស់ខ្លួន ដូចជាការជីកយកកំណប់ក្រោមផ្ទះដែលកប់ជ្រៅក្នុងដី និងមានថ្មដាសង្កត់អំពីលើ អធិចិត្តបានដល់ចិត្តស្ងប់ដ៏ក្រៃលែង (សមាបត្តិ៨) ជាបទដ្ឋាននៃបញ្ញា ជាជំនួយដល់ការចំរើនសតិប្បដ្ឋាន តាមដោយឥន្ទ្រិយខ្លាំងក្លា ឧបមាដូចឈើស្ងួតពួតចេញជាភ្លើង ឆេះបំភ្លឺក្នុងវេលារាត្រីកំចាត់ភាពងងឹតអន្ធការ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

**៤. វណ្ណំ ភណមានំ បសំសតិ** សរសើរនូវមនុស្សណា ដែលនិយាយរឿងល្អ ពណ៌នាគុណរបស់មិត្ត នេះជាលក្ខណៈមិត្តល្អ ដែលតែងតែជួយឃើធ្លាល ។

នៅពេលយើងសរសើរអ្នកដទៃណាម្នាក់នោះ ត្រូវបញ្ជាក់អំពីកិច្ចការដែលគួរឱ្យសរសើរនោះផង ព្រោះវាអាចធ្វើឱ្យអ្នកស្តាប់យល់ច្រឡំ ក្នុងបុគ្គលដែលយើងសរសើរនោះ បើយើងមិនបានបញ្ជាក់អំពីចំណុចល្អឱ្យបានពិតប្រាកដទេ ។

យើងសរសើរអ្នកណាម្នាក់ដែលធ្វើអាក្រក់ ខ្លួនយើងដែលជាអ្នកសរសើរគេនោះ អាចបាបជាងអ្នកដែលធ្វើអាក្រក់នោះទៅទៀត ព្រោះនាំឱ្យមានអ្នកដទៃមិនតិចនាក់ទេ ហ៊ានធ្វើនូវអំពើអាក្រក់ផ្សេងៗ ដោយមកអំពីបានស្តាប់ឮពាក្យសរសើររបស់យើង ក្នុងសេចក្តីនេះក៏គួរបានជ្រាបផងដែរ អំពីការពោលសរសើរចំពោះបុគ្គលដែលគួរឱ្យសរសើរ យ៉ាងពិតប្រាកដនោះ បើវាចាររបស់យើង ឬក៏ការងាររបស់យើងជាធម្មទាន នេះជាទានឈ្នះអស់ទានទាំងពួង ។

ការពោលសរសើរឬក៏និន្ទាចំពោះទៅអ្នកណាម្នាក់នោះ ត្រូវពិចារណាឱ្យបានល្អិតល្អន់ ព្រោះវាជាគ្រោះកំណាចដ៏ក្រៃលែង បើសិនជាយើងសរសើរចំទៅលើមនុស្សទ្រុស្តសីល ហើយបែរជាទៅនិន្ទា ចំលើអ្នកទ្រទ្រង់នូវសីលទៅវិញនោះ គឺវាគ្រោះថ្នាក់ជាងផឹកទឹកទង់ដែង ដែលកំពុងរលាយដោយអំណាចភ្លើងនោះទៅទៀត ។

✧α✧α✧α✧α✧
✧α✧α✧α✧
✧α✧α✧
✧α✧
✧



Document Produced by deskPDF Unregistered :: http://www.docudesk.com

# អំពីការងារ ៣ មុខ
# តាមឱវាទព្រះពុទ្ធគ្រប់ព្រះអង្គ

≈≈≈≈≈

១- ការងារសង្រួមកាយ ការងារសង្រួមវាចា ការងារសង្រួមចិត្ត ពិតជាការងារប្រចាំថ្ងៃ នៃជនប្រុសស្រី ទាំងគ្រហស្ថ ទាំងបព្វជិត ព្រោះជាការបិទទ្វារការពារទប់ស្កាត់នូវបាបថ្មីៗ កុំឱ្យចូលមករួមដៃជាមួយបាបចាស់ កាត់បន្ថយកម្លាំងបាបដែលសន្សំក្នុងសន្តានចិត្ត ប្រៀបបីដូចជាបុគ្គលដែលខំព្យាយាមតមចំណីទាស់ ព្រោះហេតុតែខ្លួនឯងឈឺរោគថ្លើម ដូច្នោះឯង ។

២- ការងារបំពេញសេចក្តីល្អ ពិតជាត្រូវធ្វើបន្តមិនឱ្យដាច់ ធ្វើទានរឿយៗ រក្សាសីលជាប់លាប់ អប់រំចម្រើនសេចក្តីស្ងប់ជាប្រចាំ រៀនធម៌ស្តាប់ធម៌បំពេញចំណេះ ទាំងអស់នេះសុទ្ធតែជាការងារបំប៉ននូវស្មារតី ប្រៀបបីដូចអ្នកឈឺថ្លើម ខំប្រឹងថែសុខភាព បំប៉នចំណីល្អៗ ប្រើប្រាស់អ្វីៗមានអនាម័យ ដើម្បីជួយកម្លាំងគ្រប់សង្កត់នូវរោគ ដូច្នោះដែរ ។



៣- ការងារអប់រំចម្រើននូវសតិប្បដ្ឋាន៤ គឺជាការងារស្រាវជ្រាវរាវរកសេចក្តីពិត ក្នុងជីវិតដែលមានតែរូបធម៌ និង នាមធម៌ ដើម្បីកំចាត់បង់នូវការវង្វេង ព្រមដោយការប្រកាន់ខុសផ្សេងៗ ប្រព្រឹត្តទៅដើម្បីអរិយមគ្គជាលោកុត្តរ ប្រហារបង់នូវអនុស័យ ។ ចំពោះកិលេស ឬ នីវរណៈច្រើនៗក្នុងជីវិតប្រចាំថ្ងៃ វាជាមេរោគចង្រៃ បើទុកឱ្យវាចេះតែរីកច្រើនឡើងៗ ជាការលំបាកក្នុងការសម្លាប់វាឱ្យអស់ណាស់ ដូច្នេះជាមួយគ្នានឹងការចំរើនសតិប្បដ្ឋាន៤ ពុទ្ធបរិស័ទរមែងបំពេញនូវការងារមួយទៀត គឺការងារគ្របសង្កត់នូវនីវរណធម៌ ការស្តាប់ព្រះធម៌ពីរោះ មានសេចក្តីជ្រះថ្លា មានការតាំងចិត្តមាំទាំក្នុងពេលស្តាប់នោះ ក៏ជាការគ្របសង្កត់នូវនីវរណធម៌ដោយពិត ម្យ៉ាងទៀតព្រោះការប្រកបព្យាយាមក្នុងអធិចិត្ត គ្របសង្កត់នូវនីវរណៈដោយសមថកម្មដ្ឋាន សេចក្តីនេះប្រៀបដូចអ្នកឈឺរោគថ្លើម ក្នុងការប្រើប្រាស់ថ្នាំ រមែងប្រើប្រាស់ថ្នាំពីរមុខ គឺមួយមុខសម្រាប់ហ៊ុមព័ទ្ធមេរោគ និង មួយមុខទៀត សម្រាប់ជំនួយដល់ការប្រហារនូវមេរោគនោះ ដូច្នោះឯង ។

ការចម្រើនសតិប្បដ្ឋាន៤ ជាការដុសខាត់សេចក្តីប្រកាន់

Document Produced by deskPDF Unregistered :: http://www.docudesk.com

រឿយៗ បញ្ញាក៏ភ្លឺថ្លាឡើងៗ ហើយរមែងជាឧបការៈដល់កុសលធម៌ដទៃទៀតគ្រប់យ៉ាងទាំងអស់ សតិប្បដ្ឋាន៤ជាគំនរនៃកុសលធម៌ ការចម្រើនសតិយ៉ាងនេះរឿយៗ រមែងឈានទៅរកការឃើញច្បាស់មួយថា «ធម៌ទាំងឡាយទាំងពួង គឺកុសលធម៌ អកុសលធម៌ និង អព្យាកតធម៌ គ្រាន់តែជាខន្ធ អាយតនៈ ធាតុ តែប៉ុណ្ណោះ ពុំមែនជាសត្វសោះឡើយ ហើយមិនគួរប្រកាន់ថាជារបស់មាំមួនទៀតផង » ។

✧α✧α✧α✧α✧
✧α✧α✧α✧
✧α✧α✧
✧α✧
✧



# អំពីការខារស្វែងយល់នូវលក្ខណៈ សំខាន់ ៣ យ៉ាង

≈≈≈≈≈

១-<u>លក្ខណៈព្រះពុទ្ធសាសនា</u> ព្រះអង្គទ្រង់ត្រាស់សំដែងថា «ខន្តីជា-តបធម៌ដ៏ឧត្តម» តបធម៌គឺធម៌ជាគ្រឿងដុតបំផ្លាញនូវកិលេសក្នុងសន្តានចិត្ត មនុស្សសម័យដើមមុនព្រះអង្គបានត្រាស់ដឹង គេនិយមធ្វើតបធម៌ច្រើនបែប ច្រើនយ៉ាងណាស់ ប៉ុន្តែសុទ្ធតែជារបៀបធ្វើខ្លួនឱ្យលំបាកឥតប្រយោជន៍ ជាការធ្វើទារុណកម្មយ៉ាងខ្លាំងក្លា ឱ្យដល់រូបកាយរបស់ខ្លួនឯង ដោយយល់ថា ធ្វើរបៀបនេះនឹងនាំឱ្យគេបានបរិសុទ្ធ ដល់ទីបំផុតនៃសាសនាឬលទ្ធិរបស់គេ ។

តាមពិតកិលេសមិនមែនមានរូបកាយជាប្រភពនៃកំណើតនោះទេ សូម្បីសត្វក្នុងអរូបភពក៏នៅមានកិលេសដែរ ប៉ុន្តែប្រភពពិតប្រាកដរបស់កិលេស គឺអវិជ្ជាដែលមិនដឹងនៅក្នុងសច្ចធម៌ ។

អំណត់គឺសេចក្តីអត់ធន់ ជាភ្លើងដុតកំទេចនូវអវិជ្ជា ព្រោះ

Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

សេចក្តីអត់ធន់ជាកម្លាំង ក្នុងការញ៉ាំងកុសលធមិទាំងពួងឱ្យសម្រេច ដូចកម្លាំងកាយរបស់បុរស ដែលញ៉ាំងឱ្យការងារនោះៗ មានការ ភ្ជួររាស់ជាដើម សម្រេចទៅបាន ។

សេចក្តីអត់ធន់គឺជាវិជ្ជាមួយដ៏យ៉ាងខ្ពង់ខ្ពស់បំផុត ដែលសត្វលោកមិនងាយរៀនចេះ ប៉ុន្តែបើបុគ្គលណាប្រកបបាននូវវិជ្ជានេះ បុគ្គលនោះរមែងរួចផុតអំពីការញាប់ញ័រ ដោយលោកធមិទាំង៨ គឺ : មានលាភ១ , អត់លាភ១ , មានយស១ , អត់យស១ សរសើរ១ , និន្ទា១ , សុខ១ , ទុក្ខ១ ។

ក្នុងជីវិតទាំងគ្រហស្ថ ទាំងបព្វជិត សុទ្ធតែមានសេចក្តីលំបាក ដូច្នេះទើបគ្រប់គ្នាត្រូវចេះអត់ទ្រាំ គឺអត់ទ្រាំបំពេញការងារតាមតួនាទី ទាំងជាការងារប្រាសចាកទោសផង ឱ្យសម្រេចទៅបាន ជាពិសេសគឺអត់ទ្រាំបានចំពោះអារម្មណ៍ក្នុងលោក រឿងរ៉ាវផ្សេងៗ ដែលមានជាប្រចាំក្នុងជីវិត ។

អារម្មណ៍ឯណាមួយក្នុងលោក អារម្មណ៍នោះគេតែងរៀន គឺរៀនទទួលយកដោយស្មារតី រៀនទ្រាំអត់ស្រឡាញ់ អត់ស្អប់ អត់វង្វេង អត់ស្រវឹង អត់តក់ស្លុត និង រៀនលះបង់ ។

ចំពោះវិជ្ជាថ្នាក់ឧត្តមក្នុងជីវិត គឺវិជ្ជាអាចទ្រាំបាន ឃើញអារម្មណ៍ក្នុងលោកទាំងអស់ ជារបស់សម្រាប់ស្រាវជ្រាវ ឃើញការទ្រាំបានជាការរៀនចប់ ឃើញការមិនជាប់ជំពាក់ ជាសញ្ញាប័ត្រនៃការប្រឡងចេញ ។

ដូច្នេះលក្ខណៈសំខាន់ដែលត្រូវយល់ដឹង គឺព្រះពុទ្ធសាសនាមានការទ្រាំបាន ជាលក្ខណៈ ការទ្រាំបានគឺជាទង់ជ័យព្រះពុទ្ធសាសនា ។

២-លក្ខណៈទិសដៅ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា « ព្រះនិព្វានជាបរមធមិ » ស្ងប់ពិត ប្រណីតពិត ផុតទុក្ខទាំងពួង ជាលក្ខណៈនៃទិសដៅដែលត្រូវសម្រេចដល់ ជាផលសម្រេចនៃតបធមិ ។

មនុស្សមុនសម័យព្រះអង្គត្រាស់ដឹង គេធ្វើតបៈរបស់គេ ដើម្បីបាននូវអត្តាបរិសុទ្ធ កាលបើអត្តាបរិសុទ្ធ គេរមែងបានទៅនៅជាមួយព្រះជាម្ចាស់របស់គេ ឬព្រះព្រហ្មរបស់គេ គេចូលចិត្តថាមានបរមាត្ម័ន គឺព្រលឹងធំមួយដ៏ក្រៃលែង សម្រាប់អត្តាបរិសុទ្ធរបស់គេចូលទៅជ្រកនៅជាមួយ លែងវិលត្រឡប់មកកើតស្លាប់ជាបន្តទៀតហើយ ទាំងអស់នេះជាការយល់ឃើញមិនពិត ជាតួទិដ្ឋិមួយដែលយល់ខុស ព្រោះការប្រកាន់បញ្ចក្ខន្ធ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

តាមច្បាប់ហេតុនិងផល បានដល់ កម្មខ្មៅឱ្យផលខ្មៅ កម្មសឱ្យផលស ដូច្នេះបើគេមានបំណងចូលទៅកាន់កំណើតព្រហ្ម គេត្រូវចំរើនព្រហ្មវិហារ៤ ឬកម្មដ្ឋានដទៃទៀត រហូតទាល់តែបានសម្រេចនូវហេតុ ដែលអាចឱ្យបដិសន្ធិក្នុងព្រហ្មលោកបាន ទោះបីបានចូលដល់កំណើតជាព្រហ្មក៏ដោយ ក៏នៅជាខន្ធ ជាសង្ខារ ធម្មតាការមិនទៀងតែងតែមានក្នុងសង្ខារធម៌ជានិច្ច ។

ទិសដៅនៃការប្រព្រឹត្តតបធម៌ក្នុងព្រះពុទ្ធសាសនា មិនមែនជាកំណើតអ្វីណាមួយឡើយ ព្រោះបានកំណត់ដឹងនូវសង្ខារធម៌ទាំងពួង ឃើញថាជាទុក្ខហើយ ក៏រលត់នូវឆន្ទរាគៈ រលត់អវិជ្ជា រលត់សេចក្តីប្រកាន់ក្នុងសង្ខារធម៌ទាំងពួងនោះ នេះជាទីបំផុតទុក្ខ មានសេចក្តីស្ងប់ដ៏ក្រៃលែងជាលក្ខណៈ ។

៣-លក្ខណៈរបស់អ្នកបួស អ្នកបួសគឺជាអ្នកស្វែងរកសន្តិភាពឱ្យខ្លួនឯង ទុកដាក់ខ្លួនជាមនុស្សធម្មតាម្នាក់ មិនតម្កើងខ្លួនឯងដោយសារបានបួស មិនជំពាក់ទាក់ចិត្តនៅត្រង់ការគោរពបូជា ថ្វាយបង្គំរបស់អ្នកដទៃ អាស្រ័យខ្លួនជាអ្នកបួសនោះទេ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា អ្នកបួសដែលបៀតបៀនបុគ្គលដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

ដំណើរជីវិតរបស់អ្នកបួស គឺដើរក្នុងផ្លូវដ៏ស្ងប់ស្ងាត់ ស្ងាត់ជ្រងំ មានមេត្តា មានការមិនបៀតបៀន មានការមិនអាល័យជារុក្ខជាតិអមសងខាងផ្លូវ មានសេចក្តីព្យាយាមជាជើងដើរទៅ មានការឃើញត្រូវនិងការត្រិះរិះត្រូវជាចក្ខុទាំងគូ មានបណ្តាំរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូជាអ្នកនាំផ្លូវ ទ្រោលនូវប្រទីបបំភ្លឺក្នុងទីងងឹត សន្តិបូរីជាដែនដីស្អាត មានក្លិនក្រអូប ប្រាសចាកក្លិនឆ្អាប សម្បូណ៌ឥតខ្វះនូវរបស់ជាភោគផល អ្នកបានទៅដល់មានតែសេចក្តីក្សេមប៉ុណ្ណោះ ភ័យស្រណោះ អាឡោះអាល័យបន្តិចបន្តួចពុំមានសោះឡើយ កន្លែងនេះជាទិសដៅ ជាទីបំផុតនៃផ្លូវ ដែលអ្នកបួសខំដើរទៅ ទើបបានដល់ ។

ឈ្មោះថាបព្វជិត គឺជាអ្នកវៀរចាកបាបទាំងពួង ឈ្មោះថាសមណៈ គឺជាអ្នកស្ងប់រម្ងាប់ ដូច្នេះវត្ថុបំណងរបស់អ្នកបួស គឺវៀរចាកបាបទាំងពួង និងគឺសេចក្តីស្ងប់រម្ងាប់ ។ អ្នកបួសជាអ្នកស្វែងរកសន្តិភាពឱ្យជីវិតរបស់ខ្លួន និង សង្គមសត្វលោក ជាអ្នកធ្វើសង្គ្រាមជាមួយសត្រូវគឺកិលេសក្នុងចិត្តរបស់ខ្លួន ជាអ្នកយកឈ្នះខ្លួនឯងដែលធ្លាប់ជាចោរ ឱ្យមកជាអ្នកបួសពិតប្រាកដម្នាក់ ជា

Document Produced by deskPDF Unregistered :: http://www.docudesk.com

សមណៈស្ថិតនៅក្នុងមគ្គដ៏ប្រសើរ មានខន្តីជាទង់ជ័យ ។

**អំពីការងារចេញចាកគ្រោះថ្នាក់** ការងាររំដោះគ្រោះជាការងារដែលមនុស្សគ្រប់គ្នាកំពុងតែធ្វើ ទោះជាធ្វើអ្វីក៏ដោយឱ្យតែនៅក្នុងរឿងរក្សាជីវិត ការពារទប់ស្កាត់កុំឱ្យជីវិតមានសេចក្ដីលំបាក តាំងតែអំពីការសុំទាន ការខំប្រឹងលីសែងក្នុងភាពខ្លួនឯងជាទាសកម្មករ ការស្លៀកពាក់ហូបចុករាល់ថ្ងៃឡើងទៅ ។

គ្រប់ជីវិតខំប្រឹងគេចចេញអំពីគ្រោះថ្នាក់ ព្រោះជីវិតកំពុងតែមានគ្រោះថ្នាក់ ក្នុងបណ្ដាគ្រោះថ្នាក់ម៉ឺនសែនជំពូក មានគ្រោះដែលសត្វលោកលំបាកនឹងរំដោះដ៏ក្រៃលែង គឺ ឈឺ ចាស់ ព្រាត់ប្រាស និងស្លាប់ មិនត្រឹមតែប៉ុណ្ណោះ ការកើតក្នុងភពថ្មីទៀត ជាគ្រោះថ្នាក់ដ៏កាចសាហាវ ។

គ្រោះថ្នាក់ដែលកំពុងប្រឈមមុខ និងជាហេតុនៃគ្រោះថ្នាក់ទាំងអស់ទៀតផងនោះ គឺចិត្តបាប សរុបមកជីវិតទាំងមូលជាតួគ្រោះថ្នាក់ ជាតួរោគ ជាផ្សែងពុល ជាគ្រឿងស្រវឹង អ្នកដែលបៀតបៀនសត្វលោកគ្រប់គ្នា ក្រៃលែងជាងជីវិតសត្វលោកខ្លួនឯងពុំមានឡើយ ព្រោះជីវិតនេះបាននាំមកនូវធាតុ៤ ដូចជាពស់មានពិសដ៏ពន្លឹក សម្រាប់ឱ្យសត្វលោកថែរក្សា នាំមកនូវឧបាទានក្ខន្ធ៥ ដូចជាខ្មាំងសត្រូវ សម្រាប់ចាំប្រហារ នាំមកនូវរាគៈ ដូចជាបាបមិត្របួសត្រូវទី៦ សម្រាប់បោកបញ្ឆោតលួងលោមសត្វលោកឱ្យវង្វេងស្រឡាញ់នូវធាតុ៤ ពេញចិត្តនឹងឧបាទានក្ខន្ធ៥ មិនឱ្យនឿយណាយក្នុងជីវិតដ៏លំបាកលំបិន និងជាគ្រោះថ្នាក់បំផុតនេះ ។

**នេក្ខម្មៈ** ការងារនេះគេច្រើនចាត់ទុកថា ជាការមិនសមគួរចំពោះជីវិតបច្ចុប្បន្ននេះ ជារឿងដែលគេមិនសូវយកចិត្តទុកដាក់សម្រាប់រំដោះគ្រោះថ្នាក់ឱ្យខ្លួនឯងឡើយ គេគិតថាខ្ពស់ហួសពេកខ្លួនគេមិនអាចប្រព្រឹត្តទៅបាន ព្រោះវាជាការងារដែលត្រូវចោលបុត្រភរិយា ចោលការងារដែលត្រូវធ្វើតាមចិត្តចង់ និង ចោលនូវអ្វីៗទៀតជាច្រើន ដែលគេមិនអាចចោលទៅបាននោះ មានបុគ្គលខ្លះ ថែមទាំងមើលងាយនូវការងារក្នុងនេក្ខម្មៈនេះទៀតផង ជាការដែលគួរឱ្យស្ដាយណាស់នោះ គឺអ្នកដែលបានឈ្មោះថាជាភិក្ខុជាសាមណេរ ជាសមណៈ ជាសមណសក្យបុត្រទៅហើយ តែការងារជានេក្ខម្មៈពិតប្រាកដនោះមិនមាន ។

**នេក្ខម្មៈ** គឺគុណជាតជាគ្រឿងចេញ បានដល់ការចេញអំពីគ្រោះថ្នាក់ក្នុងជីវិត ដូចបានពោលរួចហើយថា ចិត្តបាបជាកំពូលគ្រោះថ្នាក់ ជាគ្រោះកាចដ៏អាក្រក់ ដូច្នេះ នេក្ខម្មៈគឺជាការរំដោះ

គ្រោះកាចដ៏មានប្រសិទ្ធភាព ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ព្រះគាថាធម្មបទ ប្រារព្ធចំពោះសន្តតិមហាមាត្យថា ទោះបីបុគ្គលប្រដាប់នូវសំពត់ និង អាភរណៈ ប៉ុន្តែជាអ្នកមានធម៌៥ ប្រការគឺ :

១- ស្ងប់រម្ងាប់

២- ទូន្មាន

៣- សភាពទៀងទាត់

៤- ប្រព្រឹត្តិប្រសើរ

៥- ដាក់ចុះនូវអាជ្ញាចំពោះសព្វសត្វទាំងពួង ព្រះអង្គទ្រង់ត្រាស់ហៅថា ព្រាហ្មណ៍ ហៅថា សមណៈ ហៅថា ភិក្ខុ ។

**សន្តោ** អ្នកស្ងប់រម្ងាប់ ព្រោះចេញអំពីកិលេសជាគ្រឿងមិនស្ងប់ **ទន្តោ** អ្នកហ្វឹកហាត់អប់រំទូន្មាននូវឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើម និងមានមនិន្ទ្រិយជាទីបំផុត គឺជាអ្នកចេញអំពីកិលេសជាគ្រឿងស្រវឹង **និយតោ** បុគ្គលមានសភាពទៀងទាត់ គឺមានសភាពត្រូវនិងទៀង ព្រោះសម្រេចនូវមគ្គទាំង៤ ជាអ្នកចេញចាកទុក្ខ ព្រោះរំលត់តណ្ហាឥតមានសល់ **ព្រហ្មចារី** អ្នកប្រព្រឹត្តប្រសើរ ព្រោះចេញផុតអំពីការប្រព្រឹត្តសៅហ្មង ស្មោកគ្រោក **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ជាអ្នកដាក់ចុះនូវអាជ្ញាចំពោះ សព្វសត្វទាំងពួង ព្រោះបានចេញផុតអំពី កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត **សោ ព្រាហ្មណោ** បុគ្គលនោះជាព្រាហ្មណ៍ គឺជាអ្នកមានបាបបានបន្សាត់ចោលហើយ **សោ សមណោ** បុគ្គលនោះជាសមណៈ គឺជាអ្នកមានបាបបានរម្ងាប់ហើយ **ស ភិក្ខុ** បុគ្គលនោះឈ្មោះថាភិក្ខុ គឺជាអ្នក ជីកទម្លាយនូវកិលេស ឱ្យហូរចេញអស់អំពីសន្តាន ដោយចប គឺអរិយមគ្គ ។

ចំពោះការងារចេញចាកគ្រោះថ្នាក់ ដែលបានរៀបរាប់មកទាំងប៉ុន្មាននេះ រមែងមានចំពោះជនណាដែលពិចារណាឃើញគ្រោះថ្នាក់ពិតប្រាកដក្នុងជីវិតគឺចិត្តបាប ចិត្តទទឹកដោយកិលេសមានរាគៈជាដើម ដូច្នេះគ្រប់គ្នាឱ្យតែមាននូវសតិសម្បជញ្ញៈ អាចចាប់ផ្តើមនូវនេក្ខម្មៈ គឺជាការរៀបចំផ្លូវដើរចេញអំពីគ្រោះថ្នាក់ ប្រៀបដូចប្រទេសមានសង្គ្រាម អ្នកស្រុកគ្រប់គ្នាប្រឹងជីកដីធ្វើលេណដ្ឋាន ដើម្បីគេចអំពីគ្រាប់រំសេវ ដូច្នោះឯង ។

ការចំរើនសតិប្បដ្ឋាន៤ គឺជាការប្រព្រឹត្តនូវនេក្ខម្មៈដ៏ប្រសើរបំផុត ព្រោះក្នុងនោះមាននេក្ខម្មសង្កប្បៈ ទល់គ្នានឹង



Document Produced by deskPDF Unregistered :: http://www.docudesk.com

អារម្មណ៍ដែលសតិកំពុងរលឹក តាមពិតវិតក្កៈក្នុងខណៈមានសតិផ្ទាក់សតិប្បដ្ឋាន មិនត្រឹមតែជានេក្ខម្មសង្កប្បៈប៉ុណ្ណោះទេ គឺជាអព្យាបាទសង្កប្បៈផង និងអវិហិង្សាសង្កប្បៈផង វិតក្កៈនេះជាការចេញចាកកាម ចេញចាកការព្យាបាទ និង ការបៀតបៀនផ្សេងៗ គឺជាវិតក្កៈដែលប្រកបជាមួយសម្មាទិដ្ឋិ ឃើញច្បាស់នូវលោកដែលកំពុងប្រាកដ កំចាត់បង់នូវអវិជ្ជាដែលជាភាពងងឹត តែងបិទបាំងនូវលោក ធ្វើឱ្យលោកភ្លឺស្វាងដោយរស្មីនៃបញ្ញា ។

លោកភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្ដាត លោកកាយ និងលោកចិត្ត សុទ្ធតែជាលោកដែលមានគ្រោះថ្នាក់គ្រប់ពេលវេលា ប្រៀបបីដូចជាស្រុកស្ងាត់ ប៉ុន្តែជាភូមិចោរ ពួកចោររមែងបៀតបៀនដល់អ្នកដែលនៅក្នុងទីនោះ សេចក្ដីនេះគឺថា លោក៦ជាស្រុកស្ងាត់ ព្រោះស្ងាត់ចាកសត្វបុគ្គល មានត្រឹមតែរូបធម៌ និងនាមធម៌ប៉ុណ្ណោះ ដែលថាជាភូមិចោរ ព្រោះជាទីមកនៃអារម្មណ៍ទៅតាមទ្វារនោះៗ មានចក្ខុទ្វារជាដើម ដែលថាជាការបៀតបៀន ព្រោះអារម្មណ៍នោះជាបច្ច័យនៃអភិជ្ឈាឬទោមនស្ស ដូច្នេះសតិប្បដ្ឋាន៤ គឺជាតួនេក្ខម្មៈដ៏ប្រសើរ ជាដំណើរចេញអំពីភូមិចោរគឺលោក៦ ឆ្លងស្ទឹងតណ្ហាដល់នូវព្រះនិព្វានជាបរមសុខសាន្ត ។

ទោះជាយ៉ាងណាក៏ដោយ ឱ្យតែបុគ្គលណាម្នាក់បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹក ហើយមានការតាំងចិត្តវៀរចាកអំពើអាក្រក់ទាំងពួង បុគ្គលនោះគឺជាអ្នកបួសម្នាក់ដែលគួរដល់ការគោរពនិងបូជា ទោះបីបុគ្គលនោះកំសត់ក្រីក្រលំបាកតោកយ៉ាកខ្វះមុខខ្វះក្រោយ ធ្វើការចិញ្ចឹមជីវិតដោយខ្លួនឯងយ៉ាងណាក៏ដោយ ក៏គួរឱ្យជ្រះថ្លា គួរឱ្យរាប់អាន គួរដល់ការគោរពណាស់ ព្រោះគេនោះមិនបានធ្វើចោរ បរិភោគអាហារមិនមានបំណុល ។

ជាទីបញ្ចប់នៃកម្រងអត្ថបទ ដែលមានឈ្មោះថា **មនុស្សជាមួយនឹងការងារ**នេះ សូមពុទ្ធបរិស័ទធ្វើនូវការងារមួយទៀត គឺការសិក្សាព្រះពុទ្ធភាសិតផ្សេងៗជាបន្តនៅទំព័របន្ទាប់ ។

✧α✧α✧α✧α✧
✧α✧α✧α✧
✧α✧α✧
✧α✧
✧



Document Produced by deskPDF Unregistered :: http://www.docudesk.com

## ធម្មបទ  អត្តវគ្គ

អត្តា ហិ អត្តនោ នាថោ    កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន    នាថំ លភតិ ទុល្លភំ ។

ខ្លួនជាទីពឹងរបស់ខ្លួន  អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ  រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

អត្តនា វ កតំ បាបំ    អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ    អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ    នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និង មិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានឡើយ ។



## ធម្មបទ  សុខវគ្គ

ជយំ វេរំ បសវតិ    ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ    ហិត្វា ជយបរាជយំ ។

បុគ្គលអ្នកឈ្នះតែងប្រទះនូវពៀរ  បុគ្គលអ្នកចាញ់តែងដេកជាទុក្ខ  ចំណែកបុគ្គលលះបង់នូវការឈ្នះនិងការចាញ់ចេញហើយជាអ្នកស្ងប់រម្ងាប់ រមែងដេកជាសុខ ។

នត្ថិ រាគសមោ អគ្គិ    នត្ថិ ទោសសមោ កលិ
នត្ថិ ខន្ធសមា ទុក្ខា    នត្ថិ សន្តិបរំ សុខំ ។

ភ្លើងស្មើដោយរាគៈ មិនមាន កំហុសស្មើដោយទោសៈមិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅអំពីសេចក្តីស្ងប់ មិនមានឡើយ ។

បវិវេករសំ បិត្វា    រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ    ធម្មបីតិរសំ បិវំ ។

បុគ្គលបានក្រេបផឹកនូវរសនៃវិវេកផង  រសនៃព្រះនិព្វានជាទីរម្ងាប់នូវកិលេសផង  បានក្រេបផឹកនូវរសនៃធម្មបីតិផង រមែងជាអ្នកគ្មានសេចក្តីក្រវល់ក្រវាយ គ្មានសេចក្តីសៅហ្មងឡើយ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ធម្មបទ មគ្គវគ្គ

តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុគឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកស្រវឹងជ្រប់ ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមាន ដើម្បីជាទីពឹងឡើយ គឺទីពឹងរមែងមិនមានក្នុងពពួកញាតិទាំងឡាយ បណ្ឌិតដឹងអំណាចនៃប្រយោជន៏នេះហើយ គួរជាអ្នកសង្រួម ក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឱ្យបានស្អាត ។



## ធម្មបទ នាគវគ្គ

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនចាកភក់គឺកិលេស ដែលគេឆ្លងបានដោយកម្រ ដូចដំរីជាប់ភក់ រើខ្លួនរួចបាន ។

**អត្ថម្ហិ ជាតម្ហិ សុខា សហាយា**

កាលបើសេចក្តីត្រូវការកើតឡើងហើយ សម្លាញ់ទាំងឡាយ
នាំសេចក្តីសុខមកឱ្យ ។

**តុដ្ឋី សុខា យា ឥតរីតរេន**

សេចក្តីសន្តោសចំពោះបច្ច័យ ជាហេតុនាំសេចក្តីសុខមកឱ្យ ។

**បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ**

បុណ្យនាំសេចក្តីសុខមកឱ្យ ក្នុងកាលទៀបនឹងអស់ជីវិត ។

**សព្វស្ស ទុក្ខស្ស សុខំ បហានំ**

ការលះបង់នូវទុក្ខទាំងអស់បាន គឺជាសុខ ។

**សុខា មត្តេយ្យតា លោកេ**

សេចក្តីប្រតិបត្តិល្អក្នុងមាតា នាំសេចក្តីសុខមកឱ្យក្នុងលោក

**អថោ បេត្តេយ្យតា សុខា**

ម្យ៉ាងទៀត សេចក្តីប្រតិបត្តិល្អក្នុងបិតា ក៏នាំសេចក្តីសុខមកឱ្យ ។

**សុខា សាមញ្ញតា លោកេ**

សេចក្តីប្រតិបត្តិល្អក្នុងសមណៈ នាំសេចក្តីសុខមកឱ្យក្នុងលោក

**អថោ ព្រហ្មញ្ញតា សុខា**

ម្យ៉ាងទៀត សេចក្តីប្រតិបត្តិល្អក្នុងព្រាហ្មណ៍ ក៏នាំសេចក្តី
សុខមកឱ្យ ។

**សុខំ យាវ ជរា សីលំ**

សីលនាំសេចក្តីសុខមកឱ្យ ដរាបដល់ចាស់ជរា ។

**សុខា សទ្ធា បតិដ្ឋិតា**

សទ្ធាដែលតម្កល់ខ្ជាប់ខ្ជួនហើយ នាំសេចក្តីសុខមកឱ្យ ។

**សុខោ បញ្ញាបដិលាភោ**

ការសម្រេចបាននូវបញ្ញា នាំសេចក្តីសុខមកឱ្យ ។

**បាបានំ អករណំ សុខំ**

ការមិនធ្វើនូវបាបទាំងពួង នាំសេចក្តីសុខមកឱ្យ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពុទ្ធភាសិតគោលៗក្នុងវគ្គផ្សេងៗ

α **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ ។

α **ចិត្តំ ទន្តំ សុខាវហំ** ចិត្តដែលបុគ្គលទូន្មានហើយ តែងនាំមកនូវសេចក្តីសុខ ។

α **ធម្មបីតិ សុខំ សេតិ** អ្នកមានបីតិក្នុងធម៌ តែងដេកជាសុខ ។

α **សុខោ ពុទ្ធានមុប្បាទោ** ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ ។

α **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ការអស់ទៅនៃ តណ្ហាឈ្នះអស់នូវសេចក្តីទុក្ខទាំងពួង ។

α **និព្វានំ បរមំ សុខំ** ព្រះនិព្វានជាសុខដ៏យ៉ាងក្រៃលែង ។

α **សុខា សទ្ធម្មទេសនា** ការសំដែងនូវធម៌របស់សប្បុរស រមែងនាំមកនូវសេចក្តីសុខ ។

α **សុខាសង្ឃស្ស សាមគ្គី** សេចក្តីព្រមព្រៀងគ្នានៃសង្ឃ រមែងនាំមកនូវសេចក្តីសុខ ។

α **កោធំ ឃត្វា សុខំ សេតិ** សម្លាប់សេចក្តីក្រោធបាន ទើបដេកជាសុខ ។

α **កោធំ ឃត្វា ន សោចតិ** សម្លាប់សេចក្តីក្រោធបាន ទើបមិនសោយសោក ។

α **ធម្មោ សុចិណ្ណោ សុខមាវហាតិ** ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្តីសុខ។

α **ឧបសន្តោ សុខំ សេតិ** អ្នកមានសេចក្តីស្ងប់រម្ងាប់ រមែងដេកជាសុខ ។

α **អកិច្ចានំ នានុបតន្តិ ទុក្ខា** ទុក្ខទាំងឡាយ រមែងមិនធ្លាក់តាមបុគ្គលដែលឥតកង្វល់ ។

α **ឯតំ ភយំ មរណេ បេក្ខមានោ លោកាមិសំ បជ្ជហេ សន្តិបេក្ខោ** កាលបុគ្គលពិចារណាឃើញភ័យក្នុងសេចក្តីស្លាប់នៃជីវិតនេះ គប្បីសម្លឹងនូវសន្តិបទគឺព្រះនិព្វាន ហើយលះបង់នូវនុយគឺគ្រឿងជាប់ជំពាក់ក្នុងលោកចោលឱ្យផុតស្រឡះ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

α **សតិមា សុខមេធតិ** អ្នកមានសតិ តែងចំរើនដោយសេចក្តីសុខ ។

## ឧទាន មុចលិន្ទសូត្រ

α **សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ** សេចក្តីស្ងប់ស្ងាត់របស់អ្នកដែលត្រេកអរក្នុងទីស្ងាត់ ជាអ្នកមានធមិបានស្តាប់ហើយ ពិចារណាឃើញនូវធមិ នាំមកនូវសេចក្តីសុខ ។

α **អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ** កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

α **សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ** កិរិយាប្រាសចាកតម្រេក គឺ កិរិយាប្រព្រឹត្តកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

α **អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ** កិរិយា កំចាត់បង់នូវអស្មិមានៈ ដំណើរទុំះ គឺជាសុខដ៏ក្រៃលែង ។



## ឧទាន រាជសូត្រ

α **យញ្ច កាមសុខំ លោកេ យញ្ចិទំ ទិវិយំ សុខំ**
**តណ្ហក្ខយសុខស្ស តេ កលំ នគ្ឃន្តិ សោឡសិន្តិ**

កាមសុខណាក្នុងលោកក្តី ទិព្វសុខណាក្តី សេចក្តីសុខទាំងនោះ មិនដល់នូវចំណិត១ ក្នុងចំណែក១៦ នៃសេចក្តីសុខព្រោះការអស់ទៅនៃតណ្ហា ។

## ឧទាន ទណ្ឌសូត្រ

α **សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ**
**សុខំ។**
**សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខន្តិ**
**។**

បុគ្គលណា កាលស្វែងរកសេចក្តីសុខដើម្បីខ្លួន ហើយបៀតបៀនពួកសត្វអ្នកប្រាថ្នានូវសេចក្តីសុខ ដោយអាជ្ញា បុគ្គលនោះលុះលះលោកនេះទៅ រមែងមិនបាននូវសេចក្តីសុខឡើយ ។ បុគ្គល

Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ណា កាលស្វែងរកសេចក្ដីសុខដើម្បីខ្លួន ហើយមិនបៀតបៀនពួកសត្វអ្នកប្រាថ្នានូវសេចក្ដីសុខ ដោយអាជ្ញា បុគ្គលនោះ លុះលះលោកនេះទៅ រមែងបាននូវសេចក្ដីសុខ ។

## ឧទាន វិសាខាសូត្រ

α យេកេចិ សោកា បរិទេវិតា វា
ទុក្ខា ច លោកស្មិំ អនេករូបា
បិយំ បដិច្ច ភវន្តិ ឯតេ
បិយេ អសន្តេ ន ភវន្តិ ឯតេ ។
តស្មា ហិ តេ សុខិនោ វីតសោកា
យេសំ បិយំ នត្ថិ កុហិញ្ចិ លោកេ
តស្មា អសោកំ វិរជំ បត្ថយានោ
បិយំ ន កយិរាថ កុហិញ្ចិ លោកេតិ ។

សេចក្ដីសោកក្ដី សេចក្ដីខ្សឹកខ្សួលក្ដី ឯណានីមួយ ឬសេចក្ដីទុក្ខជាច្រើនយ៉ាង ក្នុងលោក ធម៌ទាំងនោះរមែងកើតឡើង ព្រោះអាស្រ័យសត្វ និងសង្ខារជាទីស្រឡាញ់ កាលបើមិនមានសត្វ និងសង្ខារជាទីស្រឡាញ់ហើយ ធម៌ទាំងនោះក៏រមែងមិនមានឡើយ ។ ព្រោះហេតុនោះឯង បុគ្គលណា មិនមានសត្វ និងសង្ខារជាទីស្រឡាញ់ ក្នុងលោកឯណានីមួយទេ បុគ្គលនោះ ទើបមាននូវសេចក្ដីសុខ ប្រាសចាកសេចក្ដីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្ដីមិនសោក និង ការប្រាសចាកធូលីគឺកិលេស មិនគប្បីធ្វើសត្វ និងសង្ខារឱ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។

## សំយុត្តនិកាយ សគាថវគ្គ

α សទ្ធិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតីតិ ។

បុគ្គលគួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសតែប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស បុគ្គលដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរួចផុតចាកទុក្ខទាំងពួង ។

≈≈≈≈≈

## អានិសង្សនៃបុគ្គលមិនប្រមាទ

α បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ បរមំ សុខន្តិ។

ពួកជនពាលល្ងង់ខ្លៅ មិនមាននូវប្រាជ្ញា តែងប្រកបរឿយៗដោយសេចក្តីប្រមាទ គឺការធ្វេសប្រហែស អ្នកប្រាជ្ញរមែងរក្សានូវសេចក្តីមិនប្រមាទ គឺការមិនធ្វេសប្រហែស ដូចជាគេរក្សាទុកនូវទ្រព្យដ៏ប្រសើរថ្លៃថ្លា អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗដោយសេចក្តីប្រមាទ គឺការធ្វេសប្រហែសនេះឡើយ កុំគប្បីធ្វើសេចក្តីស្និទ្ធស្នាល ត្រេកត្រអាលក្នុងកាមទាំងឡាយឡើយ ព្រោះថា បុគ្គលអ្នកមិនមាននូវសេចក្តីប្រមាទ មានការសម្លឹងពិនិត្យរមែងបានដល់នូវសេចក្តីសុខដ៏ឧត្តម ។

## អន្នទសូត្រ

α **អន្នទោ ពលទោ ហោតិ** អ្នកឱ្យបាយ ឈ្មោះថាឱ្យកម្លាំង ។

α **វត្ថទោ ហោតិ វណ្ណទោ** អ្នកឱ្យសំពត់ ឈ្មោះថាឱ្យពណ៌សម្បុរ ។

α **យានទោ សុខទោ ហោតិ** អ្នកឱ្យយានជំនិះ ឈ្មោះថាឱ្យសេចក្តីសុខ ។

α **ទីបទោ ហោតិ ចក្ខុទោ** អ្នកឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុ ។

α **សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ**
**អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតីតិ**

ម្យ៉ាងទៀត បុគ្គលណា ឱ្យទីនៅអាស្រ័យ បុគ្គលនោះឈ្មោះថាឱ្យនូវវត្ថុគ្រប់យ៉ាង ចំណែកបុគ្គលណា ជាអ្នកប្រៀនប្រដៅនូវព្រះធម៌ បុគ្គលនោះ ឈ្មោះថាឱ្យនូវព្រះនិព្វាន ។

## ធម្មទានប្រសើរឧត្តម

≈≈≈≈≈

α **សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទានឈ្នះអស់លើទានទាំងពួង ។

α **សព្វរសំ ធម្មរសោ ជិនាតិ** ធម្មរសឈ្នះអស់លើរសទាំងពួង ។

α **សព្វរតឹ ធម្មរតិ ជិនាតិ** វីករាយក្នុងធម៌ ឈ្នះអស់តម្រេកទាំងពួង ។

α **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ការក្ស័យតណ្ហា ជាការឈ្នះលើកងទុក្ខទាំងពួង ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ក្នុងមហាបរិនិព្វានសូត្រ

៙ ទហរាបិ ច យេ វុឌ្ឍា
យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច
សព្វេ មច្ចុបរាយនា ។

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។

៙ យថាបិ កុម្ភការស្ស
កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច
យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទបរិយន្តំ
ឯវំ មច្ចាន ជីវិតំ ។

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។



## អថាបរំ ឯតទវោច សត្ថា

ព្រះសាស្តាទ្រង់មានព្រះបន្ទូល ដូច្នេះតទៅទៀតថា :

៙ បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ

វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់នូវអ្នកទាំងឡាយ ហើយទៅឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

៙ អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។
យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំគប្បីមានសេចក្តីប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យបានរឿយៗ ។ ភិក្ខុណា មិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ដែលជាទីបំផុតនៃទុក្ខ បានពុំខានឡើយ ។

~៙~៙~៙~៙~៙~

## មហាបរិនិព្វានសូត្រ

## ព្រះរព្ធបិណ្ឌបាតរបស់ចុន្ទកម្មារបុត្ត

α ទទតោ បុញ្ញំ បវឌ្ឍតិ
សំយមតោ វេរំ ន វីយតិ
កុសលោ វ ជហាតិ បាបកំ
រាគទោសមោហក្ខយា និព្វុតោតិ ។

បុណ្យរមែងចម្រើនដល់អ្នកឱ្យទាន ពៀរវេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស រមែងលះបង់នូវអំពើបាបបាន បុគ្គលនោះបរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

=====

## បណ្ដាំព្រះបរមសាស្ដា

α យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។ ម្នាលអានន្ទ ធមិណាក្ដី វិន័យណាក្ដី ដែលតថាគតសម្ដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធមិនិងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ។



## បច្ឆិមវាចារបស់ព្រះតថាគត

α ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។ អយំ តថាគតស្ស បច្ឆិមាវាចា ។ ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចា របស់ព្រះតថាគត ។

## សំយុត្តនិកាយ សគាថវគ្គ

## ពុទ្ធោវាទចំពោះមានត្ថទ្ធព្រាហ្មណ៍

α ន មានំ ព្រាហ្មណ សាធុ
អត្ថិ កស្សីធ ព្រាហ្មណ
យេន អត្ថេន អាគញ្ឆិ
តមេវមនុព្រូហយេតិ ។

ម្នាលព្រាហ្មណ៏ បុគ្គលណាក្នុងលោកនេះមាននូវមានៈមិនល្អឡើយ បុគ្គលមកហើយដោយប្រយោជន៏ណា គប្បីជាអ្នកចម្រើននូវប្រយោជន៏នោះឯងចុះ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ពុទ្ធោវាទចំពោះបច្ចនិកសាតព្រាហ្មណ៍

≈≈≈≈≈

១ ន បច្ចនិកសាតេន សុវិជានំ សុភាសិតំ
ឧបក្កិលិដ្ឋចិត្តេន សារម្ភពហុតេន ច
យោ ច វិនេយ្យ សារម្ភំ អប្បសាទញ្ច ចេតសា
អាឃាតំ បដិនិស្សជ្ជ សចេ ជញ្ញា សុភាសិតន្តិ។

បុគ្គលដែលត្រេកអរដើម្បីធ្វើជាសត្រូវ មានចិត្តសៅហ្មងច្រើនដោយការប្រណាំងប្រជែង មិនងាយនឹងបានដឹងនូវសុភាសិតឡើយ លុះត្រាតែបុគ្គលណា កម្ចាត់បង់នូវការប្រណាំងប្រជែង និងសេចក្តីមិនជ្រះថ្លានៃចិត្តផង លះចោលនូវគំនុំគុំគួនផង បុគ្គលនោះ ទើបដឹងនូវពាក្យជាសុភាសិតទៅបាន ។

## ពុទ្ធោវាទចំពោះអសុរិន្ទកព្រាហ្មណ៍

១ ជយំ វេ មញ្ញតិ ពាលោ
វាចាយ ផរុសំ ភណំ
ជយញ្ចេវស្ស តំ ហោតិ
យា តីតិក្ខា វិជានតោ ។

បុគ្គលពាលពោលនូវពាក្យទ្រគោះដេរប្រទេចអ្នកដទៃ មានសេចក្តីសំគាល់ថាបាននូវជ័យជំនះ តែថាសេចក្តីអត់ធន់ ជាជ័យជំនះរបស់បណ្ឌិតអ្នកបានដឹងច្បាស់ ។

១ តស្សេវ តេន បាបិយោ
យោ កុទ្ធំ បដិកុជ្ឈតិ
កុទ្ធំ អប្បដិកុជ្ឈន្តោ
សង្គាមំ ជេតិ ទុជ្ជយំ ។

បុគ្គលណា ក្រោធតបនឹងបុគ្គលអ្នកក្រោធហើយ បុគ្គលនោះឯង រមែងអាក្រក់ជាងអ្នកដែលក្រោធហើយនោះទៅទៀត ព្រោះហេតុតែការក្រោធតបនោះឯង បុគ្គលដែលមិនក្រោធតបនឹងបុគ្គលអ្នកក្រោធហើយ ឈ្មោះថា ឈ្នះនូវសង្គ្រាម ដែលគេឈ្នះបានដោយកម្រ ។

១ ឧភិន្នមត្ថំ ចរតិ
អត្តនោ ច បរស្ស ច
បរំ សង្កុបិតំ ញត្វា
យោ សតោ ឧបសម្មតិ ។

បុគ្គលណាដឹងថា អ្នកដទៃមានសេចក្ដីក្រោធហើយ ក៏មានស្មារតីនៅដោយសេចក្ដីស្ងប់រម្ងាប់ អ្នកនោះឈ្មោះថា ប្រព្រឹត្តនូវប្រយោជន៍ដល់ជនទាំងពីរនាក់ គឺដល់ខ្លួនឯងនិងដល់អ្នកដទៃ ។

១ ឧភិន្នំ តិកិច្ឆន្តានំ
អត្តនោ ច បរស្ស ច
ជនា មញ្ញន្តិ ពាលោតិ
យេ ធម្មស្ស អកោវិទាតិ ។

កាលដែលបុគ្គលរក្សានូវប្រយោជន៍ ឱ្យដល់ជនទាំងពីរចំណែក គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ ជនទាំងឡាយដែលមិនឆ្លាតនៅក្នុងធម៌ រមែងសំគាល់នូវអ្នកដែលអត់ធន់បាននោះ ថាជាមនុស្សពាលទៅវិញ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

## ពុទ្ធភាសិតចំពោះកសិភារទ្វាជព្រាហ្មណ៍

≈≈≈≈≈

១ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគ គង់នៅក្នុងព្រាហ្មណគ្រាម ឈ្មោះឯកនាលា ក្នុងទក្ខិណាគិរិជនបទ នាដែនមគធៈ ។

សម័យនោះ កសិភារទ្វាជព្រាហ្មណ៍ បានតាក់តែងនង្គ័លប្រមាណ ៥០០ ក្នុងវេលាដែលព្រោះស្រូវ ។

លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយព្រះអង្គទ្រង់យាងចូលទៅកាន់កន្លែងធ្វើការរបស់កសិភារទ្វាជព្រាហ្មណ៍ ។ សម័យនោះ ការលៀងភ្ញៀវរបស់កសិភារទ្វាជព្រាហ្មណ៍ កំពុងប្រព្រឹត្តទៅ ព្រះដ៏មានព្រះភាគក្នុងពេលនោះ ទ្រង់ក៏បានចូលទៅដល់កន្លែងលៀងអាហាររបស់ព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏ប្រថាប់ឈរក្នុងទីដ៏សមគួរ ។

កសិភារទ្វាជព្រាហ្មណ៍ បានឃើញព្រះដ៏មានព្រះភាគ ដែលទ្រង់ប្រថាប់ឈរបិណ្ឌបាត លុះឃើញហើយ ក៏បានពោលនូវពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គ

ភ្ជួរផង ព្រោះផង លុះខ្ញុំព្រះអង្គភ្ជួរហើយ ព្រោះហើយ ទើបបរិភោគ បពិត្រព្រះសមណៈ ចំណែកព្រះអង្គ ចូរភ្ជួរផង ព្រោះផង លុះភ្ជួរហើយ ព្រោះហើយ ចូរបរិភោគចុះ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគតភ្ជួរហើយ ព្រោះហើយ ទើបតថាគតបរិភោគដែរ ។ ព្រាហ្មណ៍បានស្តាប់ហើយក៏ពោលថា យើងខ្ញុំមិនបានឃើញនឹមនង្គ័ល ផាលជន្លួញ និង គោទាំងឡាយរបស់ព្រះគោតមដ៏ចម្រើនឡើយ តែព្រះគោតមដ៏ចម្រើន ត្រាស់យ៉ាងនេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួរផង ព្រោះផង លុះតថាគតភ្ជួរហើយ ព្រោះហើយ ទើបតថាគតបរិភោគដែរ ។

លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍ បានទូលសួរចំពោះព្រះដ៏មានព្រះភាគ ដោយគាថាដែលមានសេចក្តីថា :

> ព្រះអង្គប្តេជ្ញាថាជាអ្នកធ្វើស្រែ តែថា ខ្ញុំព្រះអង្គមិនដែលឃើញនូវការភ្ជួររបស់ព្រះអង្គសោះ ខ្ញុំព្រះអង្គសូមសួរចំពោះព្រះអង្គដែលជាអ្នកស្រែ សូមព្រះអង្គទ្រង់ត្រាស់ប្រាប់មកចុះ ធ្វើដូចម្តេច ដើម្បីឱ្យយើងខ្ញុំបានដឹង នូវការធ្វើស្រែរបស់ព្រះអង្គនោះទៅបាន ?



## ព្រះពុទ្ធភាសិត

៱ សទ្ធា ពីជំ តបោ វុដ្ឋិ
បញ្ញា មេ យុគនង្គលំ
ហិរិ ឦសា មនោ យោត្តំ
សតិ មេ ផាលបាចនំ ។

សទ្ធាជាពូជ តបៈគឺការសង្រួមឥន្ទ្រិយរារាំងនូវកិលេសជាភ្លៀង បញ្ញារបស់តថាគតជានឹមនិងផ្ទៀងនង្គ័ល ហិរិគឺការខ្មាសខ្ពើមបាបជាដងនង្គ័ល ចិត្តនឹងធឹងមិនរវើរវាយគឺជាខ្សែ សតិរបស់តថាគត ជាផាល និង ជន្លួញ ។

៱ កាយគុត្តោ វចីគុត្តោ
អាហារេ ឧទរេ យតោ
សច្ចំ ករោមិ និទ្ទានំ
សោរច្ចំ មេ បមោចនំ ។

តថាគតគ្រប់គ្រងកាយ គ្រប់គ្រងវាចា សង្រួមអាហារ សង្រួមផ្ទៃ តថាគតធ្វើនូវការដកសំអាតស្មៅ (គឺវាចាឡេះឡោះ និង អត្តានុទិដ្ឋិ) ដោយសច្ចៈ (គឺវចីសច្ចៈ និង ទិដ្ឋិសច្ចៈ) ឯសេចក្តីត្រេកអរក្នុងព្រះនិព្វានរបស់តថាគត មានការរលត់កិលេសជាសេចក្តីរួចស្រេច ពោលគឺសម្រេចហើយក្នុងកិច្ចការងារ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

α      វីរិយំ  មេ  ធុរធោរយ្ហំ
យោគក្ខេមាធិវាហនំ
គច្ឆតិ  អនិវត្តន្តំ
យត្ថ  គន្ត្វា  ន  សោចតិ  ។

សេចក្ដីព្យាយាមរបស់តថាគត ដូចជាគោទាញរនង្គ័ល ព្រោះជាការនាំទៅនូវធុរៈ ឱ្យបានសម្រេចដល់ទីក្សេមចាកយោគៈ គឺព្រះនិព្វាន បុគ្គលទៅក្នុងទីណាមិនមានសេចក្ដីសោក សេចក្ដីព្យាយាមត្រូវឆ្ពោះទៅកាន់ទីនោះ ដែលមិនមានការវិលត្រឡប់មកវិញឡើយ ។

α      ឯវមេសា  កសី  កដ្ឋា
សា  ហោតិ  អមតប្ផលា
ឯតំ  កសឹ  កសិត្វាន
សព្វទុក្ខា  បមុច្ចតីតិ  ។

ស្រែន៎ុះតថាគតបានភ្ជួរយ៉ាងនេះ ស្រែន៎ុះមានព្រះនិព្វានជាផល បុគ្គលភ្ជួរស្រែន៎ុះហើយ រមែងរួចផុតចាកទុក្ខទាំងពួងបាន។

ព្រាហ្មណ៍ស្ដាប់ព្រះធម៌ទេសនា ដែលមានសេចក្ដីដ៏ជ្រាលជ្រៅហើយ ក៏បានជ្រាបថា មនុស្សដែលបានបរិភោគផលនៃការភ្ជួរស្រែរបស់យើង រមែងឃ្លាននៅក្នុងថ្ងៃស្អែកជាពិតប្រាកដណាស់ ប៉ុន្តែអ្នកដែលបរិភោគផលនៃការភ្ជួរស្រែអមតៈនេះ រមែងរួចផុតចាកទុក្ខទាំងពួង ហើយព្រាហ្មណ៍ក៏សូមដល់នូវព្រះរតនត្រ័យជាទីរលឹកស្មើដោយជីវិត រួចសូមបព្វជ្ជា ឧបសម្បទា មិនយូរប៉ុន្មានក៏បានជាព្រះអរហន្តមួយព្រះអង្គដែរ ។

ΓαΓαΓαΓαΓ
ΓαΓαΓαΓ
ΓαΓαΓ
ΓαΓ
Γ



Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពុទ្ធភាសិតចំពោះឧទយព្រាហ្មណ៍

≈≈≈≈≈

៤ សាវត្ថីនិទាន ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចយាងចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ លំដាប់នោះ ឧទយព្រាហ្មណ៍យកបាយ ដាក់ពេញក្នុងបាត្ររបស់ព្រះដ៏មានព្រះភាគ ។

ថ្ងៃទី២ ទ្រង់យាងចូលទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ទៀត ព្រាហ្មណ៍ក៏យកបាយដាក់ពេញក្នុងបាត្រដូចមុនដែរ ថ្ងៃទី៣ ព្រះអង្គទ្រង់យាងទៅដូចមុនទៀត ឧទយព្រាហ្មណ៍បានដាក់បាត្រព្រះសម្មាសម្ពុទ្ធជាគំរប់ ៣ដង ព្រាហ្មណ៍ដាក់បាយពេញក្នុងបាត្រនៃព្រះដ៏មានព្រះភាគ៣ដង មិនមែនដោយសទ្ធាឡើយ តែព្រោះខ្លាចពាក្យតិះដៀលអំពីអ្នកដទៃ ក្រែងគេស្តីថា បព្វជិតមកឈរមុខផ្ទះហើយ គ្រាន់តែបាយក៏កំណាញ់ដែរ ជាអ្នកបរិភោគតែឯងយ៉ាងនេះ ។

ក្នុងថ្ងៃទី៣ ព្រាហ្មណ៍មិនអាចទ្រាំបាន កាលគាត់ដាក់បាត្ររួចហើយ ក៏ពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា ព្រះសមណៈគោតមនេះ ជាអ្នកជាប់ជំពាក់ចិត្តក្នុងរសអាហារ ទើបនិមន្តមករឿយៗ ។

ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់យាងទៅកាន់លំនៅរបស់ឧទយព្រាហ្មណ៍ រហូតដល់ទៅ ៣ លើក ជាប់៣ថ្ងៃតគ្នា ក៏ព្រោះដើម្បីឱ្យព្រាហ្មណ៍បន្លឺនូវវាចាយ៉ាងនេះឯង ។កាលព្រះបរមសាស្ដាទ្រង់បានស្ដាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍អ្នកថ្វាយបិណ្ឌបាត្រ៣ថ្ងៃជាប់តគ្នា គឺនៅមិនទាន់ច្រើនរឿយៗប៉ុន្មានឡើយ រួចហើយព្រះអង្គទ្រង់ត្រាស់ភាសិតអំពីធម៌ច្រើនប្រការក្នុងលោក ដែលមានការប្រព្រឹត្តទៅជារឿយៗរាប់ដងមិនអស់ ដូច្នេះថា :

៤ បុនប្បុនំ ចេវ វបន្តិ ពីជំ
បុនប្បុនំ វស្សតិ ទេវរាជា
បុនប្បុនំ ខេត្តំ កសន្តិ កស្សកា
បុនប្បុនំ ធញ្ញមុបេន្តិ រដ្ឋំ
បុនប្បុនំ យាចកា យាចយន្តិ
បុនប្បុនំ ទានបតី ទទន្តិ
បុនប្បុនំ ទានបតី ទទិត្វា
បុនប្បុនំ សគ្គមុបេន្តិ ឋានំ



Document Produced by deskPDF Unregistered :: http://www.docudesk.com

បុនប្បុនំ ខីរណិកា ទុហន្តិ
បុនប្បុនំ វច្ឆោ ឧបេតិ មាតរំ
បុនប្បុនំ កិលមតិ ផន្ទតិ ច
បុនប្បុនំ គព្ភមុបេតិ មន្ទោ
បុនប្បុនំ ជាយតិ មិយ្យតិ ច
បុនប្បុនំ សីវថិកំ ហរន្តិ
មគ្គញ្ច លទ្ធា អបុនព្ភវាយ
បុនប្បុនំ ជាយតិ ភូរិបញ្ញោតិ ។

ភ្លៀងបង្អុរចុះរឿយៗ ជនទាំងឡាយក៏ព្រោះពូជរឿយៗ អ្នកភ្ជួររាស់ទាំងឡាយ ភ្ជួររាស់ស្រែរឿយៗ តែងនាំស្រូវទៅកាន់ដែនក៏រឿយៗ ។ ស្មូមទាំងឡាយ សុំរឿយៗ ម្ចាស់ទានទាំងឡាយក៏ឱ្យរឿយៗ លុះម្ចាស់ទានទាំងឡាយឱ្យរឿយៗហើយ រមែងទៅកាន់ស្ថានសួគ៌ក៏រឿយៗ ។ អ្នករូតទឹកដោះគោទាំងឡាយ រូតរឿយៗ កូនគោចូលទៅរកមេគោក៏រឿយៗ អ្នកល្ងង់ខ្លៅលំបាកផង ញាប់ញ័រផងជារឿយៗ តែងចូលទៅកាន់គភ៌ក៏ជារឿយៗ សត្វលោករមែងកើត និងស្លាប់រឿយៗ គេនាំទៅកាន់ទីស្មសានក៏រឿយៗ ចំណែកអ្នកមានបញ្ញាដូចជាដែនដី បានសម្រេចនូវមគ្គហើយ រមែងមិនកើតក្នុងភពថ្មីទៀតរឿយៗឡើយ ។

ក្នុងទីបំផុតនៃធម៌ទេសនា ព្រាហ្មណ៍ព្រមទាំងបុត្រភរិយា ពួកមិត្រ និងញាតិ ក៏បានជ្រះថ្លា ថ្វាយបង្គំព្រះយុគលបាទនៃព្រះដ៏មានព្រះភាគជាអង្គម្ចាស់ ប្រកាសខ្លួនសុំដល់ព្រះរតនត្រ័យជាទីពឹងទីរលឹកស្មើដោយជីវិត តរៀងទៅ ។

ΓαΓαΓαΓαΓ
ΓαΓαΓαΓ
ΓαΓαΓ
ΓαΓ
Γ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ខុទ្ទកនិកាយ សុត្តនិបាត
## ត្រាស់តបបញ្ហាអាឡវកយក្ស

≈≈≈≈≈

α សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ ក្នុងលោកនេះ សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរសស្ត្រីគ្រប់គ្នា ។

α ធម្មោ សុចិណ្ណោ សុខមាវហាតិ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំនូវសេចក្តីសុខមកប្រគល់ឱ្យ ។

α សច្ចំ ហវេ សាធុតរំ រសានំ ពាក្យសច្ចៈមានរសឆ្ងាញ់ពិសា ជាងរសទាំងពួង ។

α បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ បណ្ឌិតហៅជីវិតដែលរស់នៅដោយបញ្ញា ថាជាជីវិតប្រសើរ ។

α សទ្ធាយ តរតី ឱឃំ បុគ្គលឆ្លងអន្លង់មិច្ឆាទិដ្ឋិបានដោយសទ្ធា ។

α អប្បមាទេន អណ្ណវំ ឆ្លងមហាសមុទ្រគឺសង្សារវដ្តបាន ដោយសេចក្តីមិនប្រមាទ ។

α វីរិយេន ទុក្ខមច្ចេតិ កន្លងរួចផុតអំពីសេចក្តីទុក្ខព្រោះកាមជាហេតុបាន ដោយការព្យាយាម ។

α បញ្ញាយ បរិសុជ្ឈតិ បរិសុទ្ធផុតចាកអវិជ្ជាបានដោយបញ្ញា ។

α សទ្ទហានោ អរហតំ ធម្មំ និព្វានបត្តិយា
សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ។

បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីសម្រេចដល់នូវព្រះនិព្វាន ជាអ្នកមិនប្រមាទ មានការពិចារណា ជាអ្នកស្តាប់ដោយល្អ រមែងបាននូវបញ្ញា ។

α បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ
សច្ចេន កិត្តឹ បប្បោតិ ទទំ មិត្តានិ គន្ថតិ ។

បុគ្គលមានការងារដ៏សមគួរ មានធុរៈគឺការព្យាយាមផ្លូវចិត្ត មានការប្រឹងប្រែងដោយកម្លាំងកាយ រមែងបាននូវទ្រព្យ បុគ្គលបានដល់នូវសេចក្តីសរសើរ ដោយសច្ចៈ បុគ្គលកាលឱ្យនូវទាន (មានសង្គហធម៌) រមែងចងនូវមិត្តទាំងឡាយបាន ។

α យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ
សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ

បុគ្គលណាមានសទ្ធា ហើយជាអ្នកនៅគ្រប់គ្រងផ្ទះ ជាអ្នកមាននូវធម៌ ៤ប្រការនេះគឺៈ សច្ចៈ (ដែលនាំឱ្យមានកេរ្តិ៍ឈ្មោះល្អ

ឬការសរសើរ) ១ , ធម្មៈ (ការហ្វឹកហាត់អប់រំទូន្មានចិត្តដោយសទ្ធា ដោយសេចក្តីមិនប្រមាទ ដោយការពិចារណា និងដោយការស្តាប់ល្អ ជាធម៌នាំឱ្យមានបញ្ញា) ១ , ធិតិ (ព្យាយាមដោយអំណត់អត់ធន់ ប្រឹងប្រែងធ្វើការងារដ៏សមគួរ ជាការងារប្រាសចាកនូវទោស ដើម្បីបានទ្រព្យសម្បត្តិប្រកបដោយធម៌) ១ ,ចាគៈ (សង្គហធម៌មានការបរិច្ចាគសម្បត្តិជួយអ្នកដទៃ ជាហេតុនៃការចងមិត្ត) ១ , បុគ្គលនោះឯង រមែងមិនមាននូវសេចក្តីសោកក្នុងលោកខាងមុខ ។

α ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

(បើថា ហេតុនៃកេរ្តិ៍ឈ្មោះល្អ មានធម៌ដទៃទៀតក្រៃលែងជាងសច្ចៈក្តី ហេតុនៃការបាននូវបញ្ញា មានធម៌ដទៃទៀតក្រៃលែងជាងទមៈគឺការទូន្មានខ្លួនឯងក្តី ហេតុនៃការចងមិត្ត មានធម៌ដទៃទៀតក្រៃលែងជាងចាគៈក្តី ហេតុនៃការបានទ្រព្យ មានធម៌ដទៃទៀតក្រៃលែងជាងខន្តីក្តី) បើមានធម៌ដទៃ ក្នុងលោកនេះ ឱ្យក្រៃលែងជាងសច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀតនោះ អញ្ជើញអ្នក ទៅសួរពួកសមណព្រាហ្មណ៍ជាច្រើននាក់ ដទៃផ្សេងទៀតចុះ ។

ព្រោះការស្តាប់ព្រះធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបបញ្ហាហើយ អាឡវកយក្សក៏បានសោតាបត្តិផល ។ ពេលចប់ព្រះពុទ្ធដីកា ដែលទ្រង់ត្រាស់ឱ្យយក្សសួរបញ្ហាចំពោះសមណព្រាហ្មណ៍ដទៃទៀតនោះ យក្សក៏បានពោលថា :

ឥឡូវនេះ ខ្ញុំព្រះអង្គចាំបាច់សួរពួកសមណព្រាហ្មណ៍ជាច្រើននាក់ ធ្វើអ្វីទៀត ព្រោះក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបានដឹងប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខច្បាស់លាស់ហើយ ព្រះសម្ពុទ្ធជាអង្គម្ចាស់ ទ្រង់ស្តេចយាងមកកាន់ដែនអាឡវី ដើម្បីគង់នៅ ជាប្រយោជន៍ដល់ខ្ញុំព្រះអង្គដោយពិត ក្នុងថ្ងៃនេះខ្ញុំព្រះអង្គបានដឹងច្បាស់ហើយថា ទានដែលបុគ្គលឱ្យហើយ ចំពោះព្រះសម្មាសម្ពុទ្ធអង្គណា គឺជាទានមានផលច្រើន ខ្ញុំព្រះអង្គនឹងត្រាច់ទៅអំពីស្រុកមួយ ចូលកាន់ស្រុកមួយទៀត អំពីបូរីមួយចូលកាន់បូរីមួយទៀត ហើយខ្ញុំព្រះអង្គនឹងថ្វាយបង្គំនូវព្រះសម្ពុទ្ធជាអង្គម្ចាស់ផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ដូច្នេះថា :

α ខ្ញុំព្រះអង្គសូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ព្រះអង្គទ្រង់ត្រាស់ដឹងដោយល្អ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

α ខ្ញុំព្រះអង្គសូមថ្វាយបង្គំចំពោះព្រះធម៌ ដែលព្រះដ៏មានព្រះភាគជាអង្គម្ចាស់ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ និង ជាព្រះធម៌ដែលព្រះដ៏មានព្រះភាគជាអង្គម្ចាស់ទ្រង់ត្រាស់ សំដែងទុកល្អហើយ ។

α ខ្ញុំព្រះអង្គសូមថ្វាយបង្គំចំពោះព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគជាអង្គម្ចាស់ ដែលបានបដិបត្តិដោយល្អ ។

**សរសេរចប់នៅថ្ងៃ ១កើត ខែ អស្សុជ ឆ្នាំ រោង**
**ទោស័ក ព.ស ២៥៤៤**













Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពាក្យផ្តើម

ខ្ញុំព្រះករុណា ខ្ញុំបាទបានសរសេរនូវកូនសៀវភៅតូចមួយនេះ ដាក់ឈ្មោះឱ្យថា ***មនុស្សជាមួយនឹងការងារ*** ក្នុងបំណងពង្រឹងនូវស្មារតីជនប្រុសស្រី ដើម្បីសេចក្តីមិនប្រមាទចំពោះកិច្ចការងារទាំងឡាយ ។

មនុស្សគ្រប់គ្នាស្រឡាញ់សេចក្តីសុខ ដូច្នេះត្រូវសិក្សាស្វែងយល់អំពីប្រភពនៃសេចក្តីសុខឱ្យបានច្បាស់ប្រាកដ កាលណាបើបានយល់ច្បាស់ហើយ ត្រូវប្រឹងប្រែងថែរក្សា និង បណ្តុះបណ្តាលនូវប្រភពនៃសេចក្តីសុខនោះ ឱ្យបានល្អតទៅ ។

សេចក្តីសុខដែលប្រាសចាកទោស គឺជាសេចក្តីសុខដ៏មានតម្លៃ ជាលទ្ធផលនៃការងារត្រូវ ការងារដោយប្រពៃ សេចក្តីសុខជាកុសលវិបាកគឺជាផលបុណ្យ សេចក្តីសុខក្នុងឈាន ព្រោះស្ងប់នីវរណធម៌ ឯចំណែកព្រះនិព្វាន ជាបរមសុខ ផុតចាកទុក្ខទាំងពួង។

ពុទ្ធបរិស័ទបានសម្រេចនូវព្រះនិព្វាន ដោយអាស្រ័យបាននូវអរិយមគ្គជាលោកុត្តរ អរិយមគ្គជាលោកុត្តរគឺជាសង្ខតធម៌ជាធម៌តាក់តែងដោយបច្ច័យច្រើនយ៉ាង ជាពិសេសឧបនិស្សយ-បច្ច័យ។ ឱ្យតែពុទ្ធបរិស័ទមានអធ្យាស្រ័យដើម្បីព្រះនិព្វាន ការងារដោយប្រពៃទាំងអស់ មិនថា ទាន សីល ឬ ភាវនាឡើយ សុទ្ធតែជាធម៌សម្រាប់តាក់តែងនូវលោកុត្តរកុសលដោយពិត ដូច្នេះសូមពុទ្ធបរិស័ទមានការពេញចិត្តនូវគ្រប់អំពើល្អទាំងអស់ ។ រាល់ពេលដែលប្រកបកិច្ចការងារជាកុសលនោះៗ ត្រូវដឹងខ្លួនឯងថា ដូចជាកំពុងចម្រើននូវអរិយមគ្គប្រកបដោយអង្គ៨ដែរ ព្រោះអរិយមគ្គមិនអាចពេញទៅបានទេ បើខ្វះនូវការសន្សំបុណ្យ ឬការសន្សំបុណ្យនោះពុំទាន់បានគ្រប់គ្រាន់នៅឡើយ ។

អ្នកធ្វើដំណើរ ត្រូវដឹងអំពីទិសដៅដែលត្រូវទៅ អ្នកធ្វើការងារ ត្រូវដឹងអំពីលទ្ធផលរបស់ការងារ ។

អ្នកបួសធ្ងន់ក្នុងលាភយសមិនបវរ គ្រហស្ថគ្មានរបរមិនថ្លៃថ្នូរ ។

សូមពុទ្ធបរិស័ទ ដាំផ្កា ក្រងផ្កាគឺកុសល បូជាដល់ព្រះរតនត្រ័យ សូមពុទ្ធបរិស័ទអុជធូបក្រអូបគឺការសមាទានសីលបូជាដល់ព្រះរតនត្រ័យ សូមពុទ្ធបរិស័ទអុជនូវប្រទីបគឺការចម្រើនបញ្ញា ការពារខ្យល់ ការពារសត្វកុំឱ្យពន្លត់នូវភ្លើងប្រទីបនោះ



Document Produced by deskPDF Unregistered :: http://www.docudesk.com

ដោយការចម្រើនសេចក្តីស្ងប់នីវរណធម៌ នេះគឺជាសក្ការបូជាដ៏បវរ ថ្លៃថ្លា សម្រាប់បូជាថ្វាយព្រះត្រៃរតន៍ ។

សូមឱ្យពុទ្ធបរិស័ទបានរីករាយនៅក្នុងការអានកូនសៀវភៅមួយនេះ សូមឱ្យសត្វលោកទាំងឡាយបានមកជាពុទ្ធបរិស័ទ ហើយបានសម្រេចនូវធម៌ដែលព្រះអរិយៈទាំងពួង បានសម្រេចហើយ ។

**ថ្ងៃអង្គារ ១១រោច ខែ អស្សុជ ឆ្នាំរោង**

**ទោស័ក ព.ស ២៥៤៤**

**ខ្ញុំព្រះករុណា**

**ខ្ញុំបាទ ប៊ុត សាវង្ស**



Document Produced by deskPDF Unregistered :: http://www.docudesk.com

# រាយនាមម្ចាស់ដើមបុណ្យបច្ច័យ ៤

≈≈≈≈≈

α នៅក្នុងពិធីបុណ្យឆ្លងព្រះធម្មចេតិយ ព្រះពោធិព្រឹក្ស ក្នុងមណ្ឌលសាលារៀនសតិប្បដ្ឋានខេត្តបាត់ដំបង មានរៀបចំ បច្ច័យ៤ ដាក់បាត្រព្រះសង្ឃ៥០០អង្គ សំដែងធម៌ទេសនា ព្រម ទាំងអញ្ជើញភ្ញៀវពិសានូវភោជនាហារ ម្ចាស់ដើមបុណ្យត្រូវបាន បរិច្ចាគប្រាក់អស់ជាងពីរម៉ឺនដុល្លារអាមេរិក ក្នុងនោះមានសៀវភៅ ធម៌នេះចំនួនមួយម៉ឺនក្បាលសំរាប់ចែកជាធម្មទានទៀតផង ក្នុងតម្លៃ បោះពុម្ពសរុប ៣២០០USD សូមទានជ្រាប និង អនុមោទនា បុណ្យពីម្ចាស់ដើមបុណ្យ ដូចខាងក្រោម :

១- លោកគ្រូ ប៊ុត សាវង្ស

២- ភិក្ខុ មាស ផុន បរិបុណ្ណោ ចៅអធិការវត្ត ពុទ្ធិការាម រដ្ឋម៉ារីឡែន

៣- ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ ចៅអធិការ វត្ត រាជបូណ៌ ខេត្តសៀមរាប

៤- ឧបាសក រស់ សូផាត លោកគ្រូបង្រៀនធម៌នៅសាលា រៀនសតិប្បដ្ឋាន ខេត្តបាត់ដំបង

(ភិក្ខុ ២អង្គ និង លោកគ្រូ ២នាក់ខាងលើនេះ ម្ចាស់ដើម បុណ្យខាងក្រោម ជាអ្នកបរិច្ចាគប្រាក់ជំនួសទាំងអស់ )

៥- ឧបាសក ឆាយ អ៊ីវស៊ាង និង ឧបាសិកា ហុង គីមសែ

៦- ឧបាសក យូសៀង ងួនលី និង ឧបាសិកា លីម ឃីម

៧- ឧបាសក ឡុង ហុកសូ និង ឧបាសិកា តាន់ ជីវហា

៨- ឧបាសក ហៀប បេ និង ឧបាសិកា ឡៅ កែវម្លិះ

៩- ឧបាសក ខេង ស៊ុនឆាយ និងឧបាសិកា គីម ស្រ៊ុនឆាយ

១០- ឧបាសក យុក ហៀង និង ឧបាសិកា យា យុកហួ

១១- ឧបាសក អ៊ុន ឆាយគ្រី និង ឧបាសិកា ទី គីមប៊ួយ

១២- ឧបាសិកា អៀប ផៃហុង

១៣- ឧបាសក ឆាយ អ៊ីវស្រេងលីម និងឧបាសិកា ហួត ឃីម

១៤- ឧបាសិកា ហុង គីមអេង

១៥- ឧបាសិកា សុខ លន់

១៦- ឧបាសក ហៃ ប៊ុនណារិន និង ឧបាសិកា អោង ស៊ីថាន់

១៧- ឧបាសិកា ឈិត ហ៊ួរ



Document Produced by deskPDF Unregistered :: http://www.docudesk.com

១៨-  ឧបាសក សយ ញឹម និង ឧបាសិកា មួង ស៊ីវ៉ូ

១៩-  ឧបាសក ស៊ីន ម៉ៅ និង ឧបាសិកា ឈឹម ណារ៉ែន

(ទាំង ១៩ គ្រួសារខាងលើនេះ ជាពុទ្ធបរិស័ទនៅ សហរដ្ឋអាមេរិក)

២០-  ពុទ្ធបរិស័ទក្នុងសាលារៀនសតិប្បដ្ឋានទាំងអស់គ្នា ។

បោះពុម្ពមួយម៉ឺនក្បាលជាធម្មទាន ក្នុងពិធីបុណ្យឆ្លងព្រះធម្មចេតិយ ព្រះពោធិព្រឹក្ស ក្នុងមណ្ឌលសាលារៀនសតិប្បដ្ឋាន ខេត្តបាត់ដំបង នៅថ្ងៃ ១៥កើត ខែ កត្តិក ឆ្នាំ រោង ទោស័ក ព.ស ២៥៤៤

**សូមអនុមោទនា!**



**បុរាណភាសិតខ្មែរ**

*អ្នកធំកុំមើលងាយអ្នកតូច ស្មៅវល្លិវេញក្ងួចចងដំរី*

*ស្តេចពឹងរាស្ត្រសង្ឃពឹងវិន័យ មច្ឆាជលស័យពិតពឹងទឹក*



Document Produced by deskPDF Unregistered :: http://www.docudesk.com